**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# លំហូរនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ឃន ប៉េងឡុង**

**ឈឹន សុវណ្ណនរាជ**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រៈ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំបញ្ចប់ការសិក្សា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យន ម៉េងឡុង** និង **ឈឹន សុវណ្ណនារាជ** ជានិស្សិតឆ្នាំទី៤ មហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០២០-២០២១ ជំនាន់ទី២១។

**សូមលំអោនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកតញ្ញូតាធម៌ និងកតវេទីយ៉ាង ខ្ពង់ខ្ពស់ចំពោះជីដូន ជីតា ក្រុមគ្រួសារ ជាពិសេសមាតាបិតា៖**

**លោក សួ ប៉ុណ្ណារ៉ុង** **លោក ឈឹន សុខា**

**លោកស្រី ម៉ែន ម៉ុនរឿន** **លោកស្រី ទឹម សុចិន្តា**

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងទូន្មានប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗឲ្យកូនៗធ្វើជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អនៅក្នុងសង្គមប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានលើកទឹកចិត្តផ្នែកស្មារតី និងគាំទ្រផ្នែកធនធានដែលជាហេតុធ្វើឲ្យយើងខ្ញុំបានបន្តការសិក្សាគ្រប់ភូមិសិក្សារហូតមកដល់ឆ្នាំទី៤ នៃថ្នាក់បរិញ្ញាបត្រនេះប្រកបដោយភាពជោគជ័យ។

**សូមគោរពថ្លែងអំណរគុណផងដែរចំពោះ ៖**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាប្រមុខរាជរដ្ឋាភិបាលដោយបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីដឹកនាំប្រទេសជាតិឲ្យមានភាពរុងរឿង សន្តិភាព និងរីកចម្រើនលើគ្រប់វិស័យ។
- **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាលា និងមន្ត្រីគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំក្នុងការដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀន និងសម្របសម្រួល ណែនាំដល់យើងខ្ញុំឲ្យទទួលបាននូវចំណេះដឹង បទពិសោធន៍យ៉ាងច្រើនអនេកទាំងក្នុងវិស័យនីតិសាស្ត្រ និងក្នុងវិស័យយុត្តិធម៌ជាពិសេសទទួលបាននូវការតម្រង់ទិស ដែលបានធ្វើឲ្យយើងខ្ញុំក្លាយជាយុវជន និស្សិត និងពលរដ្ឋល្អនៅក្នុងសង្គមដើម្បីជាសសរទ្រូងដ៏រឹងមាំមួយនៃសង្គមជាតិទាំងមូលក្នុងបរិបទសកលភាវូបនីយកម្មនេះ។
- លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ជាសាស្ត្រាចារ្យណែនាំ ដែលលោកបានចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃរបស់លោកក្នុងការបង្ហាត់បង្ហាញណែនាំផ្តល់នូវគំនិតដំបូន្មានល្អៗ កែសម្រួល និងត្រួតពិនិត្យ ព្រមទាំងលើកទឹកចិត្តដល់យើងខ្ញុំក្នុងការស្រាវជ្រាវ និងតាក់តែងសារណាបញ្ចប់ការសិក្សាមួយនេះឡើង។
- លោក **ខឿន ម៉េងហេង** ជាមិត្តនិស្សិតរួមជំនាន់ ដែលបានជួយរៀបចំ សម្រិតសម្រាំងផ្នែកបច្ចេកទេស និងរចនាបទនានាក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ ដើម្បីញ៉ាំងឲ្យស្នាដៃនេះកាន់តែមានសោភណ្ឌភាព និងសមស្របទៅតាមលក្ខណៈស្តង់ដារ ដែលសាកលវិទ្យាល័យបានកំណត់។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យដល់មាតាបិតា ជីដូនជីតា ក្រុមគ្រួសារ អាណាព្យាបាល ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាលា និងមន្ត្រីគ្រប់ផ្នែកទាំងអស់ឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

ការសិក្សាជំនាញនីតិសាស្ត្រអស់រយៈពេល៤ ឆ្នាំមកនេះ ជាវឌ្ឍនភាពថ្មីមួយនៅលើវិថីនៃជីវិតសិក្សារបស់យើងខ្ញុំ។ ដោយមានការកំណត់នូវចក្ខុវិស័យ ការខិតខំប្រឹងប្រែងព្យាយាមរៀនសូត្រប្រកបដោយភាពអត់ធ្មត់ ស្មារតីយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ ព្រមទាំងទទួលបានការលើកទឹកចិត្ត ការផ្តល់ចំណេះដឹង ការចែករំលែកនូវបទពិសោធន៍ និងដំបូន្មានល្អៗពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យបានធ្វើឲ្យយើងខ្ញុំទាំងពីររូបទទួលបាននូវកាលានុវត្តភាព ព្រមទាំងការអនុញ្ញាតពីសាកលវិទ្យាល័យក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**លំហូរនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌ**" ដែលបានកើតចេញពីការខិតខំសិក្សាស្រាវជ្រាវនាពេលកន្លងមកនេះ។ ការស្រាវជ្រាវទៅលើប្រធានបទនេះ មានកម្មវត្ថុដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅនូវនីតិវិធីក្នុងការដោះស្រាយនូវរឿងក្តីព្រហ្មទណ្ឌរបស់តុលាការកម្ពុជាពីដំណាក់កាលដំបូងនៃការដាក់ពាក្យបណ្តឹង រហូតដល់ការចេញសាលក្រមរបស់សាលាជម្រះក្តីជាន់ទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រធានបទស្តីពី "**លំហូរនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌ**" គឺជាការខិតខំស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ ដោយទុកជាអនុស្សាវរីយ៍ដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយទុកជាគំរូឯកសារក្នុងការសិក្សាស្រាវជ្រាវស្វែងយល់បន្តទៀត។ ជាពិសេសប្រធានបទ និងខ្លឹមសារនៃសារណានេះ ត្រូវបានតាក់តែងឡើងដោយផ្អែកទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយរបស់កម្ពុជា ព្រមទាំងសៀវភៅឯកសារចងក្រងជាច្រើនទៀតរបស់អ្នកជំនាញ និងសាស្ត្រាចារ្យល្បីៗផ្នែកនីតិសាស្ត្រនៅកម្ពុជា។ ម្យ៉ាងវិញទៀត សារណានេះអាចលេចចេញជារូបរាងបានដោយសារមានការជួយជ្រោមជ្រែង ជម្រុញ និងគាំទ្រពីលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំផ្តល់អនុសាសន៍ល្អៗ និងត្រួតពិនិត្យក្នុងគោលដៅញ៉ាំងឲ្យសារណាបញ្ចប់ការសិក្សានេះមានលក្ខណៈល្អប្រសើរទាំងផ្នែកអក្ខរាវិរុទ្ធ និងផ្នែកអត្ថន័យប្រកបដោយសុក្រឹត្យភាព និងការវាយតម្លៃខ្ពស់។

ជាការពិតណាស់ សារណាបញ្ចប់ការសិក្សានេះ ប្រាកដជាមាននូវចំណុចខ្វះខាតមួយចំនួនជាក់ជាពុំខាន។ អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាននានា ក្នុងករណីដែលនៅក្នុងស្នាដៃនេះមានកំហុសខុសឆ្គងត្រង់ប្រការណាមួយទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធរួមទាំងចំណុចលើសលស់ ខ្វះខាត ឬខ្លឹមសារមិនពិស្តារត្រង់ចំណុចណាមួយដែលបានកើតឡើងដោយអចេតនា។

ជាទីបញ្ចប់ យើងខ្ញុំពិតជាសេចក្តីសោមនស្សរីករាយ ក្នុងការទទួលយកនូវរាល់មតិរិះគន់ ការទិតៀននានាក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានជុំវិញ ដើម្បីជាការកែលម្អនូវរាល់កំហុសឆ្គង ចំណុចខ្វះខាត ក៏ដូចជាចូលចុងបញ្ចប់ក្នុងនាមយើងខ្ញុំទាំងពីរជាអ្នករៀបរៀងនូវសារណាមួយនេះឡើងមកក្នុងគោលបំណងដែលសង្ឃឹមថាស្នាដៃមួយនេះនឹងក្លាយជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងជាជំនួយដល់ការពង្រីកចំណេះដឹងបន្ថែមដល់និស្សិតដែលកំពុងសិក្សាទៅតាមតម្រូវការរៀងៗខ្លួន។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ដំណាក់កាលមុនដាក់ពាក្យបណ្តឹង**

**១.១. មូលហេតុនៃការដាក់ពាក្យបណ្តឹង** ........ ៤

**១.២. ភាគីនៅក្នុងរឿងក្តី** ........ ៤

១.២.១. ជនល្មើស ........ ៤

១.២.២. ជនរងគ្រោះ ........ ៥

១.២.៣. ដើមបណ្តឹងរដ្ឋប្បវេណី ........ ៦

១.២.៤. អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ........ ៦

**ជំពូកទី២**

**ដំណាក់កាលពេលដាក់ពាក្យបណ្តឹង**

**២.១. លក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹង** ........ ៧

២.១.១. បុគ្គល ........ ៧

២.១.២. អត្ថិភាពនៃបទល្មើស ........ ៧

២.១.៣. ព្យសនកម្មនៃបទល្មើស ........ ៧

**២.២. ប្រភេទនៃបណ្តឹង** ........ ៧

២.២.១. បណ្តឹងអាជ្ញា ........ ៨

២.២.២. បណ្តឹងរដ្ឋប្បវេណី ........ ៨

**២.៣. ការដាក់ពាក្យបណ្តឹង** ........ ៩

**២.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលបណ្តឹង** ........ ១០

២.៤.១. អង្គភាពនគរបាលយុត្តិធម៌ ........ ១០

២.៤.២. ស្ថាប័នអយ្យការ ........ ១០

**ជំពូកទី៣**

**ដំណាក់កាលនីតិវិធីនៃបណ្តឹង**

**៣.១. ដំណាក់កាលអយ្យការ** ........ ១២

**៣.១.១. សញ្ញាណទូទៅនៃអង្គការអយ្យការ** ..... ១២

**៣.១.២. លក្ខខណ្ឌនៃការចោទប្រកាន់** ..... ១២

**៣.១.៣. សេចក្តីសម្រេចរបស់អយ្យការ** ..... ១៣

៣.១.៣.១. ការតម្កល់រឿងទុកឥតចាត់ការ ..... ១៣

៣.១.៣.២. ជម្រើសនៃការចោទប្រកាន់ ..... ១៦

៣.១.៣.២.១. ការបើកការស៊ើបសួរ ..... ១៦

៣.១.៣.២.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..... ១៧

៣.១.៣.២.៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ..... ១៩

**៣.២. ដំណាក់កាលចៅក្រមស៊ើបសួរ** ..... ២០

**៣.២.១. ការទទួលពាក្យបណ្តឹង** ..... ២១

៣.២.១.១. តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ..... ២១

៣.២.១.២. តាមរយៈពាក្យបណ្តឹងពីជនរងគ្រោះ ..... ២២

**៣.២.២. ដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ** ..... ២៤

**៣.២.៣. ការបើកការស៊ើបសួរ** ..... ២៤

**៣.២.៤. ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ..... ២៥

៣.២.៤.១. ការជូនដំណឹងដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ ..... ២៦

៣.២.៤.២. ការសួរចម្លើយជនត្រូវចោទ ..... ២៦

៣.២.៤.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ..... ២៧

៣.២.៤.៤. ការស្តាប់ចម្លើយរបស់សាក្សី ..... ២៨

៣.២.៤.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង ..... ២៩

៣.២.៤.៦. ការធ្វើកោសលវិច័យ ..... ៣០

៣.២.៤.៧. ការស្តាប់ទូរស័ព្ទ ..... ៣១

**៣.២.៥. ការចាត់ឲ្យស៊ើបសួរជំនួស** ..... ៣២

**៣.២.៦. វិធានការនិរន្តរាយ** ..... ៣២

៣.២.៦.១. វិធានការធានាឲ្យមានវត្តមានជនត្រូវចោទនៅមុខចៅក្រមស៊ើបសួរ ..... ៣៣

៣.២.៦.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន ..... ៣៣

៣.២.៦.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន ..... ៣៤

៣.២.៦.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន ..... ៣៤

៣.២.៦.១.៤. ដីកាបង្គាប់ឲ្យឃុំខ្លួន ........ ៣៥
៣.២.៦.២. វិធានការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ........ ៣៥
៣.២.៦.៣. វិធានការរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ ........ ៣៦
៣.២.៦.៣.១. ការឃុំខ្លួនបណ្ដោះអាសន្ន ........ ៣៦
៣.២.៦.៣.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩
**៣.២.៧. ការបិទការស៊ើបសួរ** ........ ៤១
៣.២.៧.១. ការបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា ........ ៤១
៣.២.៧.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ........ ៤២
៣.២.៧.៣. ដីកាដំណោះស្រាយ ........ ៤២
៣.២.៧.៣.១. ដីកាលើកលែងចោទប្រកាន់ ........ ៤២
៣.២.៧.៣.២. ដីកាបញ្ជូនទៅជំនុំជម្រះ ........ ៤៣
**៣.៣. ដំណាក់កាលជំនុំជម្រះ** ........ ៤៣
**៣.៣.១. ដំណាក់កាលមុនពេលជំនុំជម្រះ** ........ ៤៣
៣.៣.១.១. ការទទួលបណ្ដឹងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ........ ៤៣
៣.៣.១.២. ការទទួលបណ្ដឹងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ៤៤
៣.៣.១.៣. ការទទួលបណ្ដឹងតាមរយៈកំណត់ហេតុចូលបង្ហាញខ្លួនភ្លាម ........ ៤៤
**៣.៣.២. ដំណាក់កាលពេលជំនុំជម្រះ (សវនាការ)** ........ ៤៥
៣.៣.២.១. សមាសភាពក្នុងសវនាការ ........ ៤៥
៣.៣.២.១.១. សមាសភាពជំនុំជម្រះ ........ ៤៥
៣.៣.២.១.២. សមាសភាពភាគី ........ ៤៦
៣.៣.២.២. ដីកាកោះហៅឲ្យចូលសវនាការ ........ ៤៧
៣.៣.២.៣. ការចូលខ្លួនរបស់ភាគី ........ ៤៧
៣.៣.២.៣.១. ការចូលខ្លួនរបស់ជនជាប់ចោទ ........ ៤៧
៣.៣.២.៣.២. ការចូលខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ........ ៤៨
៣.៣.២.៣.៣. ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែកបណ្ដឹងរដ្ឋប្បវេណី ........ ៤៨
៣.៣.២.៣.៤. ការចូលខ្លួនរបស់សាក្សី ........ ៤៩
៣.៣.២.៤. កិច្ចដេញដោលក្នុងពេលជំនុំជម្រះ ........ ៤៩
៣.៣.២.៥. សក្ខីកម្ម និងភស្តុតាង ........ ៤៩

៣.៣.២.៦. សេចក្ដីសន្និដ្ឋានចុងក្រោយ ..... ៥០
**៣.៤. សេចក្ដីសម្រេចរបស់សាលាដំបូងរាជធានី-ខេត្ត** ..... ៥០
**៣.៤.១. ការពិភាក្សាសម្រេច** ..... ៥០
**៣.៤.២. ការប្រកាសសាលក្រម** ..... ៥០
៣.៤.២.១. ការតាក់តែងសាលក្រម ..... ៥០
៣.៤.២.២. ការជូនដំណឹងពីសាលក្រម ..... ៥២
៣.៤.២.២.១. សាលក្រមចំពោះមុខ ..... ៥២
៣.៤.២.២.២. សាលក្រមដែលចាត់ទុកថាចំពោះមុខ ..... ៥២
៣.៤.២.២.៣. សាលក្រមកំបាំងមុខ ..... ៥៣

## ជំពូកទី៤

## ដំណាក់កាលក្រោយចេញសាលក្រម

**៤.១. ការអនុវត្តទោស** ..... ៥៤
**៤.១.១. ទិដ្ឋភាពទូទៅនៃការអនុវត្ត** ..... ៥៤
៤.១.១.១. មូលទោស ..... ៥៥
៤.១.១.២. អនុទោស ឬទោសបន្ថែម ..... ៥៥
៤.១.១.៣. ទោសជំនួស ..... ៥៦
**៤.១.២. ការប្រតិបត្តិការឃុំខ្លួនបណ្ដោះអាសន្ន និងទោសដកហូតសេរីភាព** ..... ៥៧
៤.១.២.១. វិធានទាក់ទងនឹងការឃុំខ្លួន ..... ៥៧
៤.១.២.២. ការដោះលែងដោយមានលក្ខខណ្ឌ ..... ៥៨
**៤.១.៣. ការបង្ខំដល់រូបកាយ** ..... ៥៩
**៤.១.៤. ការផ្ដល់ និងការមាននីតិសម្បទាឡើងវិញ** ..... ៦២
៤.១.៤.១. ការផ្ដល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ..... ៦២
៤.១.៤.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់ ..... ៦៣
**៤.២. បណ្ដឹងទាស់** ..... ៦៣
**៤.២.១. បុគ្គលដែលមានសិទ្ធិប្ដឹងទាស់** ..... ៦៤
៤.២.១.១. ពិរុទ្ធជន ..... ៦៤
៤.២.១.២. ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ..... ៦៥
**៤.២.២. នីតិវិធី និងបែបបទនៃបណ្ដឹង** ..... ៦៥

៤.២.៣. ប្រភេទនៃសេចក្តីសម្រេចរបស់តុលាការ ........ ៦៧

**៤.៣. បណ្តឹងឧទ្ធរណ៍** ........ ៦៧

៤.៣.១. បុគ្គលដែលអាចប្តឹងឧទ្ធរណ៍ ........ ៦៧

៤.៣.២. រយៈពេលនៃការប្តឹងឧទ្ធរណ៍ ........ ៦៨

**សេចក្តីសន្និដ្ឋាន** ........ ៧០

**អនុសាសន៍** ........ ៧១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានបង្កើតឲ្យមាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈព្រះរាជក្រមលេខ **នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧** ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧។ នីតិវិធីព្រហ្មទណ្ឌសំដៅលើដំណើរការនៃការប្រព្រឹត្តទៅនៅក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ហើយវានឹងបង្ហាញដល់អ្នកសិក្សាឲ្យយល់ដឹងពីការអនុវត្តនីតិវិធី និងវិធានទាំងឡាយ ដែលបានបកស្រាយដោយភាគីដែលបានចូលរួមនៅក្នុងដំណើរការនៃកិច្ចរបស់តុលាការ។ នីតិវិធី និងវិធានទាំងនោះមានប្រភពពីច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិដែលរួមមានសន្ធិសញ្ញា អនុសញ្ញា និងពិធីសារផ្សេងៗទៀត។ ក្រៅពីនោះមានច្បាប់ លិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលសភា និងស្ថាប័ននានារបស់កម្ពុជាបានអនុម័ត។

នៅក្នុងនីតិវិធីព្រហ្មទណ្ឌមានកំណត់យ៉ាងច្បាស់លាស់អំពីទម្រង់នៃបណ្តឹង និងបែបបទនៃការធ្វើបណ្តឹងដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រព័ន្ធយុត្តាធិការនៅប្រទេសកម្ពុជា។ លំហូរនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌគឺជាកិច្ចស្រាវជ្រាវដែលបានបង្ហាញអំពីនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌ ដែលរៀបរាប់ចាប់ពីការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ និងមុខងារនៃអង្គការអយ្យការ ចៅក្រមស៊ើបសួរ រហូតដល់ចៅក្រមជំនុំជម្រះដែលចេញនូវសេចក្តីសម្រេច ដែលមានច្រើនដំណាក់កាលទម្រាំនឹងដល់នូវកិច្ចបញ្ចប់ចុងក្រោយ និងដែលរៀបរាប់អំពីលំហូរនៃនីតិវិធីជំនុំជម្រះនៅសាលាដំបូង(តុលាការជាន់ទាប) ព្រមទាំងការប្តឹងតវ៉ាទៅកាន់សាលាឧទ្ធរណ៍ដែលជាតុលាការជាន់ខ្ពស់។ ដំណាក់កាលទាំងអស់នេះមានលក្ខណៈស្មុគស្មាញ ដោយត្រូវឆ្លងកាត់នូវច្រើននីតិវិធី ហេតុនេះហើយទើបប្រធានបទនេះតម្រូវអោយមានការវែកញែកនៃនីតិវិធីនីមួយៗឲ្យបានច្បាស់លាស់ និងដាច់ដោយឡែកពីគ្នា ដើម្បីជាភាពងាយស្រួលនៅក្នុងការសិក្សាស្វែងយល់នូវនីតិវិធីនីមួយៗខាងលើនេះ។

ហេតុដូចដែលបញ្ជាក់ពីខាងលើនេះហើយ ទើបយើងខ្ញុំធ្វើការបកស្រាយឲ្យបានច្បាស់លាស់បន្ថែមចំពោះចំណុចនីមួយៗអំពីកិច្ចការសារណានេះទៅតាមកម្រិតថ្នាក់បរិញ្ញាបត្រសម្រាប់និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីជាការចែករំលែកជាចំណេះដឹងជូនដល់មិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយណាដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវស្វែងយល់ពីលំហូរនីតិវិធីនៃដោះស្រាយរឿងក្តីព្រហ្មទណ្ឌនេះ ដើម្បីជាចំណេះដឹង និងជាពិសេសសម្រាប់អ្នកដែលចង់ខ្លួនជាអ្នកអនុវត្តច្បាប់ផ្នែកយុត្តាធិការជាដើម។

## ២. ចំណោទបញ្ហា

ដើម្បីជាការយល់ដឹងឲ្យបានកាន់តែច្បាស់លាស់ស៊ីជម្រៅនូវលំហូរនីតិវិធីក្នុងការដោះស្រាយរឿងក្តីនៃបណ្តឹងព្រហ្មទណ្ឌ យើងត្រូវដឹងនូវការចំណុចសំខាន់ៗមួយចំនួន ដែលជាគោលការណ៍ពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីតួនាទីតួអង្គដែលសំខាន់ៗក្នុងដំណើរការនៃនីតិវិធីខាងលើដូចជា៖

- តើមូលហេតុអ្វីទើបបានជាមាននូវបណ្តឹងកើតឡើង?
- តើបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌមានប៉ុន្មានប្រភេទ?
- តើវិធីសាស្ត្រធ្វើបណ្តឹងនីមួយៗត្រូវធ្វើឡើងយ៉ាងដូចម្តេច?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌជាអ្វី?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌមានតួអង្គសំខាន់ណាខ្លះ?
- តើតួអង្គសំខាន់ក្នុងដំណើរការរឿងក្តីនោះមានតួនាទីក្នុងការអនុវត្តនីតិវិធីដូចម្តេចខ្លះ?
- តើគេអាចប្តឹងតវ៉ានឹងសេចក្តីសម្រេចបានដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានគោលបំណងក្នុងការចែករំលែកនូវពុទ្ធិចំណេះដឹងខ្លះៗក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌដែលជានីតិវិធីរបស់តុលាការដែលមានសារៈប្រយោជន៍យ៉ាងសំខាន់ណាស់ក្នុងប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចការស្រាវជ្រាវមួយនេះ គឺជាស្នាដៃមួយដែលបានតាក់តែងឡើង ដើម្បីទុកជាជំនួយដល់និស្សិតមិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយណា ដែលចង់ស្វែងយល់ពីដំណើរការរឿងក្តីព្រហ្មទណ្ឌដែលជានីតិវិធីនៃតុលាការរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

កិច្ចការសិក្សាស្រាវជ្រាវនៃសារណាបញ្ចប់ឆ្នាំសិក្សាមួយនេះ ផ្តោតសំខាន់ទៅលើដំណើរការដោះស្រាយរឿងក្តីព្រហ្មទណ្ឌរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជាទៅតាមដំណាក់កាល ដែលចាប់ផ្តើមតាំងពីដំណាក់កាលដំបូងពេលគឺការដាក់ពាក្យបណ្តឹង រហូតដល់មានការជំនុំជម្រះ ហើយបានចេញនូវសេចក្តីសម្រេចរបស់តុលាការ។ កិច្ចការស្រាវជ្រាវនេះក៏នឹងបង្ហាញអំពីតួនាទី និងភារកិច្ចរបស់តួអង្គនីមួយៗនៅក្នុងសាលាជម្រះក្តីនៅពេលដែលខ្លួនបានទទួលនូវពាក្យបណ្តឹង ហើយនឹងមានចំណាត់ការស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងវិជ្ជាជីវៈរបស់ខ្លួនទៅតាមមុខងារផ្សេងៗគ្នា។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានឯកសារ និងព័ត៌មានទាំងអស់ដើម្បីយកមកចងក្រងឯកសារ គឺបានឆ្លងកាត់ការស្រាវជ្រាវដោយប្រើប្រាស់ឯកសារជាចម្បងមួយចំនួនដូចជាច្បាប់រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត និងតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរពិគ្រោះសុំយោបល់ពីសំណាក់លោកសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់នូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់ប្រធានបទយើងខ្ញុំ។ បន្ទាប់ពីទទួលបានឯកសារ និងព័ត៌មានទាំងអស់នេះហើយគឺត្រូវបានយកមកពិនិត្យមុននឹងជ្រើសរើសមកចងក្រងជាខ្លឹមសារសម្រាប់អត្ថបទមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ ត្រូវបានបែងចែកដូចខាងក្រោម ៖

- សេចក្តីផ្តើម
- ជំពូកទី១ ស្តីពីដំណាក់កាលមុនដាក់ពាក្យបណ្តឹង
- ជំពូកទី២ ស្តីពីដំណាក់កាលពេលដាក់ពាក្យបណ្តឹង
- ជំពូកទី៣ ស្តីពីដំណាក់កាលនីតិវិធីនៃបណ្តឹង
- ជំពូកទី៤ ស្តីពីដំណាក់កាលក្រោយចេញសាលក្រម។

# ជំពូកទី១
# ដំណាក់កាលមុនដាក់
# ពាក្យបណ្តឹង

# ជំពូកទី១
# ដំណាក់កាលមុនពេលដាក់ពាក្យបណ្ដឹង

## ១.១. មូលហេតុនៃការដាក់ពាក្យបណ្ដឹង

ជាការពិតណាស់ បទល្មើសព្រហ្មទណ្ឌបានបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់បុគ្គលព្រមទាំងសង្គមជាតិទាំងមូល។ ដូចនេះច្បាប់បានបង្កើតគោលការណ៍ និងនីតិវិធីនៃការធ្វើបណ្ដឹងដើម្បីបង្ការ និងទប់ស្កាត់នូវរាល់អំពើល្មើសទាំងនោះ។ បណ្ដឹងដែលបានធ្វើឡើងនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយ គឺមានគោលបំណងដើម្បីចាប់ខ្លួនបុគ្គលដែលបានប្រព្រឹត្តបទល្មើសយកមកផ្ដន្ទាទោសទៅតាមផ្លូវច្បាប់ ព្រមទាំងផ្ដល់នូវសំណងទាំងឡាយចំពោះព្យសនកម្មដែលបានបង្កឡើងដោយអំពើនោះ។[1]

ដោយសារបទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសង្គមជាសាធារណៈយ៉ាងដូច្នេះ បុគ្គលគ្រប់រូបអាចធ្វើបណ្ដឹងព្រហ្មទណ្ឌបាន។ ចំណែកឯការផ្ដន្ទាទោសដល់ជនល្មើសគឺស្ថិតក្រោមការកំណត់ដោយច្បាប់ជាធរមាន។ ដោយឡែកសំណងចំពោះព្យសនកម្មដែលបានកើតឡើងដោយបទល្មើសនោះ គឺកើតចេញតាមរយៈការទាមទាររបស់ជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ។ តាមរយៈការលើកឡើងខាងលើនេះ អាចបង្ហាញឲ្យឃើញថានៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយមានការកើតឡើងនូវបណ្ដឹងជាពីរទម្រង់ គឺការប្ដឹងដាក់ទោសជនល្មើស និងការប្ដឹងទាមទារសំណងចំពោះព្យសនកម្មដែលបានកើតឡើងចំពោះជនរងគ្រោះ។

## ១.២. ភាគីនៅក្នុងរឿងក្ដី

### ១.២.១. ជនល្មើស

ជនល្មើសអាចជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានប្រព្រឹត្តនូវអំពើល្មើសច្បាប់ណាមួយ ដែលខ្លួនត្រូវទទួលខុសត្រូវចំពោះអំពើដែលបានកើតឡើងនោះតាមច្បាប់កំណត់។ ផ្អែកតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ការប្រើប្រាស់វាក្យស័ព្ទចំពោះជនដែលប្រព្រឹត្តបទល្មើសនេះមានខុសៗគ្នា ដោយផ្អែកលើដំណាក់កាលនីមួយៗនៃនីតិវិធីបណ្ដឹងក្នុងគោលបំណងសម្រាប់សម្គាល់ដំណាក់កាលនីតិវិធី ដោយប្រើប្រាស់នូវបច្ចេកស័ព្ទគតិយុត្តឲ្យសមស្របទៅនឹងដំណាក់កាលនីតិវិធីនីមួយៗខុសៗពីគ្នា។[2] បច្ចេកស័ព្ទគតិយុត្តនេះបានបញ្ជាក់អំពីអត្ថន័យនៃពាក្យនីមួយៗដូចខាងក្រោម៖

- **ជនសង្ស័យ** សំដៅលើជនដែលត្រូវបានគេប្ដឹងនៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬដំណាក់កាលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា។[3]

[1] មាត្រា១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[2] មេធាវីឡោ គីមហ៊្គិច, បទសម្ភាសន៍ស្ដីពីច្បាប់, ០៤ កញ្ញា ២០១៧។

[3] មាត្រា៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- **ជនត្រូវចោទ** សំដៅលើជនដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្ដឹងចាប់ពីពេល ដែលមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ។ នៅដំណាក់កាលស៊ើបសួរនេះ ជនដែលត្រូវបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬជនដែលមានតម្រុយពីពិរុទ្ធភាព (ជនដែលមិនត្រូវបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ប៉ុន្តែអាចមានការពាក់ព័ន្ធ) ត្រូវហៅថា "**ជនត្រូវចោទ**" រហូតផុតដំណាក់កាលស៊ើបសួរ។[4]
- **ជនជាប់ចោទ** សំដៅលើជនដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្ដឹងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុស្ដីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ឬជនដែលត្រូវបានចៅក្រមស៊ើបសួរបានចោទប្រកាន់តាមរយៈដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ទៅកាន់តុលាការជំនុំជម្រះ។ នៅដំណាក់កាលជំនុំជម្រះនេះ ជនខាងលើត្រូវហៅថា "**ជនជាប់ចោទ**" រហូតមានសេចក្ដីសម្រេចប្រកាសពីតុលាការជំនុំជម្រះ។[5]
- **ពិរុទ្ធជន** សំដៅលើជន ដែលត្រូវបានតុលាការជំនុំជម្រះ ប្រកាសអំពីពិរុទ្ធភាពទៅលើអង្គហេតុដែលខ្លួនបានប្រព្រឹត្តបទល្មើស។ ប៉ុន្តែប្រសិនបើសេចក្ដីសម្រេចលើអង្គហេតុនេះមិនទាន់ចូលជាស្ថាពរទេ ពិរុទ្ធជន ឬព្រះរាជអាជ្ញាអាចធ្វើការប្ដឹងឧទ្ធរណ៍បាន។ ចាប់ពីពេលមានបណ្ដឹងឧទ្ធរណ៍នេះពិរុទ្ធជនត្រូវបានហៅថា "**ជនជាប់ចោទ**" ជាថ្មីម្ដងទៀត។[6]
- **ទណ្ឌិត** សំដៅលើជនដែលត្រូវបានតុលាការជំនុំជម្រះប្រកាសអំពីពិរុទ្ធភាពជាស្ថាពរ (សេចក្ដីសម្រេចចូលជាស្ថាពរ)។ កាលណាសេចក្ដីសម្រេចចូលជាស្ថាពរហើយ ទណ្ឌិតមិនអាចធ្វើបណ្ដឹងឧបាស្រ័យទៀតបានទេ លុះត្រាតែមានមូលហេតុនៃបណ្ដឹងសើរើ។[7]

### ១.២.២. ជនរងគ្រោះ

ជនរងគ្រោះ គឺជាបុគ្គលដែលបានទទួលរងគ្រោះដោយផ្ទាល់ពីអំពើល្មើសរបស់ជនដែលបានប្រព្រឹត្តបទល្មើស។ ការខូចខាតដែលជនរងគ្រោះទទួលរង អាចជាព្យសនកម្មខាងរូបកាយ ផ្លូវចិត្ត និងទ្រព្យសម្បត្តិជាដើម។[8] នៅក្នុងក្រមនីតិវិធីបណ្ដឹងព្រហ្មទណ្ឌ ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីដើម្បីទាមទារនូវសំណងពីជនល្មើសទៅតាមទំហំនៃព្យសនកម្មដែលខ្លួនបានទទួលរង។ ចំពោះព្យសនកម្ម អាចត្រូវបានជួសជុលដោយការសងជម្ងឺចិត្តដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការបដិទាន (ធ្វើឲ្យដូចសភាពដើមវិញ) នូវទ្រព្យ

---

4 មាត្រា១៣៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

5 មាត្រា២៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

6 មាត្រា៣៦៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

7 មាត្រា៥០២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

8 វចនានុក្រមតម្រាច្បាប់នៃក្រុមហ៊ុនមេធាវីតម្រាច្បាប់។

សម្បត្តិដែលជនល្មើសបានបំផ្លាញ ឬធ្វើឲ្យខូចខាត។ សំណងជម្ងឺចិត្តត្រូវមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលបានទទួលរង។[9]

### ១.២.៣. ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីមាននៅក្នុងរឿងក្ដីព្រហ្មទណ្ឌ នៅពេលដែលជនរងគ្រោះនៃរឿងក្ដីនោះ គឺជាអនីតិជន ឬជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ឬជនស្ថិតក្រោមហិតូបត្ថម្ភ ដែលតម្រូវឲ្យអ្នកមានសិទ្ធិគ្រប់គ្រងលើជនរងគ្រោះដែលជាអនីតិជន ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ឬជនស្ថិតក្រោមហិតូបត្ថម្ភ ឬសិទ្ធិវន្តរបស់ជនរងគ្រោះនោះ ដោយអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីពីជនល្មើស។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងក្នុងនាមផលប្រយោជន៍របស់ជនរងគ្រោះ និងអាចធ្វើនៅពេលណាក៏បានដរាបណាចៅក្រមមិនទាន់សម្រេចលើអង្គសេចក្ដី។[10]

### ១.២.៤. អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

អ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាជនទាំងឡាយណា ដែលច្បាប់តម្រូវឲ្យទទួលខុសត្រូវខាងផ្នែកសំណងរដ្ឋប្បវេណីចំពោះទង្វើរបស់ជនល្មើស ដែលជននោះកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ហើយត្រូវបានច្បាប់ទទួលស្គាល់។[11]

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចជា៖

- ឪពុកម្ដាយ ឬ អាណាព្យាបាលរបស់ជនល្មើសដែលជាអនីតិជន
- អ្នកមានសិទ្ធិជាអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈរបស់ជនល្មើស
- សិទ្ធិវន្តរបស់ជនល្មើស
- និយោជករបស់ជនល្មើស
- ក្រុមហ៊ុនធានារ៉ាប់រង។[12]

---

[9] មាត្រា១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[10] មាត្រា១៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[11] មាត្រា២១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[12] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងចាំងស៊ីណាត, *មេរៀននីតិវិធីព្រហ្មទណ្ឌ*, ឆ្នាំ២០១៣, ទំព័រទី១០។

# ជំពូកទី២
# ដំណាក់កាលពេលដាក់
# ពាក្យបណ្តឹង

# ជំពូកទី២
# ដំណាក់កាលពេលដាក់ពាក្យបណ្ដឹង

## ២.១. លក្ខខណ្ឌនៃការដាក់ពាក្យបណ្ដឹង

### ២.១.១. បុគ្គល

ក្នុងការដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅកាន់ស្ថាប័នតុលាការ ចាំបាច់ត្រូវតែមាននូវលក្ខខណ្ឌមួយចំនួន ដែលតម្រូវឲ្យគោរពតាម ដើម្បីឲ្យបណ្ដឹងនោះស្របច្បាប់ ដែលអាចធ្វើឲ្យតុលាការសម្រេចយករឿងក្ដីនោះមកធ្វើការដោះស្រាយ។ ក្នុងនោះដែរវត្តមាននៃបុគ្គលគឺជាលក្ខខណ្ឌចម្បង ព្រោះនៅក្នុងពាក្យបណ្ដឹងតម្រូវជាចាំបាច់ឲ្យមាននូវបុគ្គលដែលធ្វើការដាក់ពាក្យប្ដឹង និងបុគ្គលដែលត្រូវបានគេចោទប្ដឹង។ ជាទូទៅជនដែលបានប្រព្រឹត្តបទល្មើស និងជនរងគ្រោះអាចជារូបវន្តបុគ្គល និងនីតិបុគ្គលដោយនីតិបុគ្គលអាចមានអ្នកតំណាងនៃនីតិបុគ្គលនោះបានផងដែរ។[13]

### ២.១.២. អត្ថិភាពនៃបទល្មើស

ដើម្បីធ្វើការដាក់ពាក្យបណ្ដឹងបាន លុះត្រាតែមានអំពើនៃបទល្មើសត្រូវបានកើតឡើង ដោយជនល្មើសបានប្រព្រឹត្តទៅលើខ្លួនជាជនរងគ្រោះ ហើយមានចែងនៅក្នុងច្បាប់ ពោលគឺធាតុផ្សំនីត្យានុកូល ដែលវាជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងបី ដើម្បីកំណត់ឲ្យបាននូវបទល្មើស ដែលបានកើតឡើងស្របទៅតាមច្បាប់ដែលបានបញ្ញត្តិទុកសម្រាប់ដាក់ទណ្ឌកម្មទៅលើជន ដែលបានប្រព្រឹត្តបទល្មើសហើយបានបង្កឲ្យមានការខូចខាតដល់សណ្ដាប់ធ្នាប់សង្គម។[14]

### ២.១.៣. ព្យសនកម្មនៃបទល្មើស

នៅពេលដែលជនល្មើសបានប្រព្រឹត្តនូវបទល្មើសទៅលើជនរងគ្រោះ តែងតែកើតមានឡើងនូវព្យសនកម្មចំពោះជនរងគ្រោះ ដែលមានដូចជាផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ ទ្រព្យសម្បត្តិផ្សេងៗ ដោយតម្រូវឲ្យជនល្មើសធ្វើការទទួលខុសត្រូវដើម្បីជួសជុលនូវព្យសនកម្មដែលខ្លួនបានប្រព្រឹត្ត។[15]

## ២.២. ប្រភេទនៃបណ្ដឹង

ចំពោះប្រភេទនៃបណ្ដឹងនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ត្រូវបានគេធ្វើការបែងចែកជាពីរប្រភេទគឺបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណីដែលនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ។[16]

---

[13] មាត្រា៣, ៤, ៥, ៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[14] https://www.khsearch.com/qna/25576 , ចូលទស្សនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១។

[15] មាត្រា១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[16] មាត្រា២ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ២.២.១. បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា ឬជាទូទៅត្រូវបានហៅថាបណ្តឹងព្រហ្មទណ្ឌ មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញអំពីពិរុទ្ធភាពនៃជនល្មើស និងធ្វើការផ្តន្ទាទោសទៅលើជនដែលបានប្រព្រឹត្តបទល្មើសតាមការកំណត់នៃច្បាប់។[17] បណ្តឹងអាជ្ញាត្រូវអនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គលទាំងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។[18] យោងតាមមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា *"មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"* ដូច្នេះការធ្វើបណ្តឹងអាជ្ញាគឺជាសិទ្ធិផ្តាច់មុខរបស់ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវបានចាប់ផ្តើមដំណើរការ ដោយមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយដោយអយ្យការ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ចំពោះបទល្មើសត្រូវមានអាជ្ញាយុកាលនៃការធ្វើបណ្តឹងអាជ្ញាដោយៈ

- ចំពោះបទឧក្រិដ្ឋ មានអាជ្ញាយុកាល ១៥ឆ្នាំ
- ចំពោះបទមជ្ឈិម មានអាជ្ញាយុកាល ៥ឆ្នាំ
- ចំពោះបទលហុ មានអាជ្ញាយុកាល ១ឆ្នាំ។[19]

### ២.២.២. បណ្តឹងរដ្ឋប្បវេណី

ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនា និងអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអង្គការអយ្យការ ដែលជាអ្នកធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ប៉ុន្តែបើយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងអាជ្ញាក៏អាចមានចលនាបានដោយបុគ្គលដែលទទួលរងគ្រោះដោយផ្ទាល់ ឬភាគីដែលពាក់ព័ន្ធនឹងហេតុការណ៍ដែលត្រូវបានកំណត់ក្នុងបណ្តឹងអាជ្ញានោះមានសិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណី ដែលត្រូវបានកំណត់ថាជាប្រភេទបណ្តឹងរដ្ឋប្បវេណីក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយបណ្តឹងរដ្ឋប្បវេណីនេះ មានគោលបំណងឲ្យភាគីរងគ្រោះបានទទួលសំណងជម្ងឺចិត្តឲ្យបានសមល្មមនឹងព្យសនកម្មដែលខ្លួនបានទទួលរង។[20] ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញាបាន។[21]

---

[17] មាត្រា២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[18] មាត្រា៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[19] មាត្រា១០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[20] មាត្រា៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[21] មាត្រា១៣៩ និងមាត្រា១៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ជាគោលការណ៍បណ្តឹងនេះ គឺជាសេរីភាពឆន្ទៈបុគ្គលឯកជន ហើយការដាក់បណ្តឹងនេះទាមទារឲ្យជនរងគ្រោះពិចារណាឲ្យបានល្អិតល្អន់បំផុត ដោយហេតុថាបណ្តឹងនេះអាចនឹងទទួលរងនូវប្រតិកម្មតបវិញ ដោយអ្នកប្តឹងអាចប្រឈមនឹងការពិន័យផ្នែករដ្ឋប្បវេណី និងបណ្តឹងឲ្យជួសជុលការខូចខាតពីភាគីម្ខាងទៀត ក្នុងករណីដែលរកឃើញថាបណ្តឹងនោះធ្វើឡើងដោយរំលោភបំពាន ឬបណ្តឹងអូសបន្លាយពេលវេលា។

ពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌត្រូវសរសេរដោយទម្រង់មួយ ដែលត្រូវមានដូចជា៖

ក/ ឈ្មោះ អត្តសញ្ញាណ មុខរបរ ទីលំនៅរបស់ជនរងគ្រោះ ឬដើមបណ្តឹង។

ខ/ ស្ថាប័ន ឬអង្គភាព ដែលជនរងគ្រោះ ឬដើមបណ្តឹងត្រូវដាក់បណ្តឹងទៅ។

គ/ កម្មវត្ថុនៃបណ្តឹង ដែលជនរងគ្រោះ ឬដើមបណ្តឹងស្នើសុំពីបទល្មើសដែលជនសង្ស័យប្រព្រឹត្តមកលើខ្លួន ញាតិ ឬក្រុមគ្រួសារ។

ឃ/ អង្គហេតុ ដែលកើតឡើងតាំងពីដើមរហូតដល់កើតបទល្មើស ដែលត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ ដើម្បីសមត្ថកិច្ចងាយកំណត់នូវបទល្មើសដែលបានប្រព្រឹត្ត។

ង/ សំណូមពរ គឺត្រូវស្នើសុំនូវចំណុចពាក់ព័ន្ធគោលបំណងនៃការធ្វើបណ្តឹង ដែលអាចប្តឹងទាំងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីពីការទាមទារពាក់ព័ន្ធនឹងបទល្មើស។

ច/ ជនរងគ្រោះ ឬដើមបណ្តឹងត្រូវផ្តិតមេដៃស្តាំលើពាក្យបណ្តឹងរបស់ខ្លួន ដែលបានបំពេញតាមចំណុចដូចរៀបរាប់ខាងលើ។[22]

បណ្តឹងនៅក្នុងរឿងព្រហ្មទណ្ឌត្រូវអនុវត្តតាមទម្រង់ខាងលើ ដើម្បីឲ្យមានលក្ខណៈពេញលេញតាមផ្លូវច្បាប់។ ក៏ប៉ុន្តែក្នុងករណីមានបទល្មើសណាមួយកើតឡើងជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចស្នើសុំឲ្យសមត្ថកិច្ចជួយសរសេរពាក្យបណ្តឹង[23] ឬអាចពឹងមេធាវីឲ្យរៀបចំធ្វើពាក្យបណ្តឹង ដើម្បីការពារផលប្រយោជន៍របស់ខ្លួនបានផងដែរ។[24]

## ២.៣. ការដាក់ពាក្យបណ្តឹង

មុននឹងដាក់ពាក្យបណ្តឹងទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការដោះស្រាយនូវរឿងក្តីរបស់ខ្លួនភាគីនៃរឿងក្តីដូចជាជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចសរសេរនូវពាក្យបណ្តឹងបានដោយខ្លួនឯង ឬក៏អាចធ្វើការពឹងពាក់មេធាវីក្នុងការសរសេរពាក្យបណ្តឹងឲ្យខ្លួន។ ប៉ុន្តែការដាក់ពាក្យបណ្តឹងនេះ ត្រូវតែគោរពទៅតាមលក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹងដូចបានរៀបរាប់នៅចំណុចខាងលើ។ នៅពេលដែលជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើតាមគ្រប់លក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹង ក៏ដូចជាការសរសេរពាក្យបណ្តឹងឲ្យបានត្រឹមត្រូវ និងមាន

---

[22] គម្រូពាក្យបណ្តឹងព្រហ្មទណ្ឌ។

[23] https://www.youtube.com/watch?v=bkxBKsVjMGU, ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។

[24] មាត្រា២ និងមាត្រា៣, ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី, លេខ នស/រកម/០៨៩៥/០៦, ២២ សីហា ១៩៩៥។

លក្ខណៈគតិយុត្តដូចដែលបានបញ្ជាក់ដូចនៅខាងលើនេះរួចមក បុគ្គលនោះត្រូវយកពាក្យបណ្ដឹងរបស់ខ្លួនដែលបានសរសេររួចនោះ ទៅដាក់នៅស្ថាប័នមានសមត្ថកិច្ចរួចរង់ចាំនីតិវិធីបន្ត ដើម្បីឲ្យពាក្យបណ្ដឹងរបស់ខ្លួនមានដំណើរការទៅតាមលំហូរនីតិវិធីនៃបណ្ដឹងនោះ។[25] នៅក្នុងដំណាក់កាលនេះប្រសិនបើជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីចង់យកពាក្យបណ្ដឹងរបស់ខ្លួនទៅដាក់ មានសំណួរសួរថាតើនរណាជាអ្នកដែលអាចទទួលពាក្យបណ្ដឹងព្រហ្មទណ្ឌបាន ហើយគេអាចយកពាក្យបណ្ដឹងព្រហ្មទណ្ឌនោះទៅដាក់នៅកន្លែងណា? យើងអាចក្រឡេកទៅមើលផ្នែកទី៤ នៃជំពូកទី២នេះ ដែលនឹងអធិប្បាយអំពីស្ថាប័នដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្ដឹងព្រហ្មទណ្ឌនេះ។

## ២.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការទទួលបណ្ដឹង

### ២.៤.១. អង្គភាពនគរបាលយុត្តិធម៌

នៅពេលបទល្មើសបានកើតឡើង ជនរងគ្រោះនៃបទល្មើសនោះអាចដាក់ពាក្យបណ្ដឹងទៅកាន់ស្ថាប័ន ឬអង្គភាពណាដែលច្បាប់ផ្ដល់សម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលវាអាស្រ័យទៅតាមប្រភេទនៃបទល្មើស និងសម្បទារបស់មន្ត្រីនគរបាលយុត្តិធម៌នោះ។[26] ស្ថាប័ននៃការរក្សាសណ្ដាប់ធ្នាប់ថ្នាក់មូលដ្ឋាននៃសង្គមមួយនេះ ក៏មានតួនាទីក្នុងការទទួលបណ្ដឹងដោយផ្ទាល់ពីសំណាក់ប្រជាជនផងដែរ ដែលក្នុងនោះមានបណ្ដឹងតវ៉ា ឬបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យបណ្ដឹងពីជនរងគ្រោះ ឬអ្នកតំណាង ឬដើមបណ្ដឹងរដ្ឋប្បវេណីពីករណីបទល្មើសព្រហ្មទណ្ឌណាមួយ នោះមន្ត្រីនគរបាលយុត្តិធម៌នឹងចាប់ផ្ដើមភារកិច្ចដែលមានដូចជា៖

- បើកការស៊ើបអង្កេតលម្អិតភ្លាម
- ចុះទៅកន្លែងកើតហេតុ (តាមរយៈការសួរសាក្សី ឬជនរងគ្រោះ)
- ធ្វើការកំណត់អត្តសញ្ញាណរបស់ជនល្មើស
- ធ្វើការកំណត់អត្តសញ្ញាណនៃបទល្មើស
- ធ្វើសេចក្ដីសន្និដ្ឋានបញ្ជូនទៅការិយាល័យអយ្យការដើម្បីត្រៀមធ្វើការចោទប្រកាន់។[27]

### ២.៤.២. ស្ថាប័នអយ្យការ

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ស្ថាប័ន ឬអង្គការអយ្យការក៏មានតួនាទីក្នុងការទទួលពាក្យបណ្ដឹងដោយផ្ទាល់ ឬមិនផ្ទាល់ពីសំណាក់ប្រជាជនផងដែរ។ នៅពេលដែលបានសរសេរពាក្យបណ្ដឹងបានត្រឹមត្រូវហើយត្រូវយកពាក្យបណ្ដឹងនោះទៅកាន់សាលាដំបូងដែលមានសមត្ថកិច្ចក្នុងការជម្រះក្ដី រួចដាក់ពាក្យបណ្ដឹងនោះទៅកាន់រដ្ឋបាលផ្នែក

[25] https://www.youtube.com/watch?v=bkxBKsVjMGU, ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។

[26] មាត្រា៦០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[27] មាត្រា៧៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ទទួលបណ្តឹងព្រហ្មទណ្ឌ ដើម្បីឲ្យបណ្តឹងរបស់ខ្លួនបញ្ជូនទៅដល់ស្ថាប័នអយ្យការ។[28] នៅពេលដែលស្ថាប័នអយ្យការបានទទួលពាក្យបណ្តឹងដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ឬអ្នកតំណាង ឬដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវពិនិត្យផងដែរនូវៈ

- អត្ថិភាពនៃបណ្តឹង (ករណីព្រហ្មទណ្ឌពិតប្រាកដអាចនឹងធ្វើការចោទប្រកាន់)
- ពិចារណាលើភស្តុតាងដែលមាន (ភស្តុតាងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងបណ្តឹង)
- ធ្វើមូលវិចារក្នុងការចោទប្រកាន់
- ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ
- រង់ចាំពិនិត្យ ចំពោះសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យពិនិត្យផ្ទាល់ពីចៅក្រមស៊ើបសួរ
- ធ្វើសេចក្តីសន្និដ្ឋានពិនិត្យស្ថាពរបញ្ជូនទៅចៅក្រមស៊ើបសួរ។

ប្រសិនបើរឿងក្តីនោះមានជាប់ពាក់ព័ន្ធនឹងមន្ត្រីក្នុងក្របខណ្ឌ ឬនៃរាជរដ្ឋាភិបាល ព្រះរាជអាជ្ញាមិនអាចធ្វើការផ្តើមចោទប្រកាន់តាមតែចិត្តខ្លួនឯងតែម្តងទេ គឺត្រូវស្នើសុំការយល់ព្រមពីស្ថាប័នមានអំណាច ពោលគឺក្រសួងយុត្តិធម៌ ឬម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីស្នើទៅគណៈរដ្ឋមន្ត្រីតាមរយៈក្រសួងយុត្តិធម៌ ដើម្បីស្វែងរកការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។[29]

[28] មាត្រា៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[29] មាត្រា៥១, ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា, លេខ ០៦ នស.៩៤, ៣០ តុលា ១៩៩៤។

# ជំពូកទី៣
# ដំណាក់កាលនីតិវិធី
# នៃបណ្តឹង

# ជំពូកទី៣
# ដំណាក់កាលនៃនីតិវិធីបណ្តឹង

នៅពេលដែលមានបណ្តឹងព្រហ្មទណ្ឌកើតឡើង ហើយបានបញ្ជូនទៅកាន់តុលាការ នោះតុលាការនឹងបន្តនីតិវិធី ដើម្បីឲ្យបណ្តឹងនោះមានចលនា ពោលគឺត្រូវឆ្លងកាត់នូវដំណាក់កាលបីគឺដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដែលដំណាក់កាលនីមួយៗមានអង្គភាពមានសមត្ថកិច្ចផ្សេងៗគ្នា និងរៀងៗខ្លួន។

## ៣.១. ដំណាក់កាលអយ្យការ

នៅក្នុងអង្គភាពនៃសាលាដំបូងរាជធានី-ខេត្តនីមួយៗ មានការិយាល័យ ឬស្ថាប័នអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចនៅក្នុងដែនដីនៃរាជធានី-ខេត្ត ព្រមទាំងមានសមត្ថកិច្ចលើការកំណត់បទល្មើសព្រហ្មទណ្ឌមួយដែលកើតឡើងនៅក្នុងរាជធានី-ខេត្តនោះ ហើយធ្វើការចោទប្រកាន់ចំពោះជនល្មើសនោះឲ្យទទួលនូវទណ្ឌកម្មសមស្របទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្តឡើង។

### ៣.១.១. សញ្ញាណទូទៅនៃអង្គការអយ្យការ

អង្គការអយ្យការ គឺជាម្ចាស់បណ្តឹងអាជ្ញា ដែលមាននៅអមគ្រប់សាលាជម្រះក្តី ដោយបំពេញតួនាទីក្នុងការការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ។ នៅពេលពិនិត្យឃើញអង្គហេតុណាមួយដែលជាបទល្មើស អយ្យការត្រូវធ្វើការចោទប្រកាន់ និងសុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[30] អង្គការអយ្យការធ្វើការធានារ៉ាប់រងចំពោះការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ហើយព្រមទាំងធានាដោយយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផងដែរ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ត្រូវបានចាត់តាំងជាតំណាងរបស់អង្គការអយ្យការអមសាលាដំបូងដែលខ្លួនបានកំពុងនឹងបំពេញការងារនោះ។[31] ជាទូទៅអង្គការអយ្យការមាននៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ពោលគឺសាលាជម្រះក្តីជាន់ទាប និងសាលាជម្រះក្តីជាន់ខ្ពស់គឺះ

- នៅសាលាដំបូង ហៅថាអយ្យការអមសាលាដំបូង
- នៅសាលាឧទ្ធរណ៍ ហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍
- នៅតុលាការកំពូល ហៅថាមហាអយ្យការអមតុលាការកំពូល។[32]

### ៣.១.២. លក្ខខណ្ឌនៃការចោទប្រកាន់

នៅពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងរួចមក ជាដំបូងព្រះរាជអាជ្ញាត្រូវធ្វើការត្រួតពិនិត្យទៅលើពាក្យបណ្តឹងជាមុនសិនដោយធ្វើការស៊ើបអង្កេតបឋម ឬធ្វើការស្រាវជ្រាវបន្ថែម ដើម្បីប្រមូលព័ត៌មានឲ្យ

[30] មាត្រា២៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[31] មាត្រា៣០, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។

[32] មាត្រា៨, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។

បានកាន់តែច្បាស់ថាវាមានលក្ខខណ្ឌសមស្របដើម្បីធ្វើចំណាត់ការលើបណ្តឹងនោះ។ បន្ទាប់មកព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងរាល់ពាក្យបណ្តឹង ដែលខ្លួនទទួលដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋ មន្ត្រីរាជការ ឬក៏មន្ត្រីនគរបាលយុត្តិធម៌ដែលបានបញ្ជូនមក ព្រមទាំងកំណត់ថាវាជាបទល្មើសផ្នែកព្រហ្មទណ្ឌ ឬយ៉ាងណា ហើយវាមានធាតុផ្សំគ្រប់គ្រាន់ដែរឬទេ។ ព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តទៅលើពាក្យបណ្តឹងដែលទទួលមកថាគួរតែចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ដោយយោងទៅតាមគោលការណ៍លក្ខខណ្ឌនៃការចោទប្រកាន់នោះ ដែលមានដូចជាការពិនិត្យទៅលើគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ (របបនៃគោលការណ៍ ដែលប្រទេសកម្ពុជាបានអនុវត្តសម្រាប់អង្គការអយ្យការ) និងសេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា[33] ប៉ុន្តែការតម្កល់រឿងទុករបស់ព្រះរាជអាជ្ញាត្រូវប្រែប្រួលដោយសារព្រះរាជអាជ្ញាត្រូវគោរពអធិបញ្ញារបស់ឋានានុក្រមរបស់ខ្លួននៅពេលដែលព្រះរាជអាជ្ញាតម្កល់រឿងណាមួយទុកឥតចាត់ការ ប្រសិនបើឋានានុក្រមធ្វើអធិបញ្ញាឲ្យចោទរឿងដែលបានតម្កល់នោះ ព្រះរាជអាជ្ញាត្រូវតែចោទប្រកាន់ឡើងវិញ។[34]

### ៣.១.៣. សេចក្តីសម្រេចរបស់អយ្យការ

នៅពេលដែលតំណាងអយ្យការបានធ្វើការពិនិត្យសំណុំរឿង និងធ្វើការស៊ើបអង្កេតបឋមរួចហើយ ព្រមទាំងបានសិក្សាលម្អិតអំពីធាតុផ្សំនៃបទល្មើសនៅក្នុងពាក្យបណ្តឹងនោះហើយ អង្គការអយ្យការត្រូវធ្វើការសម្រេចសេចក្តីថានឹងត្រូវធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់ចំពោះបុគ្គលនោះ។

#### ៣.១.៣.១. ការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការមានដូចជា៖

**ក. អង្គហេតុដែលប្តឹងមិនមែនជាបទល្មើសព្រហ្មទណ្ឌ៖** អំពើដែលគេប្តឹងមកគឺជារឿងរដ្ឋប្បវេណី មិនមែនជាបទល្មើសព្រហ្មទណ្ឌ មានន័យថាអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលច្បាប់បានកំណត់ផ្តន្ទាទោស។[35]

**ខ. ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់៖** ធាតុផ្សំនៃបទល្មើសមានបី គឺធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត។ ក្នុងករណីដែលមិនអាចរកឃើញនូវធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបីនេះ មិនអាចធ្វើការចោទប្រកាន់បានទេ។[36]

---

[33] កុយ នាម និងឡុង បញ្ញាវុធ, *អយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប*, បោះពុម្ពលើកទី១, ២០០៦, ទំព័រទី១០៣។

[34] មាត្រា៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[35] ទំព័រស្វែងយល់ពីច្បាប់៖ *ការតម្កល់រឿងទុកឥតចាត់ការ*, ឆ្នាំ២០១៧, ទំព័រទី១៤។

[36] ទំព័រស្វែងយល់ពីច្បាប់៖ *ការតម្កល់រឿងទុកឥតចាត់ការ*, ឆ្នាំ២០១៧, ទំព័រទី១៣។

**គ. មូលហេតុនៃការរលត់បណ្ដឹងអាជ្ញា៖** មូលហេតុនៃការរលត់បណ្ដឹងអាជ្ញា មានដូចខាងក្រោម៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។[37]

**ឃ. បុគ្គលដែលពាក់ព័ន្ធមានអភ័យឯកសិទ្ធិ៖** មន្ត្រីរាជការ ឬបុគ្គលណាដែលទទួលបានអភ័យឯកសិទ្ធិក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។[38]

**ង. ការមិនទទួលខុសត្រូវរបស់ជនល្មើស៖** ស្របទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ការមិនទទួលខុសត្រូវរបស់ជនល្មើសមានដូចជា៖

- ដោយសារវិបល្លាសស្មារតីនៃជនល្មើស[39]
- ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ[40]
- ការការពារស្របច្បាប់[41]
- សច្ចធារណ៍នៃការការពារស្របច្បាប់[42]
- ស្ថានភាពចាំបាច់[43]
- អានុភាពនៃកម្លាំង ឬការបង្ខំ[44]
- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។[45]

**ច. អនិយ័តភាពនៃនីតិវិធី៖** នីតិវិធីនៃការឃាត់ខ្លួន ឬការចោទប្រកាន់ទៅដល់ជនល្មើសមានភាពមិនប្រក្រតី។[46]

[37] មាត្រា៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[38] ទំព័រស្វែងយល់ពីច្បាប់៖ *ការតម្កល់រឿងទុកឥតចាត់ការ*, ឆ្នាំ២០១៧, ទំព័រទី១៨។

[39] មាត្រា៣១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[40] មាត្រា៣២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[41] មាត្រា៣៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[42] មាត្រា៣៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[43] មាត្រា៣៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[44] មាត្រា៣៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[45] មាត្រា៣៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[46] ទំព័រស្វែងយល់ពីច្បាប់៖ *ការតម្កល់រឿងទុកឥតចាត់ការ*, ឆ្នាំ២០១៧, ទំព័រទី១៨។

**ឆ. អត្តសញ្ញាណរបស់ជនល្មើសមិនអាចកំណត់បាន៖** ជនដែលបានប្រព្រឹត្តបទល្មើស ជាជនដែលមិនត្រូវបាននរណាម្នាក់ស្គាល់ ឬមិនអាចកំណត់បាន។

**ជ. ការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍៖** ប្រសិនបើជនដែលបានប្រព្រឹត្តបទល្មើសបានទទួលស្គាល់នូវព្យសនកម្ម ដែលខ្លួនបានប្រព្រឹត្ត និងបានជួសជុលនូវព្យសនកម្មទៅដល់ជនរងគ្រោះ ហើយជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹងអ្វីឡើយ នោះព្រះរាជអាជ្ញាយល់ឃើញថាការចោទប្រកាន់របស់ខ្លួននឹងមិនមានផលប្រយោជន៍អ្វីឡើយ លោកអាចតម្កល់រឿងនោះទុកឥតចាត់ការបាន។[47]

**ឈ. ព្យសនកម្មមានតិចតួច៖** នៅពេលដែលព្យសនកម្មមានតិចតួច នោះព្រះរាជអាជ្ញាអាចធ្វើការសម្រេចក្នុងការតម្កល់រឿងឥតចាត់ការ។[48]

ចំពោះការតម្កល់រឿងទុកឥតចាត់ការនេះ ព្រះរាជអាជ្ញាត្រូវចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមានសម្អាងហេតុ និងសម្អាងច្បាប់ត្រឹមត្រូវផងដែរ ព្រមទាំងត្រូវឲ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល០២(ពីរ)ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីនៃពាក្យប្តឹង។[49] ដីកាតម្កល់រឿងទុកឥតចាត់ការនេះ អ្នកដាក់ពាក្យបណ្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល០២(ពីរ)ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ អ្នកប្តឹងតវ៉ាអាចធ្វើជាបណ្តឹងសាមញ្ញ ដោយធ្វើការដាក់ពាក្យមកកាន់អង្គការអយ្យការពាក់ព័ន្ធ ហើយតំណាងអយ្យការអមសាលាដំបូងនឹងបញ្ជូននូវសំណុំរឿងភ្លាមជូនទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[50] ករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានយល់ឃើញថាការតវ៉ានោះប្រកបដោយមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញានឹងធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់។ ករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនៃការតម្កល់សេចក្តីសម្រេចនេះជូនទៅដល់អ្នកប្តឹងតវ៉ាវិញ។[51]

---

[47] ទំព័រស្វែងយល់ពីច្បាប់៖ ការតម្កល់រឿងទុកឥតចាត់ការ, ឆ្នាំ២០១៧, ទំព័រទី២១។

[48] កុយ នាម និងឡុង បញ្ញាវុធ, *អយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប*, បោះពុម្ពលើកទី១ ឆ្នាំ២០០៦, ទំព័រទី១០៧។

[49] មាត្រា៤១ កថាខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[50] មាត្រា៤១ កថាខណ្ឌទី៤ និងទី៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[51] មាត្រា៤១ កថាខណ្ឌទី៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

គួរបញ្ជាក់ផងដែរថា ការតម្កល់រឿងទុកឥតចាត់ការនេះពុំមានអាជ្ញាអស់ជំនុំទេ ពោលគឺព្រះរាជអាជ្ញាអាចសើរើ និងកែប្រែនូវសេចក្តីសម្រេចរបស់ខ្លួនវិញនៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។[52]

**៣.១.៣.២. ជម្រើសនៃការចោទប្រកាន់**

នៅពេលដែលភស្តុតាងត្រូវបានប្រមូលមកបានគ្រប់គ្រាន់ដែលអាចជឿបានថាជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេបានប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់។ ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ត្រូវបានតុលាការធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល៧២ ម៉ោងយ៉ាងយូរ។[53] ចំពោះការចាប់ផ្តើមចោទប្រកាន់ទៅកាន់អនីតិជនត្រូវជូនដំណឹងទៅអនីតិជនដែលជាប់សង្ស័យ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះឲ្យបានដឹង។ ចំពោះជនជាប់សង្ស័យដែលជាអនីតិជនទាក់ទងនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់ថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននោះត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះបានប្រព្រឹត្តបទល្មើស ហើយភស្តុតាងនៃអាយុរបស់អនីតិជនត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតបាន។ ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។[54] ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមបង្ហាញឲ្យឃើញថាអាយុរបស់អនីតិជនជាប់សង្ស័យតិចជាង១៤ ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញដីកាតម្កល់រឿងទុកឥតចាត់ការ ហើយផ្តល់ដំណឹងទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមបង្ហាញឲ្យឃើញថាអាយុរបស់អនីតិជនជាប់សង្ស័យនោះចាប់ពី១៤ ឆ្នាំឡើងទៅតែតិចជាង១៨ ឆ្នាំ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់បាន។[55] ប្រសិនបើរកមិនឃើញអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ ដើម្បីឲ្យចៅក្រមស៊ើបសួរពីអាយុ។

ការចោទប្រកាន់របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌអាចធ្វើឡើងទៅបានតាមរយៈការប្តឹងទៅកាន់យុត្តាធិការស៊ើបសួរ ដោយមាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងការប្តឹងទៅយុត្តាធិការជំនុំជម្រះតាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការធ្វើកំណត់ហេតុបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។[56]

---

[52] មាត្រា៤១ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[53] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *មេរៀននីតិវិធីព្រហ្មទណ្ឌ*, ២០១៣, ទំព័រទី២៧។

[54] មាត្រា៩, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦។

[55] មាត្រា៧, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦។

[56] មាត្រា៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៣.១.៣.២.១. ការបើកការស៊ើបសួរ

នៅពេលដែលសំណុំរឿងនោះ មានលក្ខណៈស្មុគស្មាញពិបាកនៅក្នុងការវិនិច្ឆ័យ ព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេត និងស៊ើបសួរបន្ថែម ដោយត្រូវធ្វើការប្តឹងទៅកាន់ចៅក្រមស៊ើបសួរដើម្បីបន្តនីតិវិធីនេះ។ ព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរទៅលើអង្គហេតុ ហើយការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដែលមានខ្លឹមសារដូចបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។[57] ក្នុងករណីដែលបទល្មើសនោះគឺជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរជាចាំបាច់។[58] ការស៊ើបសួរអាចបើកឡើងដើម្បីប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរតម្រូវឲ្យមាននិទ្ទេសដូចជា៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (ក្នុងករណីដែលអ្នកដាក់ពាក្យប្តឹងមិនបានស្គាល់ជនល្មើស)
- ចុះកាលបរិច្ឆេទ និងហត្ថលេខា។[59]

ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតែអំពីហេតុ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ។ ម្យ៉ាងទៀត បើព្រះរាជអាជ្ញាទទួលដំណឹងពីហេតុថ្មីៗដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលលើកឡើងដំបូងគេបង្អស់ នោះព្រះរាជអាជ្ញាអាចពង្រីកបណ្តឹងទៅកាន់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។[60]

### ៣.១.៣.២.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ប្រសិនបើបទល្មើសនៃពាក្យបណ្តឹងនោះ គឺជាបទមជ្ឈិម ឬជាបទលហុ ព្រះរាជអាជ្ញានឹងធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។[61] ចំពោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជានីតិវិធីដែលផ្តល់ឆន្ទានុសិទ្ធិទៅឲ្យព្រះរាជអាជ្ញាក្នុងការសម្រេចចោទប្រកាន់ទៅលើជនសង្ស័យនៅក្នុងរឿងក្តី

[57] មាត្រា១២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[58] មាត្រា៤៤ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[59] មាត្រា៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[60] មាត្រា១២៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[61] មាត្រា៤៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ព្រហ្មទណ្ឌ និងជាបញ្ជាមួយដើម្បីឲ្យជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការនៃសាលាដំបូងរាជធានី-ខេត្ត ដែលសម្រេចពីរឿងក្តីព្រហ្មទណ្ឌនោះ។[62]

ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅដើមនៃដីកាត្រូវមានការចុះនូវកាលបរិច្ឆេទ ទីកន្លែងកំណើត និងទីលំនៅរបស់ជនជាប់ចោទ ព្រមទាំងមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា។ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវចុះនូវនិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ការចង្អុលបង្ហាញប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទនៃដំណើរការសវនាការ
- ការបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន។[63]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ នេះត្រូវប្រគល់ឲ្យជនជាប់ចោទដោយ៖

- ក្រឡាបញ្ជីតាមផ្លូវរដ្ឋបាល
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត
- អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[64]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវបានប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃពីសំណាក់ព្រះរាជអាជ្ញា ឬដោយអាជ្ញាសាលា។[65] ប្រសិនបើលិខិតត្រូវបានប្រគល់ឲ្យដោយអាជ្ញាសាលា នោះអាជ្ញាសាលាត្រូវបង្ហាញថាលិខិតនេះបានប្រគល់ឲ្យដល់ជនជាប់ចោទ ឬដល់បុគ្គលដែលមានវត្តមាននៅលំនៅឋានរបស់ជនជាប់ចោទ ដោយបុគ្គលនោះត្រូវតែប្រគល់ដីកានេះក្នុងរយៈពេលខ្លីបំផុតឲ្យដល់ជនជាប់ចោទ។[66] អ្នកដែលទទួលត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលមកឲ្យព្រះរាជអាជ្ញាវិញ។[67]

ម្យ៉ាងទៀត អាជ្ញាសាលាអាចនឹងប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង នៅក្នុងករណីដែលជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬគ្មានបុគ្គល

---

[62] មាត្រា៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[63] មាត្រា៤៥៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[64] មាត្រា៤៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[65] មាត្រា៤៥៨ និងមាត្រា ៤៥៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[66] មាត្រា៤៦០ និងមាត្រា ៥៦១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[67] មាត្រា៤៦២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ ឬគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទយល់ព្រមទទួលដីកាកោះទេ។ បុគ្គលដែលទទួលដីកាក៏ត្រូវសន្យាថានឹងប្រគល់ដីកានេះក្នុងរយៈពេលខ្លីបំផុតឲ្យដល់ជនជាប់ចោទ។[68]

ចំពោះរយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។[69]

### ៣.១.៣.២.៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

នីតិវិធីបង្គាប់ឲ្យចូលខ្លួនភ្លាមនេះ គឺជាវិធីមួយផ្សេងទៀត ដែលជាសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ទៅលើជនល្មើស។ នីតិវិធីនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចធ្វើការបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ទាប ពោលគឺសាលាដំបូងរាជធានី-ខេត្ត បន្ទាប់ពីការឃាត់ខ្លួនបានបញ្ចប់រួចមក។ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះ គឺព្រះរាជអាជ្ញាធ្វើជាកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដើម្បីបញ្ជូនខ្លួនជនជាប់ចោទទៅចំពោះមុខតុលាការ។ វិធាននេះអាចអនុវត្តបាន លុះត្រាតែគោរពទៅតាមលក្ខខណ្ឌមួយចំនួនដូចជា៖

- បទល្មើសជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង និងការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង
- បទល្មើសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ
- បទល្មើសប្រព្រឹត្តដោយនីតិជន
- សំណុំរឿងត្រូវស្ថិតក្នុងស្ថានភាពដែលអាចបញ្ជូនទៅជំនុំជម្រះបាន។[70]

កងកម្លាំងការពារត្រូវបញ្ជូនខ្លួនបុគ្គលដែលបានឃាត់ខ្លួននោះ ឲ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ហើយចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាមក៏បានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយកាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឲ្យចូលបង្ហាញ ខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ជូនដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

[68] មាត្រា៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[69] មាត្រា៤៥៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[70] មាត្រា៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។[71]

ព្រះរាជអាជ្ញាក៏ត្រូវប្រាប់ទៅជនជាប់ចោទថា ខ្លួននឹងត្រូវបានធ្វើការជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្តង ដោយធ្វើនៅសាលាដំបូង ហើយអាចមានសិទ្ធិធ្វើការសុំពឹងពាក់មេធាវីដើម្បីការពារក្តី និងសិទ្ធិឲ្យខ្លួនតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[72] ចំពោះមេធាវី ដែលត្រូវបានជ្រើសរើស ឬចាត់តាំងត្រូវទទួលបានដំណឹងភ្លាម ដើម្បីឲ្យមេធាវីអាចធ្វើការពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។ ការបញ្ជូនខ្លួនជនជាប់ចោទទៅចំពោះមុខតុលាការជាន់ទាប ឬសាលាដំបូងត្រូវអមដោយកងការពាររហូតទៅដល់តុលាការហើយសវនាការនឹងត្រូវបើកនៅថ្ងៃនោះតែម្តង។[73] តុលាការត្រូវផ្ទៀងផ្ទាត់នូវអត្តសញ្ញាណរបស់ជនជាប់ចោទ និងកំណត់ហេតុដែលព្រះរាជអាជ្ញាដាក់មក។ តុលាការត្រូវពិនិត្យមើលលើសំណុំរឿងនោះថាអាចជំនុំជម្រះបាន ឬមិនបាន។ ក្នុងករណីដែលមិនអាចជំនុំជម្រះនាថ្ងៃនោះបាន តុលាការក៏អាចលើកសវនាការទៅកាលវិភាគក្រោយដោយហេតុរឿងក្តីនេះមានលក្ខណៈមិនទាន់អាចជំនុំជម្រះបាន ឬទុកពេលឲ្យជនជាប់ចោទ ដើម្បីរៀបចំខ្លួន (ការទុករយៈពេលនេះអាចធ្វើដោយឆន្ទានុសិទ្ធិរបស់តុលាការផ្ទាល់ ឬតាមការសុំរបស់ជនជាប់ចោទ ឬអាចជាមេធាវីការពារក្តីឲ្យជនជាប់ចោទផងដែរ)។[74] នៅពេលផ្អាកសវនាការ តុលាការត្រូវបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នដោយមានដីកាសម្រេច ព្រមទាំងមានសំអាងហេតុត្រឹមត្រូវ។[75] ប្រសិនបើតុលាការ លោកពិនិត្យទៅឃើញថាពាក្យបណ្តឹង មានភាពសាំញ៉ាំតម្រូវឲ្យមានការស្រាវជ្រាវ និងធ្វើការស៊ើបសួរបន្ថែម ឬលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមមិនបានបំពេញទេ នោះតុលាការនឹងបង្វិលសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាវិញ ដើម្បីធ្វើការបើកការស៊ើបសួរដោយបញ្ជូនជនជាប់ចោទឲ្យទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះជនជាប់ចោទត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។ សាលក្រមលើអង្គសេចក្តីត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ០២(ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការ ហើយការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ក្រោយពីផុតរយៈពេល០២(ពីរ) សប្តាហ៍។[76]

---

[71] មាត្រា៤៨ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[72] មាត្រា៤៨ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[73] មាត្រា៤៨ កថាខណ្ឌទី៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[74] មាត្រា៤៨ កថាខណ្ឌទី៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[75] មាត្រា៤៨ កថាខណ្ឌទី៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[76] មាត្រា៤៨ កថាខណ្ឌទី១០ និង១១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

## ៣.២. ដំណាក់កាលចៅក្រមស៊ើបសួរ

ក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរដើរតួយ៉ាងសំខាន់ក្នុងការស្វែងរកនូវការពិត។ តួនាទីយ៉ាងសំខាន់របស់ចៅក្រមស៊ើបសួរ គឺធ្វើការស៊ើបសួរដើម្បីដាក់បន្ទុកទៅលើជនត្រូវចោទ ឬធ្វើការស៊ើបសួរដើម្បីដោះបន្ទុកទៅលើជនត្រូវចោទវិញ[77] ដោយមានការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នជាដើម ដែលជាសេចក្ដីសម្រេចមានលក្ខណៈប៉ះពាល់ខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបង្កើតឲ្យមានយុត្តាធិការស៊ើបសួរមានចំនួនពីរគឺមន្ទីរស៊ើបសួរសាលាដំបូងរាជធានី-ខេត្តដែលជាយុត្តាធិការស៊ើបសួរនៃតុលាការជាន់ដំបូង និងសភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលជាយុត្តាធិការស៊ើបសួររបស់សាលាឧទ្ធរណ៍។ នៅក្នុងដំណាក់កាលនេះ ចៅក្រមស៊ើបសួរជាចៅក្រមអាសនៈ ដែលបំពេញមុខងារជាចៅក្រមស៊ើបសួរនៅសាលាដំបូង ហើយចៅក្រមអាសនៈបានបែងចែកជាពីរ គឺចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

### ៣.២.១. ការទទួលពាក្យបណ្ដឹង

ចៅក្រមស៊ើបសួរអាចទទួលពាក្យបណ្ដឹងតាមរយៈមធ្យោបាយពីរយ៉ាង គឺតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងតាមរយៈការទទួលបណ្ដឹងពីជនរងគ្រោះ ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។[78]

#### ៣.២.១.១. តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា

នៅពេលដែលព្រះរាជអាជ្ញាបានចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវតែធ្វើការបើកការស៊ើបសួរ។[79] ការស៊ើបសួរអាចបើកប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញប្រាប់ឈ្មោះអំពីជននោះ ឬប្រឆាំងទៅលើអញ្ញាតជន ដោយវាគឺជាវិធានដែលត្រូវតែគោរព ប្រសិនបើមិនគោរពតាមនោះទេនីតិវិធីនេះនឹងត្រូវមោឃភាព។[80] ដូច្នេះដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញានេះ គឺជាលិខិតដែលបើកឲ្យមានបណ្ដឹងអាជ្ញាកើតឡើង ដោយព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅកាន់ចៅក្រមស៊ើបសួរឲ្យលោកបើកការស៊ើបសួរនូវរឿងរ៉ាវមួយចំនួនជាកំណត់ ដែលយល់ថាអាចត្រូវបានផ្ដន្ទាទោសព្រហ្មទណ្ឌចំពោះបទល្មើសដែលជនត្រូវចោទនោះបានប្រព្រឹត្តឡើង។

ចៅក្រមស៊ើបសួរទទួលបណ្ដឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយព្រះរាជអាជ្ញា។[81] ចៅក្រមស៊ើបសួរមានសមត្ថកិច្ចធ្វើការស៊ើបសួរតែចំពោះអង្គហេតុ ដែលមាននៅក្នុងដីកាបញ្ជូនរឿងឲ្យ

---

[77] មាត្រា១២៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[78] មាត្រា៥ និងមាត្រា ១២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[79] មាត្រា១២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[80] មាត្រា២៥២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[81] មាត្រា៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ស៊ើបសួរនោះតែប៉ុណ្ណោះ។ ក្នុងករណីដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរហើយមានលេចឡើងនូវអង្គហេតុថ្មីដែលជាធាតុផ្សំសំខាន់នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ ឬជាបទល្មើសព្រហ្មទណ្ឌនោះ ករណីនេះចៅក្រមស៊ើបសួរត្រូវជូននូវព័ត៌មានពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទៅចៅក្រមស៊ើបសួរ។ នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរលើអង្គហេតុថ្មីនោះ ដោយគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាបានឡើយ។ ប៉ុន្តែចៅក្រមស៊ើបសួរពុំចាំបាច់ធ្វើការស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ ប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទៅលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដំបូងដែលចៅក្រមស៊ើបសួរកំពុងធ្វើការស៊ើបសួរនោះ។[82]

### ៣.២.១.២. តាមរយៈពាក្យបណ្តឹងពីជនរងគ្រោះ

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឲ្យជនរងគ្រោះ ឬមេធាវីរបស់ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[83] ករណីដែលជនរងគ្រោះមិនសរសេរនូវពាក្យប្តឹងបានដោយខ្លួនឯងនោះ មេធាវីដែលបានតំណាងឲ្យជនរងគ្រោះមានសិទ្ធិដាក់នូវពាក្យបណ្តឹងនៅក្នុងនាមជនរងគ្រោះបាន។

កាលណាចៅក្រមស៊ើបសួរនៃតុលាការជាន់ដំបូងបានទទួលនូវពាក្យបណ្តឹងដែលប្តឹងដោយជនរងគ្រោះ ឬមេធាវីរបស់ជនរងគ្រោះ ដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួរនឹងត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ បន្ទាប់ពីពិនិត្យថាមានលក្ខណៈត្រឹមត្រូវតាមការកំណត់ហើយ ចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនពាក្យបណ្តឹងនោះទៅកាន់ព្រះរាជអាជ្ញាដើម្បីពិនិត្យ។[84] បន្ទាប់ពីព្រះរាជអាជ្ញាបានពិនិត្យនូវពាក្យបណ្តឹងរួចរាល់ហើយនោះ ព្រះរាជអាជ្ញាត្រូវប្តឹងទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរវិញ។ នៅក្នុងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះអាចធ្វើឡើងក្នុងគោលបំណងប្រឆាំងនឹងអញ្ញាតជន(ជនដែលគេពុំស្គាល់) ទោះបីបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ករណីពាក្យបណ្តឹងដែលប្តឹងទៅក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលព្រះរាជអាជ្ញាធ្វើការពិនិត្យហើយបានឃើញថាបណ្តឹងអាជ្ញាត្រូវបានរលត់បាត់ទៅហើយ ឬពាក្យបណ្តឹងនោះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលជាធាតុផ្សំសំខាន់សម្រាប់ធ្វើការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរមិនឲ្យស៊ើបសួរបាន។[85] ករណីនេះ ប្រសិនបើចៅក្រមស៊ើបសួរ

---

[82] មាត្រា១២៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[83] មាត្រា១៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[84] មាត្រា១៣៩ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[85] មាត្រា១៣៩ កថាខណ្ឌទី២ និងទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

យល់ឃើញថាសម្រេចមិនធ្វើការស៊ើបសួរទេ ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។[86] ប៉ុន្តែនៅក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចធ្វើការស៊ើបសួរដដែលនោះ ចៅក្រមស៊ើបសួររូបនេះត្រូវចេញដីកាសម្រេចដែលមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញាវិញឲ្យបានជ្រាបពីករណីនេះ។[87]

ទន្ទឹមនឹងការបើកការស៊ើបសួរដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះដែលជាម្ចាស់បណ្តឹងតម្រូវឲ្យធ្វើការបង់ប្រាក់តម្កល់ទុក ដោយផ្អែកទៅលើធនធានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់តម្កល់នេះផង។[88]

ករណីដែលដើមបណ្តឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេចៅក្រមស៊ើបសួរអាចលើកលែងមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យបង់នូវប្រាក់តម្កល់នេះបាន។ ដីកាសម្រេចនេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។[89] ម្យ៉ាងទៀត ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមាននូវលទ្ធភាពបង់នូវប្រាក់តម្កល់នោះ នៅពេលដែលបានបង់ប្រាក់តម្កល់រួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបាននូវបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។[90] ផ្ទុយទៅវិញបើប្រាក់តម្កល់ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបង់នៅក្នុងរយៈពេលដែលបានកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យបណ្តឹងដែលប្តឹងដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរនឹងធ្វើការសម្រេចតាមដីកា ហើយត្រូវបញ្ជូនដំណឹងនេះជាបន្ទាន់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី។[91]

ក្រោយនីតិវិធីត្រូវបានបញ្ចប់ ប្រាក់តម្កល់នឹងត្រូវបង្វិលទៅឲ្យសាមីខ្លួន លើកលែងតែមានការប្តឹងដោយការបំពាន ឬបណ្តឹងដោយអូសបន្លាយនូវពេលវេលាដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនោះ។[92] ក្នុងករណីដែលការស៊ើបសួរត្រូវបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយសារមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានបិទតាមរយៈដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីបានធ្វើឡើងដោយរំលោភបំពាន ឬដោយអូសបន្លាយនូវពេលវេលា នោះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឲ្យដើមបណ្តឹង

[86] មាត្រា១៣៩ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[87] មាត្រា១៣៩ កថាខណ្ឌទី៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[88] មាត្រា១៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[89] មាត្រា១៤០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[90] មាត្រា១៤០ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[91] មាត្រា១៤០ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[92] មាត្រា១៤០ កថាខណ្ឌទី៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

រដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណីបានត្រឹមតែចំនួនទឹកប្រាក់ដែលត្រូវពិន័យ ដោយមិនអាចលើសពីចំនួនប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់តម្កល់បានឡើយ។[93] ចំពោះករណីនេះ ដីកាសម្រេចដែលតម្រូវឲ្យបង់ប្រាក់ពិន័យនោះ ត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាម្ចាស់បណ្ដឹង។ ទន្ទឹមនឹងនេះ ច្បាប់បានចែងពីសិទ្ធិរបស់ជនរងគ្រោះ ដែលអាចបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នោះបុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្ដឹង(បុគ្គលដែលគេប្ដឹង) អាចមានសិទ្ធិប្ដឹងសុំជួសជុលនូវការខូចខាតពីអ្នកដែលបានប្ដឹងពីខ្លួនវិញបាននៅក្នុងករណី ដែលដីកាសម្រេចលើកលែងនូវការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរ នោះដោយការចេញនូវដីកាសម្រេចនេះមានមូលហេតុដោយសំអាងលើនីតិវិធីធ្វើឡើងដោយការរំលោភ ឬអូសបន្លាយពេលវេលា។ ចំពោះនីតិវិធីនៃការដាក់ពាក្យបណ្ដឹងវិញ បុគ្គលនោះអាចយកពាក្យបណ្ដឹងទៅដាក់ជូនទៅតុលាការជាន់ដំបូង ដែលបានបើកការស៊ើបសួរនូវពាក្យបណ្ដឹងដែលបានប្ដឹងខ្លួននោះ។[94]

### ៣.២.២. ដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានដែនសមត្ថកិច្ចអនុវត្តអំណាចរបស់ខ្លួនចំពោះរឿងក្ដីនៃបទល្មើសព្រហ្មទណ្ឌ លុះត្រាតែបទល្មើសនោះកើតមានឡើងនៅក្នុងដែនដីរបស់ខ្លួន។ ករណីមួយចំនួនដែលចៅក្រមមានសមត្ថកិច្ចនៅក្នុងការចាត់ចែងបទល្មើសមានដូចជា៖

- បទល្មើសកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ
- ទីលំនៅរបស់ជនសង្ស័យស្ថិតក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ
- ចៅក្រមស៊ើបសួរ នាទីកន្លែងដែលចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។[95]

### ៣.២.៣. ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើការស៊ើបសួរជាសម្ងាត់ដើម្បីរក្សាសេចក្ដីថ្លៃថ្នូរ និងសិទ្ធិរបស់បុគ្គលម្នាក់ៗ។[96] ការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវតែធ្វើដោយខកខានពុំបានចំពោះបទល្មើសជាបទឧក្រិដ្ឋ។ ប៉ុន្តែនៅក្នុងករណីដែលបទល្មើសនោះ ជាបទមជ្ឈិម ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរក៏បាន ឬមិនចាំបាច់បើកការស៊ើបសួរក៏បានដែរ។[97] ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអង្គហេតុដែលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ប្រសិនបើលេចឡើងនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរបើកការស៊ើប

[93] មាត្រា១៤១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[94] មាត្រា១៤២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[95] មាត្រា១២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[96] មាត្រា១២១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[97] មាត្រា១២២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សួរអំពីអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានសិទ្ធិអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទៅលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។[98] ចៅក្រមស៊ើបសួរអាចសុំឲ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចខ្លះតាមដីកាចាត់ឲ្យស៊ើបសួរជំនួស។[99]

ចៅក្រមស៊ើបសួរ អាចចុះទៅដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ថាមានប្រយោជន៍ដូចមានការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង តែចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនោះ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចចុះទៅជាមួយចៅក្រមស៊ើបសួរនោះបាន។ [100]

### ៣.២.៤. ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

នៅពេលសំណុំរឿងបានទៅដល់ដៃរបស់ចៅក្រមស៊ើបសួរហើយ នោះចៅក្រមស៊ើបសួរនឹងធ្វើការបើកការត្រួតពិនិត្យដោយខ្លួនឯង ឬចេញដីកាចាត់ឲ្យមានការស៊ើបសួរជំនួស។ បើក្នុងករណីដែលចៅក្រមចាត់ឲ្យមានការស៊ើបសួរជំនួស នោះត្រូវចាត់ទៅឲ្យចៅក្រមផ្សេងទៀត ដែលនៅក្នុងតុលាការជាមួយគ្នា ឬចៅក្រមនៃតុលាការផ្សេងទៀតក៏បានដែរ ដើម្បីធ្វើការស៊ើបសួរជំនួស។

ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ត្រូវធ្វើឡើងតាមលក្ខខណ្ឌជាច្រើនដូចជា៖

- ការជូនដំណឹងដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ
- ការសួរចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយរបស់សាក្សី
- ការឆែកឆេរ និងការចាប់យកវត្ថុតាង
- ការធ្វើកោសលវិច័យ
- ការស្តាប់ទូរស័ព្ទ។[101]

[98] មាត្រា១២៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[99] មាត្រា១៣១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[100] មាត្រា១៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[101] មាត្រា១៤៣ ដល់មាត្រា១៧២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៣.២.៤.១. ការជូនដំណឹងដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ

នៅពេលដែលជនត្រូវចោទបានចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវតែពិនិត្យអំពីអត្តសញ្ញាណរបស់ជនត្រូវចោទនោះ ហើយត្រូវប្រាប់ឲ្យបានដឹងនូវរឿងរ៉ាវដែលបានចោទប្រកាន់ និងប្រាប់ពីបទល្មើសដែលខ្លួនត្រូវបានរងការចោទប្រកាន់។ ចៅក្រមស៊ើបសួរត្រូវប្រាប់ដល់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនដែលមានក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យតុលាការធ្វើការចាត់តាំងមេធាវី ដើម្បីមកការពារឲ្យខ្លួននៅក្នុងពេលសវនាការ។[102]

ចំពោះជនត្រូវចោទ ដែលជាអនីតិជនដែលត្រូវចូលបង្ហាញខ្លួនត្រូវតែមានមេធាវីអមជានិច្ច ប៉ុន្តែក្នុងករណីដែលគ្មានលទ្ធភាពក្នុងការរកមេធាវីសម្រាប់ការពារក្តី ត្រូវតែធ្វើការស្នើសុំទៅកាន់តុលាការ ដើម្បីចាត់តាំងមេធាវីសម្រាប់ការពារខ្លួន។[103] នៅពេលដែលចូលបង្ហាញខ្លួនលើកទី១ ជនត្រូវចោទត្រូវតែប្រាប់ពីទីលំនៅដែលខ្លួនបានស្នាក់នៅទៅកាន់ចៅក្រមស៊ើបសួរ។ ក្នុងករណីដែលជនត្រូវចោទមានបំណងចង់ផ្លាស់ប្តូរទីលំនៅ ត្រូវធ្វើការជូនដំណឹងទៅកាន់ចៅក្រមស៊ើបសួរជាមុនសិន ដើម្បីជាភាពងាយស្រួលសម្រាប់នីតិវិធីបន្ត[104] ហើយបន្ទាប់ពីបានផ្លាស់ប្តូរទីលំនៅរួចរាល់ហើយ ត្រូវរាយការណ៍ទៅកាន់ចៅក្រមស៊ើបសួរពីទីលំនៅចុងក្រោយរបស់ខ្លួន ដោយការផ្លាស់ប្តូរទីលំនៅនេះ ត្រូវតែធ្វើការកត់ត្រាចូលទៅក្នុងកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនលើកដំបូង។[105]

ក្នុងករណីដែលជនត្រូវចោទជាបរទេសហើយមិនអាចនិយាយភាសាខ្មែរបាន ចៅក្រមស៊ើបសួរត្រូវតែរកអ្នកបកប្រែឲ្យ ដើម្បីមានភាពងាយស្រួលដល់ជនត្រូវចោទក្នុងការផ្តល់ចម្លើយដល់ចៅក្រមស៊ើបសួរ តែចំពោះអ្នកបកប្រែត្រូវតែធ្វើសម្បថជាដាច់ខាតមុនពេលបកប្រែឲ្យជនត្រូវចោទចៀសវាងក្នុងការបកប្រែលើស ឬខ្វះពីការពិត។ ក្នុងករណីនេះ អ្នកបកប្រែភាសាមិនអាចរើសចេញពីចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ សាក្សី ឬភាគីជាដើមបានឡើយ។[106]

### ៣.២.៤.២. ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺដើម្បីទទួលបានព័ត៌មានដែលពាក់ព័ន្ធទៅនឹងបទល្មើស ហើយជាដំណាក់កាលមួយក្នុងការបំភ្លឺឲ្យឃើញកាន់តែច្បាស់នូវអង្គហេតុណាមួយ។ ចៅក្រមស៊ើបសួរអាចសួរចម្លើយដល់ជនត្រូវចោទនៅពេលដែលមានមេធាវីអម ហើយប្រសិនបើចៅក្រមស៊ើបសួរចង់ធ្វើការសួរចម្លើយ ចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីរបស់ជនត្រូវចោទយ៉ាងតិច ៥ថ្ងៃ មុននឹងធ្វើការសួរចម្លើយ។[107] ចៅក្រមស៊ើបសួរមិនអាចធ្វើការសួរចម្លើយ

[102] មាត្រា១៤៣ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[103] មាត្រា១៤៣ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[104] មាត្រា១៤៣ កថាខណ្ឌទី៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[105] មាត្រា១៤៣ កថាខណ្ឌទី៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[106] មាត្រា១៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[107] មាត្រា១៤៥ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ជនត្រូវចោទដោយគ្មានមេធាវីការពារខ្លួនរបស់ជនត្រូវចោទនោះបានទេ។ ចៅក្រមស៊ើបសួរអាចធ្វើការសួរចម្លើយជនត្រូវចោទ ដោយមិនចាំបាច់មានមេធាវីអមក៏បានដែរ ប្រសិនបើជនត្រូវចោទបានបោះបង់ចោលនូវវត្តមានរបស់មេធាវីការពារក្តីឲ្យខ្លួន។ ក្នុងករណីពិសេសដែលមានភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចធ្វើការសួរចម្លើយដល់ជនត្រូវចោទដោយមិនបាច់កោះហៅមេធាវីបានដែរ។[108] ក្នុងករណី ដែលចៅក្រមស៊ើបសួរបានកោះហៅមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទទៅតាមពេលកំណត់ ប៉ុន្តែមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទមិនបានចូលខ្លួនតាមការកំណត់ នោះចៅក្រមស៊ើបសួរអាចសួរចម្លើយ ជនត្រូវចោទដោយគ្មានមេធាវីការពារសិទ្ធិបាន ហើយចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសលើកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទដោយមូលហេតុអវត្តមានមេធាវីការពារសិទ្ធិជនត្រូវចោទ។[109] នៅពេលដែលសួរចម្លើយជនត្រូវចោទ មានសំណួរមួយចំនួនមិនអាចធ្វើការសួរទៅលើជនត្រូវចោទបានឡើយ ហើយចំពោះសំណួរដែលមិនត្រូវបានអនុញ្ញាតឲ្យសួរនោះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយ។[110] ព្រះរាជអាជ្ញា ព្រមទាំងមេធាវីក៏អាចលើកសំណួរមកសួរជនត្រូវចោទបានដែរ នៅពេលដែលចៅក្រមស៊ើបសួរបានសួរចម្លើយចប់សព្វគ្រប់ហើយ។[111] មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវបានគេស្តាប់ ឬថតបាននោះទេ។ មេធាវីអាចអានលិខិតសំណុំរឿងឲ្យកូនក្តីស្តាប់បាន ប៉ុន្តែមិនអាចឲ្យលិខិតថតចម្លងពីលិខិតសំណុំរឿងដល់កូនក្តីបានឡើយ។[112] ជាទូទៅ នៅពេលដែលជនត្រូវចោទបានបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរលើកដំបូង ហើយកន្លងអស់រយៈពេល៤ខែ ហើយជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយក្នុងករណីដែលជនត្រូវចោទបានធ្វើការស្នើសុំ។ ក្នុងរយៈពេល១ខែ ក្រោយពីជនត្រូវចោទបានស្នើសុំហើយ តែចៅក្រមស៊ើបសួរនៅតែមិនព្រមកោះហៅជនត្រូវចោទទេ ជនត្រូវចោទអាចធ្វើការប្តឹងទៅកាន់សភាស៊ើបសួរបាន។[113]

### ៣.២.៤.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ការស្តាប់ចម្លើយរបស់ចៅក្រមស៊ើបសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបាននូវព័ត៌មានដែលអាចពាក់ព័ន្ធនឹងបទល្មើស ឬអំពើនៃព្យសនកម្មផ្សេងៗដែលជាហេតុបណ្តាលមកពីការប្រព្រឹត្តបទល្មើស និងការទាមទារសំណងនៃការខូចខាត។ ដើមបណ្តឹងរដ្ឋប្បវេណីអាចពឹងពាក់មេធាវី ដើម្បីមកការពារប្រយោជន៍របស់ខ្លួនបាន។ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីការពារក្តី ជាដំបូងចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីភាគី

---

108 មាត្រា១៤៥ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

109 មាត្រា១៤៥ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

110 មាត្រា១៤៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

111 មាត្រា១៤៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

112 មាត្រា១៤៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

113 មាត្រា១៤៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិច០៥ (ប្រាំ) ថ្ងៃមុនពេលសួរចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ពិនិត្យសំណុំរឿងឡើងវិញ។ មេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីត្រូវអមកូនក្ដីរបស់ខ្លួន ទើបចៅក្រមស៊ើបសួរអាចសួរចម្លើយបាន ប៉ុន្តែប្រសិនបើនៅក្នុងករណីពិសេសដែលមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅថ្ងៃដែលបានកោះហៅទៅតាមដីកាកោះរបស់ចៅក្រមស៊ើបសួរ នោះចៅក្រមស៊ើបសួរអាចសួរចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបានដោយគ្មានមេធាវីអម។ ការសួរចម្លើយដោយគ្មានមេធាវីអម ចៅក្រមស៊ើបសួរត្រូវតែចុះនិទ្ទេសអំពីអវត្តមានរបស់មេធាវីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកំណត់ហេតុសួរចម្លើយ។[114] នៅពេលដែលសួរចម្លើយទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា ក៏ដូចជាមេធាវីអាចសួរសំណួរបានដែរ ប៉ុន្តែត្រូវតែជាសំណួរដែលមានការយល់ព្រម ឬអនុញ្ញាត ពីសំណាក់ចៅក្រមស៊ើបសួរ។[115] នៅពេលដែលសួរចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការសាកសួរអំពីព័ត៌មានដែលជនល្មើសបានប្រព្រឹត្តទៅលើជនរងគ្រោះ។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរត្រូវធ្វើការសាកសួរអំពីអំពើទាំងឡាយ ព្រមទាំងរាល់វត្ថុទាំងឡាយដែលជនល្មើសបានយកមកធ្វើជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើសនោះផងដែរ។

#### ៣.២.៤.៤. ការស្ដាប់ចម្លើយរបស់សាក្សី

ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្ដែងឲ្យឃើញនូវការពិត ដូចជាសាក្សីជាដើម។[116] សាក្សីគឺជាបុគ្គលដែលបានឃើញផ្ទាល់ ឬបានដឹងឮចំពោះហេតុការណ៍ណាមួយជុំវិញការប្រព្រឹត្តបទល្មើសនៅទីកន្លែងកើតហេតុ។ ចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅសាក្សីនោះឲ្យចូលមកបង្ហាញខ្លួនទៅតាមដីកា ដែលបានកោះហៅឲ្យចូលបំភ្លឺក្នុងនាមជាសាក្សី ដែលបានឃើញផ្ទាល់ ឬបានដឹងឮចំពោះហេតុការណ៍នោះ ដែលនៅក្នុងដីកានោះត្រូវចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណរបស់ចៅក្រមស៊ើបសួរ
- អត្តសញ្ញាណរបស់សាក្សី
- កាលបរិច្ឆេទ ដែលតម្រូវឲ្យសាក្សីចូលបំភ្លឺ
- កម្មវត្ថុនៃការកោះហៅ ពោលគឺដើម្បីបំភ្លឺ
- អត្តសញ្ញាណរបស់ជនត្រូវចោទ និងអត្តសញ្ញាណនៃបទល្មើស
- ចុះកាលបរិច្ឆេទនៃដីកា ព្រមទាំងហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងមានបោះត្រា។

[114] មាត្រា១៥០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[115] មាត្រា១៥១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[116] មាត្រា១៥៣ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចៅក្រមស៊ើបសួរត្រូវធ្វើការសាកសួរទៅដល់សាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងគ្មានវត្តមានជនត្រូវចោទនៅចំពោះមុខឡើយ។[117] មុនពេលផ្ដល់ចម្លើយ សាក្សីត្រូវតែធ្វើសម្បថហើយត្រូវតែឆ្លើយតាមសំណួរដែលចៅក្រមស៊ើបសួរបានសួរ ហើយត្រូវនិយាយតាមការពិតនូវរាល់សកម្មភាព ដែលបានឃើញនៅអំឡុងពេលមានបទល្មើសកើតមានឡើង។[118] ប្រសិនបើក្នុងករណីដែលសាក្សីគឺជាក្រុមគ្រួសារ ដូចមានសហព័ទ្ធ ឬឪពុក ម្ដាយ បងប្អូន ឬអនីតិជនដែលមានអាយុតិចជាង១៤ ឆ្នាំ មិនត្រូវបានឲ្យធ្វើសម្បថនោះឡើយ។[119] ចៅក្រមស៊ើបសួរក៏អាចសួរចម្លើយរបស់សាក្សីតទល់គ្នាជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងជនត្រូវចោទបានផងដែរ។ បន្ទាប់ពីបានស្ដាប់ចម្លើយរបស់សាក្សីរួចមក ចៅក្រមស៊ើបសួរនឹងបន្តនីតិវិធីផ្សេងៗទៀតសម្រាប់ពន្លឿនដល់ការដាក់បន្ទុកទៅលើជនត្រូវចោទបន្ថែមទៀត។ ប្រសិនបើចៅក្រមស៊ើបសួរបានចេញដីកាកោះហៅឲ្យចូលបំភ្លឺរួចហើយ ប៉ុន្តែសាក្សីមិនបានមកបង្ហាញខ្លួន ឬមានភាពរឹងទទឹងក្នុងការចូលបំភ្លឺ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យកងកម្លាំងសាធារណៈធ្វើការ បង្ខំសាក្សីនោះឲ្យចូលមកបង្ហាញខ្លួនបាន។[120] ក្នុងករណីពិសេស ប្រសិនបើសាក្សីមានជម្ងឺមិនអាចចូលមកបំភ្លឺបាន ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរអាចនាំក្រឡាបញ្ជីធ្វើដំណើរទៅកាន់លំនៅឋានរបស់សាក្សីដើម្បីធ្វើការសួរចម្លើយ។[121]

### ៣.២.៤.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរ និងចាប់យកវត្ថុដែលជាវត្ថុតាងបាននៅកន្លែងដែលមានបទល្មើសកើតឡើង។[122] ចំពោះកន្លែងដែលមានបទល្មើសកើតឡើង ត្រូវបិទមិនអនុញ្ញាតឲ្យសាមញ្ញជនចេញចូលតាមចិត្តនោះទេ ហើយត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើក្នុងករណីដែលគ្មានអ្នកកាន់កាប់ទីកន្លែងទេ ចៅក្រមស៊ើបសួរត្រូវធ្វើការឆែកឆេរនៅចំពោះមុខសាក្សីចំនួន២រូប ប៉ុន្តែត្រូវចុះនិទ្ទេសពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗឲ្យបានច្បាស់លាស់នៅលើកំណត់ហេតុស្ដីពីការឆែកឆេរ[123] ដែលនៅពេលចុះទៅធ្វើការឆែកឆេរនៅកន្លែងដែលមានបទល្មើសកើតឡើង ចៅក្រមស៊ើបសួរត្រូវតែធ្វើកំណត់ហេតុមួយស្ដីពីការចុះឆែកឆេរ ដោយមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

---

[117] មាត្រា១៥៣ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[118] មាត្រា១៥៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[119] មាត្រា១៥៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[120] មាត្រា១៥៣ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[121] មាត្រា១៥៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[122] មាត្រា១៥៩ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[123] មាត្រា១៥៩ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចំពោះការឆែកឆេររបស់ចៅក្រមស៊ើបសួរ សាក្សីដែលមានវត្តមាននៅពេលនោះ មិនអាចជាមន្ត្រីនគរបាល ឬជាកងរាជអាវុធហត្ថបាននោះទេ (កងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរ)។ ការឆែកឆេរមិនអាចធ្វើមុនម៉ោង៦ព្រឹក និងក្រោយម៉ោង១៨ល្ងាចបាននោះទេ លុះត្រាតែកន្លែងនោះជាកន្លែងដែលបើកចំហជាសាធារណៈ និងកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។[124] នៅក្នុងករណីដែលជនត្រូវចោទជាមេធាវី ហើយការឆែកឆេរត្រូវនៅកន្លែងមេធាវី នោះត្រូវធ្វើការឆែកឆេរនៅចំពោះមុខប្រធានគណៈមេធាវី ឬមុខបណ្ដាប្រតិភូរបស់គណៈមេធាវី បន្ទាប់មកត្រូវចុះពីវត្តមានរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គណៈមេធាវីនៅក្នុងកំណត់ហេតុ។ ការឆែកឆេរត្រូវតែធ្វើនៅគ្រប់ទីកន្លែងដែលជនត្រូវចោទបានយកមកធ្វើជាកន្លែងប្រព្រឹត្តបទល្មើស ឬយកធ្វើជាកន្លែងសម្រាប់លាក់ឧបករណ៍ដែលបានប្រព្រឹត្តបទល្មើស។ កន្លែងដែលត្រូវឆែកឆេរអាចជាលំនៅឋាន ទីកន្លែងធ្វើការ ទីកន្លែងលាក់ខ្លួនរបស់ជនត្រូវចោទជាដើម។ ឧបករណ៍មួយចំនួន ដែលជនត្រូវចោទយកធ្វើជាឧបករណ៍នៅក្នុងការប្រព្រឹត្តបទល្មើស ពេលចៅក្រមស៊ើបសួររកឃើញនៅពេលដែលចុះឆែកឆេរ លោកអាចចាប់យកជាវត្ថុតាង និងបោះត្រាលើវត្ថុតាងសម្រាប់ធ្វើជាកំណត់ហេតុ ព្រមទាំងត្រូវបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង។[125] បន្ទាប់មកត្រូវធ្វើកំណត់ហេតុមួយទៀតស្ដីពីការចាប់បានវត្ថុតាង ហើយត្រូវចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីព្រមទាំងអ្នកដែលបានកាន់កាប់ទីកន្លែង។

### ៣.២.៤.៦. ការធ្វើកោសលវិច័យ

ក្នុងដំណាក់កាលនៃការស៊ើបសួរ ការធ្វើកោសលវិច័យគឺជាវិធីមួយដ៏សំខាន់ ដែលត្រូវបានច្បាប់អនុញ្ញាតឲ្យចៅក្រមស៊ើបសួរបញ្ជាឲ្យមន្ត្រីជំនាញធ្វើកោសលវិច័យសម្រាប់បង្ហាញពីការពិតជុំវិញរឿងហេតុនៃបទល្មើសណាមួយ។ ក្នុងពេលដែលមានបញ្ហាបច្ចេកទេសចោទណាមួយបានកើតឡើង ចៅក្រមស៊ើបសួរអាចបង្គាប់មន្ត្រីជំនាញឲ្យធ្វើកោសលវិច័យដោយការធ្វើកោសលវិច័យនេះ ត្រូវបានធ្វើឡើងដោយ៖

- ចៅក្រមស៊ើបសួរបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង
- តាមពាក្យសុំរបស់ព្រះរាជអាជ្ញា
- តាមពាក្យសុំរបស់ជនត្រូវចោទ
- តាមពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

ប្រសិនបើចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ហើយក្នុងករណីដែលពាក្យសុំនោះចេញពីព្រះរាជអាជ្ញា ដីកានេះត្រូវសម្រេចក្នុងរយៈពេលចំនួន០៥ (ប្រាំ)ថ្ងៃ និងក្នុងករណីដែលពាក្យសុំនេះចេញពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី ដីកានេះ

[124] មាត្រា១៥៩ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[125] មាត្រា១៦០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ត្រូវសម្រេចក្នុងរយៈពេលចំនួន ០១ខែ។ ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់អ្នកសុំជាបន្ទាន់។[126] ចៅក្រមស៊ើបសួរត្រូវចេញដីកាចាត់តាំងអ្នកជំនាញបញ្ជាក់ពីបេសកកម្មរបស់អ្នកជំនាញ និងរយៈពេលនៃការបំពេញបេសកកម្មតែអ្នកជំនាញក្នុងការធ្វើកោសលវិច័យ។[127] ករណីដែលត្រូវប្រគល់វត្ថុទៅឲ្យក្រុមជំនាញសម្រាប់ធ្វើកោសលវិច័យ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់បានវត្ថុប្រគល់ទៅឲ្យក្រុមជំនាញសម្រាប់បើកការធ្វើកោសលវិច័យ។ មុនការបំពេញបេសកកម្មរបស់ខ្លួន ក្រុមជំនាញត្រូវតែស្ដាប់ចម្លើយរបស់គ្រប់បុគ្គលទាំងអស់ដែលបានពាក់ព័ន្ធនឹងបទល្មើស ប៉ុន្តែក្រុមជំនាញមិនចាំបាច់ស្ដាប់ចម្លើយរបស់ជនត្រូវចោទក៏បានដែរ។[128] នៅក្នុងករណីពិសេសណាមួយដែលក្រុមជំនាញបានស្ដាប់ចម្លើយពីបុគ្គលទាំងអស់នោះមិនបានច្បាស់ ក្រុមជំនាញអាចស្ដាប់ចម្លើយរបស់ភាគីជនត្រូវចោទបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

**៣.២.៤.៧. ការស្ដាប់ទូរស័ព្ទ**

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើការស្ដាប់ទូរស័ព្ទបានក្នុងករណីចាំបាច់ ដែលមានគោលបំណងស្វែងរកឲ្យឃើញនូវការពិត ឬជាប្រយោជន៍ចំពោះបទល្មើសទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងបណ្ដាញទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយសារតាមទូរសារ ឬសារតាមអ៊ីនធើណេតបានផងដែរ ដើម្បីជម្រុញឲ្យការស៊ើបសួររបស់ចៅក្រមស៊ើបសួរមានភាពរហ័ស និងមានប្រសិទ្ធភាព។ ប្រសិនបើចៅក្រមស៊ើបសួរបានប្រើគ្រប់មធ្យោបាយហើយ ប៉ុន្តែមិនអាចធ្វើការស្វែងរកជនត្រូវចោទដើម្បីសួរចម្លើយទេ ក្នុងករណីដែលមានលេខទំនាក់ទំនងទៅជនត្រូវចោទ ចៅក្រមស៊ើបសួរអាចធ្វើការទាក់ទងទៅកាន់ជនត្រូវចោទសម្រាប់ ផ្ដល់ជាចម្លើយដែលវាជាលក្ខណៈតាមប្រព័ន្ធអេឡិចត្រូនិច។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរអាចធ្វើការស្នើសុំទៅគ្រប់អង្គភាពសាធារណៈដែលមានជំនាញវិជ្ជាជីវៈ ឬគ្រប់មន្ត្រីរាជការជំនាញសម្រាប់តាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរ ត្រូវចេញនូវដីកាសម្រេច និងធ្វើការបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងត្រូវចាប់ និងរយៈពេលដែលត្រូវអនុវត្តបេសកកម្ម។ ករណីនេះអង្គភាពសាធារណៈមន្ត្រីរាជការ ដែលត្រូវបានចាត់តាំងត្រូវបំពេញបេសកកម្មទៅតាមពាក្យស្នើសុំរបស់ចៅក្រមស៊ើបសួរ។ ចំពោះបេសកកម្មដែលបានបំពេញរួចហើយត្រូវធ្វើការចម្លងជាលាយលក្ខណ៍អក្សរនូវគ្រប់សម្លេងដែលបានថតបានហើយត្រូវប្រគល់ជូនទៅកាន់ចៅក្រមស៊ើបសួរព្រមទាំងបិទស្លាកសម្គាល់ផងដែរ។[129]

[126] មាត្រា១៦២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[127] មាត្រា១៦៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[128] មាត្រា១៦៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[129] មាត្រា១៧២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៣.២.៥. ការចាត់ឲ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការបើកការស៊ើបសួរ ហើយនៅអំឡុងពេលដែលបំពេញភារកិច្ចរបស់ខ្លួន អាចជួបប្រទះនឹងឧបសគ្គផ្សេងៗ ដែលនាំឲ្យមិនអាចបំពេញភារកិច្ចដោយខ្លួនឯងបាន។ នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចឲ្យអ្នកផ្សេងបំពេញភារកិច្ចជំនួសខ្លួនបានទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឲ្យចៅក្រមផ្សេងនៃតុលាការដែលខ្លួនស្ថិតនៅ ឬតុលាការផ្សេងទៀតក្រៅពីតុលាការដែលខ្លួនស្ថិតនៅ ឬមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងអង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរជំនួស។[130] ករណីនេះចៅក្រមស៊ើបសួរត្រូវចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ដោយត្រូវបញ្ជាក់អំពីកិច្ចដែលតម្រូវឲ្យធ្វើជំនួស ហើយមានការទាក់ទងផ្ទាល់ជាមួយនឹងបទល្មើស ដែលត្រូវបានចោទប្រកាន់ និងត្រូវណែនាំឲ្យបានច្បាស់លាស់ ព្រមទាំងកំណត់អំពីថិរវេលា ដែលត្រូវអនុវត្តដីកាឲ្យស៊ើបសួរជំនួសឲ្យបានម៉ឺងម៉ាត់ផងដែរ ហើយចៅក្រមស៊ើបសួរក៏អាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសនេះបានគ្រប់ពេលវេលាផងដែរ។[131] នៅពេលដែលដីកាចាត់ឲ្យស៊ើបសួរជំនួសបានប្រគល់ទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិត្រឹមតែត្រួតពិនិត្យប៉ុណ្ណោះ។ ក្នុងករណីមួយចំនួនចៅក្រមស៊ើបសួរមិនអាចប្រគល់ភារកិច្ចទៅឲ្យមន្ត្រីនគរបាល យុត្តិធម៌ធ្វើតែឯងបាននោះទេ ដែលករណីទាំងនោះមានដូចជា៖

- ការសួរចម្លើយជនត្រូវចោទ
- ការស្តាប់ចម្លើយភាគីដើមបណ្តឹងរដ្ឋប្បវេណី[132]
- ការផ្ទៀងផ្ទាត់ដើមនិងចុង ។ ការឆែកឆេរនៅក្នុងការិយាល័យមេធាវី។[133]

ចៅក្រមស៊ើបសួរបានប្រគល់ភារកិច្ចឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបសួរជំនួសតែពាក់កណ្តាលតែប៉ុណ្ណោះ ហើយចំពោះដីកាស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរគ្រប់សកម្មភាពដែលខ្លួនបានធ្វើកិច្ចស៊ើបសួរចាប់តាំងពីការបើកការស៊ើបសួររហូតដល់ពេលបិទការស៊ើបសួរវិញ។ ក្នុងករណីដែលមានការឃាត់ខ្លួនក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស អំណាចដែលប្រគល់ឲ្យព្រះរាជអាជ្ញាត្រូវប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។

### ៣.២.៦. វិធានការនិរន្តរាយ

កាលណាចៅក្រមស៊ើបសួរទទួលបានដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួររូបនោះ មានសិទ្ធិអំណាចក្នុងការធ្វើចំណាត់ការស៊ើបសួរជាបន្ត។ វិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរសំដៅលើ

130 មាត្រា១៧៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

131 មាត្រា១៧៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

132 មាត្រា១៨០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

133 មាត្រា៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

វិធានការទប់ស្កាត់ ដើម្បីចៀសវាងផលប៉ះពាល់ ឬធានាដល់ដំណើរការនៃនីតិវិធីឲ្យសម្រេចបានគោលដៅស្វែងរកការពិតដោយរលូនទៅបានល្អប្រសើរ។ វិធាននិវន្តរាយរបស់ចៅក្រមស៊ើបសួរជាឧបករណ៍មួយសម្រាប់ជាជំនួយដល់ដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងពេលបំពេញកិច្ចស៊ើបសួររបស់ខ្លួនដើម្បីស្វែងរកការពិត។ ក្រមនីតិវិធីព្រហ្មទណ្ឌបានបែងចែកវិធានការនិវន្តរាយចំនួន ០៣ ប្រភេទ គឺ

- វិធានការធានាឲ្យមានវត្តមានជនត្រូវចោទនៅមុខចៅក្រមស៊ើបសួរ
- វិធានការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ
- វិធានការរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ។[134]

#### ៣.២.៦.១. វិធានការធានាឲ្យមានវត្តមានជនត្រូវចោទនៅមុខចៅក្រមស៊ើបសួរ

កាលណាបុគ្គលណាម្នាក់ពុំឆ្លើយតបទៅនឹងការកោះហៅរបស់ចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចបង្ខំឲ្យជននោះមានវត្តមាននៅចំពោះមុខតុលាការក្នុងក្របខណ្ឌនៃការស៊ើបសួរ ដើម្បីស្វែងរកការពិត។ ចំពោះវិធានការបង្ខំដើម្បីធានាឲ្យមានវត្តមានរបស់ជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន។ ការប្រើប្រាស់នូវដីការបស់ចៅក្រមស៊ើបសួរនេះ មិនបានតម្រូវឲ្យប្រើប្រាស់ជាលំដាប់លំដោយនោះទេ ប៉ុន្តែការប្រើប្រាស់ដីកាណាមួយ (អាចចេញលើសពីមួយ) ជាសិទ្ធិក្នុងការសម្រេចរបស់ចៅក្រមស៊ើបសួរសម្រាប់ធានាប្រសិទ្ធភាពនៃកិច្ចស៊ើបសួររបស់ខ្លួនតាមការចាំបាច់។[135]

##### ៣.២.៦.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន

កាលណាមានតម្រុយលើជនណាថាមានពិរុទ្ធភាព ចៅក្រមស៊ើបសួរអាចចេញដីកាឲ្យចូលខ្លួន ដែលដីកានេះ គឺជាការបញ្ជារបស់ចៅក្រមស៊ើបសួរទៅដល់បុគ្គល ដែលមានតម្រុយអំពីពិរុទ្ធភាពឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។[136] ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- កាលបរិច្ឆេទ និងទីកន្លែងត្រូវចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ
- និងឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។[137]

---

[134] http://pheakdeylaw.com/en/publication/19, ចូលទស្សនាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១។

[135] https://www.youtube.com/watch?v=KW0yAOVOT34, ចូលទស្សនាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១។

[136] មាត្រា១៨៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[137] មាត្រា១៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

នគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដីកានេះឲ្យសាមីខ្លួនជនពាក់ព័ន្ធចុះហត្ថលេខា ឬផ្ដិតមេដៃទទួល ហើយត្រូវបង្វិលដីកានេះមួយច្បាប់ឲ្យទៅចៅក្រមស៊ើបសួរវិញ។[138] ការប្រើដីកានេះ នៅពេលដែលជនត្រូវចោទមិនរត់គេចខ្លួន ប៉ុន្តែមិនឆ្លើយតបនឹងដីកាកោះហៅ។ ដីកាបង្គាប់ឲ្យចូលខ្លួនមិនមានលក្ខណៈបង្ខំទេ ដូចនេះបានជាអ្នកប្រគល់ដីកាត្រូវឲ្យសាមីខ្លួនចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃទទួលដើម្បីតាមដាន និងរាប់ចំនួនដង ថាតើសាមីខ្លួនបានទទួលហើយ តែពុំព្រមចូលប៉ុន្មានដង។

#### ៣.២.៦.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួននេះ គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈក្នុងការស្វែងរក និងធ្វើការនាំខ្លួនបុគ្គលណាម្នាក់ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។[139] ក្រោយពីកោះហៅមួយលើក ពីរលើកឲ្យចូលខ្លួន ប៉ុន្តែសាមីខ្លួនមិនចូលខ្លួននោះទេ ចៅក្រមស៊ើបសួរចេញដីកាមួយទៀតហៅថា **ដីកាបង្គាប់ឲ្យនាំខ្លួន**។ ដីកានេះត្រូវតែចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- និងឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។[140]

ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ឲ្យនគរបាលយុត្តិធម៌ ហើយមានសិទ្ធិចូលទៅនាំខ្លួនជនពាក់ព័ន្ធក្នុងម៉ោងការងារពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច។[141]

#### ៣.២.៦.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន

នៅក្នុងករណីមួយចំនួន ចៅក្រមស៊ើបសួរអាចចេញដីកាឲ្យចាប់ខ្លួនបាន។[142] មុននឹងចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបាន ចៅក្រមស៊ើបសួរត្រូវតែមានទទួលយោបល់ពីព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាធានានូវការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួននេះ។[143] ចៅក្រមស៊ើបសួរត្រូវសរសេរមូលហេតុក្រោយពីមានយោបល់ពីព្រះរាជអាជ្ញា។ ការចេញដីកានេះ ត្រូវមានលក្ខខណ្ឌដូចជា៖

- កាលណាបទល្មើសជាបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- ឬបុគ្គលពាក់ព័ន្ធគេចខ្លួន មិនអាចដឹងអំពីទីកន្លែងច្បាស់លាស់។[144]

---

[138] មាត្រា១៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[139] មាត្រា១៩០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[140] មាត្រា១៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[141] មាត្រា១៩២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[142] មាត្រា១៩៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[143] មាត្រា១៩៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[144] មាត្រា១៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដីកានេះត្រូវតែចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- និងឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។

ដីកានេះគឺបង្គាប់ឲ្យកម្លាំងសាធារណៈស្រាវជ្រាវរកចាប់ និងនាំខ្លួនទៅពន្ធនាគារ ឬមន្ទីរឃុំឃាំង ព្រមទាំងបង្គាប់ដល់ប្រធានពន្ធនាគារ ឬមន្ទីរឃុំឃាំង ក្នុងការទទួល និងឃុំខ្លួនបុគ្គលនោះ ហើយដីកានេះអាចបិទផ្សាយជាសាធារណៈបាន។ ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យនគរបាលយុត្តិធម៌ ហើយមានសិទ្ធិចូលទៅចាប់ខ្លួនជនដែលមានចង្អុលបង្ហាញនៅក្នុងដីកាក្នុងម៉ោងការងារពីម៉ោង៦ព្រឹក ដល់ម៉ោង៦ល្ងាច។[145] ក្នុងករណីដែលចាំបាច់ការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួននេះអាចត្រូវដាក់ជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដើម្បីឲ្យនីតិវិធីមានប្រសិទ្ធភាពខ្ពស់។[146]

#### ៣.២.៦.១.៤. ដីកាបង្គាប់ឲ្យឃុំខ្លួន

ដីកាបង្គាប់ឲ្យឃុំខ្លួននេះ សំដៅទៅលើការបញ្ជារបស់ចៅក្រមស៊ើបសួរទៅដល់ប្រធានពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនតែក្នុងករណីដែលជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។[147] ការសម្រេចឃុំខ្លួនជនត្រូវចោទ ត្រូវផ្អែកលើមូលហេតុដូចមានចែងនៅមាត្រា ២០៥ គឺដើម្បីបញ្ចប់បទល្មើស កុំឲ្យធ្វើការគាបសង្កត់ដល់សាក្សី រក្សាភស្តុតាង រក្សាជនល្មើសទុកជូនតុលាការ ដើម្បីចាត់ការតាមនីតិវិធីការពារសុវត្ថិភាពជូនជនល្មើស និងរក្សាសណ្តាប់ធ្នាប់សង្គម។

ដីកានេះត្រូវតែចុះនិទ្ទេសដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- និងឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។[148]

#### ៣.២.៦.២. វិធានការដាក់ឲ្យស្ថិតក្រោមការពិនិត្យ

កាលណាជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយអំពីពិរុទ្ធភាពបានបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងករណីនោះចៅក្រមស៊ើបសួរត្រូវតែដាក់ជននោះឲ្យស្ថិតក្រោមការពិនិត្យ។[149] ចៅក្រមស៊ើបសួរ

---

[145] មាត្រា១៩៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[146] មាត្រា២០០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[147] មាត្រា២២០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[148] មាត្រា២២១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[149] មាត្រា១៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

មានសិទ្ធិអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាក៏ដោយ។ គោលបំណងនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យ គឺដើម្បីឲ្យចៅក្រមស៊ើបសួរជូនដំណឹង និងប្រាប់អំពីឋានៈរបស់ជននោះក្នុងឋានៈជាចារី ជាសហចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។ ទោះបីចៅក្រមស៊ើបសួរបានកោះហៅជននោះឲ្យចូលមកនៅក្នុងនាមជាសាក្សីក៏ដោយឲ្យ តែប្រសិនបើចៅក្រមស៊ើបសួរពិនិត្យឃើញថាជននោះមានតម្រុយពិរុទ្ធភាព បន្ទាប់ពីចៅក្រមស៊ើបសួរបានស្តាប់ចម្លើយជននោះរួច ចៅក្រមស៊ើបសួរនឹងជូនដំណឹងជននោះភ្លាមៗ ដោយបង្វែរឋានៈសាក្សីទៅជាជនត្រូវចោទ និងដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យភ្លាមៗ។ កាលណាជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យជនត្រូវចោទក្លាយជាភាគីនៃសំណុំរឿងព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរត្រូវប្រាប់អំពីសិទ្ធិនានារបស់ជននោះដូចជាសិទ្ធិការពារខ្លួនតាមរយៈសិទ្ធិទទួលជំនួយពីមេធាវី សិទ្ធិចូលរួមក្នុងការការពារខ្លួនដោយឆ្លើយ ឬមិនឆ្លើយសំណួររបស់ចៅក្រមស៊ើបសួរ សិទ្ធិត្រូវបានស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ សិទ្ធិទទួលបានព័ត៌មានអំពីការសម្រេចរបស់ចៅក្រមស៊ើបសួរ និងការអនុញ្ញាតឲ្យជនត្រូវចោទប្តឹងឧទ្ធរណ៍ជាអាទិ៍។ បន្ទាប់ពីវិធានការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវសម្រេចអំពីវិធានការរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការជាបន្ត។

**៣.២.៦.៣. វិធានការរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ**

ដើម្បីធានាឲ្យបាននូវការរក្សាជនត្រូវចោទឲ្យនៅក្រោមការចាត់ចែងរបស់តុលាការ ចៅក្រមស៊ើបសួរមានវិធានការសំខាន់ពីរដែលមានសិទ្ធិអំណាចបង្ខំតិច ឬច្រើន គឺ

- ការឃុំខ្លួនបណ្តោះអាសន្ន
- ការត្រួតពិនិត្យតាមផ្លូវតុលាការ។[150]

**៣.២.៦.៣.១. ការឃុំខ្លួនបណ្តោះអាសន្ន**

គោលការណ៍សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋត្រូវយកមកអនុវត្តគឺ ជនត្រូវចោទនៅតែមានសេរីភាព ប៉ុន្តែក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវជាប់ឃុំខ្លួនបណ្តោះអាសន្នតាមរយៈដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃការឃុំខ្លួន។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបានក្នុងករណីបទឧក្រិដ្ឋ ហើយការឃុំខ្លួនបណ្តោះអាសន្ន ចំពោះបទមជ្ឈិមបានលុះត្រាតែទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមនោះមានថិរវេលាស្មើ ឬលើសពី ០១ (មួយ) ឆ្នាំ នៃទោសអតិបរមា[151] ដែលកំណត់ក្នុងច្បាប់ព្រហ្មទណ្ឌសារធាតុ ហេតុនេះការឃុំខ្លួនបណ្តោះអាសន្នចំពោះបទលហុមិនត្រូវបានអនុវត្តទេ។ ការឃុំខ្លួនបណ្តោះអាសន្ន អាចផ្តួចផ្តើមពីសេចក្តី

[150] មាត្រា២០៣ ដល់មាត្រា២៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[151] មាត្រា២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សន្និដ្ឋានរបស់ព្រះរាជអាជ្ញា ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬដោយផ្តើមចេញពីចៅក្រមស៊ើបសួរផ្ទាល់។[152] ទោះបីការផ្តួចផ្តើមស្នើសុំឃុំខ្លួននេះ ចេញពីព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីការស្នើសុំនេះមិនចងកាតព្វកិច្ចក្នុងការសម្រេចរបស់ចៅក្រមស៊ើបសួរទេ។ មុននឹងធ្វើការសម្រេចឃុំខ្លួន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទថានឹងធ្វើការឃុំខ្លួន ឬមានការស្នើសុំឲ្យមានការឃុំខ្លួន ដើម្បីឲ្យជនត្រូវចោទ ឬមេធាវីរបស់ជនត្រូវចោទលើកឡើងអំពីវិបាកនៃការឃុំខ្លួន ដើម្បីឲ្យចៅក្រមស៊ើបសួរពិចារណាសម្រេចសេចក្តី។ កាលណាចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងនេះភ្លាមទៅព្រះរាជអាជ្ញា និងជនត្រូវចោទដើម្បីបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងចិរវេលា០៥ (ប្រាំ)ថ្ងៃ។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ វាមានអានុភាពអនុវត្តភ្លាមដោយមិនរង់ចាំឲ្យផុតចិរវេលានៃបណ្តឹងឧទ្ធរណ៍០៥ (ប្រាំ)ថ្ងៃ ឬរង់ចាំរហូតដល់សភាស៊ើបសួរសម្រេច (ករណីមានបណ្តឹងឧទ្ធរណ៍) នោះទេ ព្រោះការសម្រេចរបស់ចៅក្រមស៊ើបសួរជាការសម្រេចដោយឯករាជ្យដែលឈរលើគោលការណ៍បែងចែកអំណាច ហើយរាល់ការសម្រេចរបស់ចៅក្រមស៊ើបសួរ លោកជាអ្នកទទួលខុសត្រូវដោយខ្លួនឯង។[153] ចំពោះការឃុំខ្លួនបណ្តោះអាសន្ន គឺត្រូវរាប់បញ្ចូលដោយស្វ័យប្រវត្តិក្នុងការផ្តន្ទាទោសស្ថាពរ។ ការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវសិក្សាអំពីមូលហេតុនៃការឃុំខ្លួន ចិរវេលានៃការឃុំខ្លួន និងការសម្រេចមិនឃុំខ្លួន ដែលចេញដោយដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។

### ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ដីកាឃុំខ្លួនបណ្តោះអាសន្នអាចចេញបាន លុះត្រាតែមានមូលហេតុនៃការឃុំខ្លួនណាមួយខាងក្រោម៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការទប់ស្កាត់បទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់មកលើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាផ្លូវសម្ភារៈ
- ដើម្បីការពារជនត្រូវចោទឲ្យមានសុវត្ថិភាព និងរក្សាជនត្រូវចោទសម្រាប់ទុកជូនតុលាការចាត់ការទៅតាមនីតិវិធី។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូលច្របល់ដែលបណ្តាលមកពីបទល្មើស។[154]

---

[152] មាត្រា២០៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[153] មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[154] មាត្រា២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

**ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវកំណត់ទៅតាមអាយុរបស់ជនត្រូវចោទ និងអាស្រ័យទៅនឹងប្រភេទនៃបទល្មើសផងដែរ។[155]

**ខ.១. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន**

ចំពោះបទមជ្ឈិមដែលបានប្រព្រឹត្តដោយនីតិជន នោះការឃុំខ្លួនបណ្តោះអាសន្នគឺមិនអាចឲ្យលើសពី០៤ខែបានទេ។ នៅពេលដែលផុតចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នោះចៅក្រមស៊ើបសួរអាចពន្យារពេលនៃការឃុំខ្លួនបានម្តងទៀត ដោយមិនឲ្យលើសពី០២ខែ និងពន្យារពេលបានចំនួនម្តងគត់ ដោយចេញនូវដីកាដែលមានសំអាងហេតុត្រឹមត្រូវ ព្រមទាំងត្រូវផ្តល់ដំណឹងដល់ជនត្រូវចោទឲ្យបានដឹង ។[156]

ចំពោះជនត្រូវចោទជានីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ត្រូវឃុំខ្លួនបណ្តោះអាសន្នមិនឲ្យលើសពី០៦ខែនោះឡើយ ហើយចំពោះការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នត្រូវ បានអនុញ្ញាតឲ្យធ្វើឡើងបានរយៈពេល០៦ខែ និងពន្យារពេលបានចំនួន០២ដង។[157]

**ខ.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន**

ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើសទាំងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចៅក្រមស៊ើបសួរមិនអាចធ្វើការឃុំខ្លួនបណ្តោះអាសន្ននោះឡើយ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវប្រគល់ជនត្រូវចោទជាអនីតិជននោះទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីថែរក្សាបណ្តោះអាសន្ន ប៉ុន្តែប្រសិនបើជនត្រូវចោទដែលជាអនីតិជននោះមិនមានឪពុកម្តាយ ឬអាណាព្យាបាលទេ ត្រូវប្រគល់ទៅឲ្យមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន ដើម្បីការពារកុំឲ្យមានការបំពានពីមជ្ឈដ្ឋានជុំវិញ និងរង់ចាំសេចក្តីសម្រេចរបស់តុលាការបន្តទៀត។[158]

ចំពោះអនីតិជនដែលមានអាយុពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ ហើយបានប្រព្រឹត្តបទមជ្ឈិម ត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្នមិនឲ្យលើសពី០២ខែឡើយ។ ចំណែកឯអនីតិជនដែលមានអាយុពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្នមិនឲ្យលើសពី០៤ខែទេ។ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន មិនអាចឲ្យលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ។[159]

---

155 មាត្រា២០៨ និងមាត្រា២០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

156 មាត្រា២០៩ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

157 មាត្រា២០៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

158 មាត្រា២១២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

159 មាត្រា២១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចំពោះអនីតិជនដែលមានអាយុពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ ហើយបានប្រព្រឹត្តបទឧក្រិដ្ឋត្រូវធ្វើការឃុំខ្លួនបណ្ដោះអាសន្នមិនឲ្យលើសពី០៤ខែឡើយ។ ចំណែកឯអនីតិជនដែលមានអាយុពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ត្រូវធ្វើការឃុំខ្លួនបណ្ដោះអាសន្នមិនឲ្យលើសពី០៦ខែបាននោះទេ។ [160]

**គ. ការសម្រេចមិនឃុំខ្លួន**

កាលណាចៅក្រមស៊ើបសួរបានទទួលបាននូវពាក្យបណ្ដឹងទៅតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលមានខ្លឹមសារស្នើសុំឲ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ប៉ុន្តែចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមការស្នើសុំរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នក្នុងរយៈពេល ០៥ ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុនោះឡើយ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងស្នើសុំ។ ក្នុងករណី ដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ០៥ ថ្ងៃទេ ព្រះរាជអាជ្ញាមានសិទ្ធិប្ដឹងសុំទៅសភាស៊ើបសួរសាលាឧទ្ធរណ៍បាន។[161]

**៣.២.៦.៣.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ**

ក្រៅពីវិធានការដកហូតសិទ្ធិសេរីភាពពោលគឺដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរក៏អាចសម្រេចឲ្យជនត្រូវចោទស្ថិតនៅក្រៅឃុំបានផងដែរ ពោលគឺតាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។[162] ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការដាក់ឲ្យជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលផ្ដល់នូវសេរីភាពដល់ជនត្រូវចោទមកវិញ ប៉ុន្តែត្រូវចងបុគ្គលនោះនូវកាតព្វកិច្ច ឬការហាមឃាត់ដែលមានចែងដោយច្បាប់។ ដើម្បីអាចប្រើវិធាននេះបាន លុះត្រាតែជនត្រូវចោទបានប្រព្រឹត្តអំពើ ដែលច្បាប់បានបញ្ញត្តិឲ្យទទួលទោសជាប់ពន្ធនាគារ។ ក្នុងករណី ដែលចៅក្រមស៊ើបសួរសម្រេចក្នុងការមិនឃុំខ្លួនបណ្ដោះអាសន្ន ឬសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរអាចដាក់ជននេះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយតម្រូវឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើនដូចជា៖

- មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។
- មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។
- មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ។
- ត្រូវបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
- ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

---

[160] មាត្រា២១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[161] មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[162] មាត្រា២២៣ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។
- មិនត្រូវបើកបររថយន្ត។
- មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។
- ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។
- ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងអាជីពបានឡើយ។[163]

ដោយឡែក ចំពោះដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមិនអាចធ្វើចំពោះអនីតិជនអាយុក្រោម ១៤ ឆ្នាំ បានឡើយ។[164] ក្នុងអំឡុងពេលដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ចៅក្រមស៊ើបសួរអាចកែប្រែកាតព្វកិច្ចចាស់ ដោយបន្ថែមកាតព្វកិច្ចថ្មីលុបកាតព្វកិច្ចដែលកំណត់ពីមុន កែប្រែកាលកំណត់របស់កាតព្វកិច្ចនីមួយៗព្យួរជាពិសេស ឬបណ្ដោះអាសន្ន។ ការកែប្រែនេះធ្វើឡើងដោយដីកាដែលមានលក្ខណៈដូចដីកាដំបូង។[165]

ការត្រួតពិនិត្យតាមផ្លូវតុលាការអាចបញ្ចប់ក្នុងពេលកំពុងស៊ើបសួរ ដោយមានការផ្ដើមគំនិតពីចៅក្រមស៊ើបសួរ ឬដោយមានការស្នើសុំពីព្រះរាជអាជ្ញា ឬជនត្រូវចោទ។[166] ការស្នើសុំធ្វើឡើងដោយសេចក្ដីសន្និដ្ឋាន ឬដោយពាក្យសុំដែលចុះបញ្ជីរដ្ឋបាលនៅលេខាធិការដ្ឋានអមសាលាដំបូងរាជធានី-ខេត្ត និងត្រូវសុំយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរសម្រេចដោយដីកាដែលមានបញ្ជាក់ ដោយសំអាងហេតុក្នុងរយៈពេល០៥ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីការបស់ចៅក្រមស៊ើបសួរអាចត្រូវរងនូវបណ្ដឹងឧទ្ធរណ៍ ប្រសិន បើចៅក្រមស៊ើបសួរចេញនូវដីកាសម្រេចបដិសេធតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។[167] ករណីនេះសភាស៊ើបសួរមានអំណាចបញ្ជាឲ្យរក្សាទុកការត្រួតពិនិត្យតាមផ្លូវតុលាការ ឬកែប្រែអត្ថន័យរបស់ដីកាសម្រេចការត្រួតពិនិត្យតាមផ្លូវតុលាការនេះ។ បើចៅក្រម

---

[163] មាត្រា២២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[164] មាត្រា២២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[165] មាត្រា២២៧, មាត្រា២២៨ និងមាត្រា២២៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[166] មាត្រា២១៥, ២១៦ និងមាត្រា២១៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[167] មាត្រា២២៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ស៊ើបសួរមិនសម្រេចក្នុងថិរវេលា ០៥ថ្ងៃ បន្ទាប់ពីមានការស្នើសុំពីបុគ្គល ដែលមានអត្ថប្រយោជន៍អាចប្ដឹងទៅសភាស៊ើបសួរដោយផ្ទាល់។

ក្នុងករណីដែលជនត្រូវចោទគេចវេសដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទនោះឲ្យនៅក្នុងឃុំជាបណ្ដោះអាសន្នវិញ ទោះបីទោសពន្ធនាគារដែលត្រូវទទួលរងនោះមានថិរវេលាប៉ុន្មានក៏ដោយ។ ការឃុំខ្លួនបណ្ដោះអាសន្នដែលសម្រេចដោយមានមូលហេតុមកពីការមិនគោរពកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចលើសពី០៤ខែ ចំពោះនីតិជន និង ០២ខែ ចំពោះអនីតិជន។ ចៅក្រមស៊ើបសួរ ក៏អាចសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្ន មកជាការត្រួតពិនិត្យតាមផ្លូវតុលាការវិញផងដែរ។ ប៉ុន្តែដីកានេះមិនទាន់មានអានុភាពអនុវត្តសម្រេចឲ្យដោះលែងភ្លាមនោះទេ គឺត្រូវរង់ចាំឲ្យផុតថិរវេលានៃបណ្ដឹងឧទ្ធរណ៍ ឬប្រសិនបើមានបណ្ដឹងឧទ្ធរណ៍ត្រូវឃុំខ្លួនរហូតដល់មានសេចក្ដីសម្រេចពីសភាស៊ើបសួរជាមុនសិន។

### ៣.២.៧. ការបិទការស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរបានយល់ឃើញថា ការស៊ើបសួរនេះមានលក្ខណៈគ្រប់គ្រាន់ដើម្បីបន្តនីតិវិធី ហើយចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរ។ ការបញ្ចប់ការស៊ើបសួរ គឺជាការបញ្ចប់នូវបេសកកម្មរបស់ចៅក្រមស៊ើបសួរ ដែលបានទទួលបន្ទុកក្នុងធ្វើការស៊ើបសួរទៅដល់ភាគីនៃរឿងក្ដីព្រហ្មទណ្ឌ ជាពិសេសគឺជនត្រូវចោទ។ នៅក្នុងដំណាក់កាលនេះ ចៅក្រមស៊ើបសួរនឹងធ្វើការសន្និដ្ឋានមួយបញ្ជូនទៅកាន់ព្រះរាជអាជ្ញាវិញ ព្រមទាំងជូនដំណឹងទៅដល់ភាគីនៃសំណុំរឿងនោះផងដែរ បន្ទាប់មកព្រះរាជអាជ្ញានឹងធ្វើការសន្និដ្ឋានស្ថាពររបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរវិញ។[168] យើងនឹងសិក្សាអំពីចំណុច ដែលបានបញ្ជាក់នៅខាងលើនេះ ដូចតទៅ៖

#### ៣.២.៧.១. ការបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញា

នៅពេលដែលចៅក្រមស៊ើបសួរបានបិទការស៊ើបសួររួចមក ចៅក្រមស៊ើបសួរនឹងធ្វើការជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដី ហើយនៅពេលក្រោយមកចំនួន ០២ ថ្ងៃ ចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាក្នុងការពិនិត្យវិញ។[169] ការសន្និដ្ឋានបញ្ជូនរឿងឲ្យត្រួតពិនិត្យផ្ទាល់មិនមែនជាដីកាដំណោះស្រាយទេ។ ចៅក្រមស៊ើបសួរចេញដីកាសន្និដ្ឋាននេះ ដើម្បីបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន និងត្រូវបញ្ជូនមកព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនរឿងឲ្យពិនិត្យទាំងមូល ហើយក្នុងករណីនេះព្រះរាជអាជ្ញានឹងធ្វើសេចក្ដីសន្និដ្ឋានស្ថាពរតាមរយៈដីកាសន្និដ្ឋានស្ថាពរទៅកាន់ចៅក្រមស៊ើបសួរវិញ ដើម្បីជាការឆ្លើយតបទៅចៅក្រមស៊ើបសួរវិញ ដោយឡែកចំពោះការឆ្លើយតបរបស់ព្រះរាជអាជ្ញាអាចជាការយល់ព្រម ឬមិនយល់ព្រមទៅលើដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ ឬដីកាលើកលែងចោទប្រកាន់) ឬព្រះរាជអាជ្ញាស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម។

---

[168] មាត្រា២៤៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[169] មាត្រា២៤៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

**៣.២.៧.២. ការសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា**

នៅពេលដែលបានទទួលសំណុំរឿងពីចៅក្រមស៊ើបសួររួចហើយ ក្នុងរយៈពេល ១៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង០១ខែ ក្នុងករណីជនត្រូវចោទនៅក្រៅឃុំ គិតចាប់ពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ដីកាសន្និដ្ឋានស្ថាពរត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ហើយនៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់។[170]

សេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា មិនអាចបង្ខំឲ្យចៅក្រមស៊ើបសួរយល់ស្របតាមនោះទេ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាសំណុំរឿងមិនទាន់ចប់សព្វគ្រប់ នោះព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងនេះទៅចៅក្រមស៊ើបសួរវិញ និងស្នើសុំឲ្យបើកការស៊ើបសួរបន្ថែមតាមរយៈដីកាបង្គាប់ឲ្យស៊ើបសួរបន្ថែម ដោយព្រះរាជអាជ្ញាត្រូវគោរពតាមបញ្ញត្តិ មាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញានៃក្រមនីតិវិធីព្រហ្មទណ្ឌ)។[171]

**៣.២.៧.៣. ដីកាដំណោះស្រាយ**

សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ គឺចង់សំដៅទៅលើសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលវាជាការសម្រេចសេចក្តីដែលតុលាការ ឬចៅក្រមអាចធ្វើឡើងបាន ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បានចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយដីកានេះ អាចជាដីកាលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនទៅជំនុំជម្រះ ។[172]

**៣.២.៧.៣.១. ដីកាលើកលែងចោទប្រកាន់**

ចៅក្រមស៊ើបសួរ ចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅៈ

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ
- ករណីបណ្តឹងអាជ្ញាបានរលត់។[173]

ករណីនេះចៅក្រមស៊ើបសួរ មិនអាចដោះលែងជននោះភ្លាមបានទេ លុះត្រាតែផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ដែលមានរយៈពេល០១ខែ គិតពីពេលប្រកាសដីកាសម្រាប់អគ្គព្រះរាជអាជ្ញាអម

[170] មាត្រា២៤៦ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[171] មាត្រា២៤៦ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[172] មាត្រា២៤៧ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[173] មាត្រា២៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សាលាឧទ្ធរណ៍ និង០៥ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងពីដីកាសម្រាប់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនដែលសុំឲ្យប្រគល់វត្ថុចាប់យកឲ្យខ្លួនវិញ។[174]

#### ៣.២.៧.៣.២. បញ្ជូនទៅជំនុំជម្រះ

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ការបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះនេះធ្វើឡើងតាមរយៈដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដោយដីកានេះត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[175] ដីកានេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

## ៣.៣. ដំណាក់កាលជំនុំជម្រះ

ការជំនុំជម្រះ គឺជាសវនាការដែលសម្រេចសេចក្ដីដោយចៅក្រមជំនុំជម្រះ ដែលជាអ្នកមានសមត្ថកិច្ចក្នុងការសម្រេចសេចក្ដីលើសំណុំរឿងព្រហ្មទណ្ឌនេះ។ មុននឹងមកដល់ដំណាក់កាលជំនុំជម្រះនេះ ត្រូវឆ្លងកាត់ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរជាមុនសិន។

### ៣.៣.១. ដំណាក់កាលមុនពេលជំនុំជម្រះ

មុនពេលធ្វើការជំនុំជម្រះ ចៅក្រមជំនុំជម្រះបានទទួលពាក្យបណ្ដឹងដែលបានបញ្ជូនមកដោយតំណាងអយ្យការអមសាលាដំបូង ឬចៅក្រមស៊ើបសួរនៃសាលាដំបូង ដើម្បីចាប់ផ្ដើមនូវនីតិវិធីនៃការជំនុំជម្រះ។ នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ហើយ ប្រធានតុលាការត្រូវធ្វើកំណត់កាលបរិច្ឆេទ នៃសវនាការលើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម។[176] ក្នុងរឿងក្ដីព្រហ្មទណ្ឌ ត្រូវទទួលពាក្យបណ្ដឹងឲ្យធ្វើការជំនុំជម្រះដោយ៖

- ដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា។[177]

#### ៣.៣.១.១. ការទទួលបណ្ដឹងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ

បន្ទាប់ពីចៅក្រមស៊ើបសួរបានបិទការស៊ើបសួររួចរាល់ហើយ ដោយបានកំណត់អំពីបទល្មើស ព្រមទាំងអត្តសញ្ញាណជនជាប់ចោទ និងប្រមូលបានភស្តុតាងគ្រប់គ្រាន់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះ

[174] មាត្រា២៧០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[175] មាត្រា២៤៧ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[176] មាត្រា២៩២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[177] មាត្រា២៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ស្រាយមួយ ពោលគឺដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ព្រមទាំងភ្ជាប់មកជាមួយនឹងឯកសារសំខាន់ៗ មួយចំនួនដែលពាក់ព័ន្ធទៅនឹងសំណុំរឿងនោះទៅកាន់ចៅក្រមជំនុំជម្រះ ដើម្បីឲ្យតុលាការចាត់ការទៅតាមនីតិវិធីបន្ត។[178]

### ៣.៣.១.២. ការទទួលបណ្តឹងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា គឺជាដីកាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅកាន់ជនជាប់ចោទ និងបញ្ជូនសំណុំរឿងនេះទៅធ្វើការជំនុំជម្រះផ្ទាល់ចំពោះបទល្មើសជាក់ស្តែង ដែលទណ្ឌកម្មមានកំណត់ក្នុងច្បាប់មិនលើសពី០១ឆ្នាំ ឬមិនលើស០៥ឆ្នាំ ហើយមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។[179] ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាវិធីមួយដែលតុលាការអាចយកមកអនុវត្តបានចំពោះបទមជ្ឈិមតូចតាច និងចំពោះបទលហុ ហើយសំណុំរឿងមានលក្ខណៈងាយស្រួល និងគ្រប់គ្រាន់ក្នុងការជំនុំជម្រះទោះបីជាជនជាប់ចោទជានីតិជន ឬអនីតិជនក្តី។

### ៣.៣.១.៣. ការទទួលបណ្តឹងតាមរយៈកំណត់ហេតុចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យជនជាប់ចោទចូលមកបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការនៃសាលាដំបូងរាជធានី-ខេត្ត ដោយមានកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើឡើងដោយព្រះរាជអាជ្ញាផ្ទាល់។ លក្ខខណ្ឌនៃការប្រើប្រាស់នូវនីតិវិធីនេះ គឺប្រសិនបើបទល្មើសនោះជាប្រភេទបទល្មើសជាក់ស្តែង ដែលការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច០១ឆ្នាំ និងយ៉ាងច្រើន០៥ឆ្នាំ ដែលមានជនជាប់ចោទជានីតិជន ហើយរឿងក្តីមានលក្ខណៈងាយស្រួលក្នុងការជំនុំជម្រះទើបអាចប្រើប្រាស់បាន។ [180]កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលត្រូវគេបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។[181]

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេនីតិវិធីត្រូវទុកជាមោឃៈ។ ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។ នៅពេលបង្ហាញខ្លួនដោយការចូលបង្ហាញខ្លួនភ្លាម តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ត្រូវប្រាប់

[178] មាត្រា២៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[179] មាត្រា៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[180] មាត្រា៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[181] មាត្រា៤៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដល់ជនជាប់ចោទថាសាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថារឿងក្ដីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ។

### ៣.៣.២. ដំណាក់កាលពេលជំនុំជម្រះ (សវនាការ)

នៅពេលដែលតុលាការបានទទួលសំណុំរឿង ដូចដែលបានបញ្ជាក់នៅដំណាក់កាលមុនពេលសវនាការរួចមក ប្រធានតុលាការ ដែលជាអ្នកមានសមត្ថកិច្ចត្រូវកំណត់អំពីកាលបរិច្ឆេទនៃសវនាការលើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម ដោយបើកសវនាការដើម្បីកំណត់ពីកាលបរិច្ឆេទនេះ។ នៅក្នុងករណីដែលបណ្ដឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរត្រូវបានតុលាការបានទទួលស្គាល់ ប្រធានតុលាការត្រូវកំណត់កាលបរិច្ឆេទនៃសវនាការទៅតាមរយៈពេល ដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួន ព្រមទាំងរយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនដើម្បីកំណត់កាលបរិច្ឆេទនេះត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា។[182]

#### ៣.៣.២.១. សមាសភាពក្នុងសវនាការ

##### ៣.៣.២.១.១. សមាសភាពជំនុំជម្រះ

សមាសភាពជំនុំជម្រះនៅក្នុងសវនាការនៃសាលាដំបូងរាជធានី-ខេត្ត មានដូចជា ចៅក្រមជំនុំជម្រះសម្រាប់ធ្វើការវិនិច្ឆ័យដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ ព្រមទាំងការសាកសួរនៅក្នុងពេលសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាង ដើម្បីធ្វើឲ្យការវិនិច្ឆ័យមានភាពសុក្រឹតមិនលំអៀងជាមួយនឹងក្រឡាបញ្ជី ដែលជាអ្នកកត់ត្រាទៅក្នុងកំណត់ហេតុនូវរាល់សកម្មភាពដែលកើតមាននៅក្នុងពេលសវនាការ ដូចជាវត្តមានរបស់ភាគីនៃរឿងក្ដី និងការសួរចម្លើយផ្សេងៗ។ នៅក្នុងពេលសវនាការ ចំពោះសំណុំរឿងដែលជាប្រភេទបទឧក្រិដ្ឋតម្រូវឲ្យមានចៅក្រមជំនុំជម្រះចំនួន៣រូប ដែលមានចៅក្រមជំនុំជម្រះ១រូប ជាប្រធានដឹកនាំអង្គសវនាការ។ ចំណែកឯសំណុំរឿងដែលជាប្រភេទបទមជ្ឈិម និងបទលហុ តម្រូវឲ្យមានចៅក្រមជំនុំជម្រះចំនួន ១រូប ជាប្រធានដឹកនាំអង្គសវនាការ។[183] នៅក្នុងចំណោមចៅក្រមទាំងបីរូបនេះ មានចៅក្រមមួយរូបគឺជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះ ចំណែកឯចៅក្រមពីររូបទៀតជាចៅក្រមប្រឹក្សា។ គួរបញ្ជាក់ផងដែរថា មុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា មានវិសមិតភាពនឹងគ្នា ដោយក្នុងករណីប្រសិនបើចៅក្រមណាម្នាក់បានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើ

[182] មាត្រា៤៥៧ និង៤៦៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[183] មាត្រា២៨៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សំណុំរឿងណាមួយហើយ ចៅក្រមនេះពុំអាចចូលរួមក្នុងការជំនុំជម្រះបានទេ បើពុំដូច្នេះទេសាលក្រមត្រូវទុកជាមោឃៈ។[184]

#### ៣.៣.២.១.២. សមាសភាពភាគី

ចំពោះសមាសភាពភាគី នៅក្នុងសវនាការមានដូចជា៖

- ជនជាប់ចោទ៖ គឺជាបុគ្គល ដែលតុលាការយល់ឃើញពីតម្រុយនៃពិរុទ្ធភាព ឬពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តបទល្មើស។
- ជនរងគ្រោះ ៖ បុគ្គលដែលទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ ឬជាបុគ្គលដែលទទួលរងនូវភាពអយុត្តិធម៌ដោយសារអំពើខុសច្បាប់ ដែលបណ្តាលឲ្យខូចខាតនូវរូបរាងកាយ ផ្លូវចិត្ត សេចក្តីថ្លៃថ្នូរ កិត្តិយស ទ្រព្យសម្បត្តិផ្ទាល់ខ្លួនជាអាទិ៍។
- ដើមបណ្តឹងរដ្ឋប្បវេណី ៖ អាចជាជនរងគ្រោះផ្ទាល់ ឬអ្នកតំណាងឲ្យភាគីខាងជនរងគ្រោះនៅក្នុងនីតិវិធីនៃដំណើរការរឿងក្តី។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែជាអ្នកតំណាងដោយស្របច្បាប់ និងទទួលបាននូវការយល់ព្រម ក៏ដូចជាការផ្ទេរសិទ្ធិរបស់ជនរងគ្រោះទៅឲ្យខ្លួន។
- អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ៖ ជាអ្នកតំណាងឲ្យជនជាប់ចោទក្នុងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីទាំងព្យសនកម្មនៃការខូចខាតដែលមានចំពោះជនរងគ្រោះ។
- ព្រះរាជអាជ្ញា ៖ អ្នកតំណាងអយ្យការសម្រាប់ចោទប្រកាន់បទល្មើសណាមួយ ទៅលើជនណាម្នាក់អោយតុលាការផ្តន្ទាទោស ព្រមទាំងតទល់ជាមួយនឹងជនជាប់ចោទ។
- មេធាវី ៖ ជាអ្នកតំណាងឲ្យភាគីណាមួយនៅក្នុងរឿងក្តីមិនថាជនរងគ្រោះ ឬជនជាប់ចោទឡើយ។ មេធាវីមិនមែនជាមន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សន៍ពីរដ្ឋនោះឡើយ មេធាវីគ្រាន់តែជាអ្នកប្រឹក្សាយោបល់ ជាអ្នកផ្សះផ្សា អ្នកសម្រុះសម្រួលឲ្យភាគីណាម្ខាង និងតាក់តែងលិខិតស្នាមដែលមានលក្ខណៈគតិយុត្តនៅក្នុងវិស័យច្បាប់តែប៉ុណ្ណោះ ហើយមេធាវីក៏មិនអាចតាំងខ្លួនជាដើមបណ្តឹងអាជ្ញានោះឡើយ។
- សាក្សី ៖ ជាបុគ្គលទាំងឡាយណាដែលបានឃើញ ឬបានដឹងឮអំពីសកម្មភាពទាំងឡាយដែលបានជនជាប់ចោទបានប្រព្រឹត្តទៅលើជនរងគ្រោះ ហើយព្រមចូលខ្លួនមកស្រាយបំភ្លឺរាល់សកម្មភាពដែលខ្លួនបានឃើញ ឬដឹងឮអំពីហេតុការណ៍នោះ។
- អ្នកជំនាញ អ្នកបកប្រែ ៖ ជាជំនួយការនៅក្នុងការបកប្រែ និយាយបន្ត ឬនិយាយជំនួសពីជនរងគ្រោះ ឬជនជាប់ចោទ ប្រសិនបើភាគីទាំងពីរមិនចេះនិយាយ ស្តាប់ភាសាខ្មែរបាន ឬមិនអាចនិយាយបានដោយមានមូលហេតុត្រឹមត្រូវ។[185]

---

[184] មាត្រា២៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[185] ឯកឧត្តម ធឿង សៀង, *នីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង*, ទំព័រទី១០។

#### ៣.៣.២.២. ដីកាកោះហៅឲ្យចូលសវនាការ

ចៅក្រមជំនុំជម្រះអាចធ្វើការកោះហៅឲ្យភាគីនៃសំណុំរឿងព្រហ្មទណ្ឌនោះឲ្យចូលសវនាការបានដោយចេញនូវដីកាកោះហៅមួយ រួចហើយបញ្ជូនទៅកាន់ភាគីនៃរឿងក្តីនោះ។[186] ចំពោះទម្រង់នៃដីកាកោះហៅភាគីនៃរឿងក្តីត្រូវធ្វើឡើងទៅតាមបុគ្គលដែលត្រូវបានកោះហៅ ដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដីកាកោះហៅជនជាប់ចោទត្រូវបានបញ្ជូនដោយព្រះរាជអាជ្ញា ឬ អាជ្ញាសាលា ហើយការបញ្ជូនដីកាកោះហៅនេះ ត្រូវបញ្ជូនឲ្យដល់ជនជាប់ចោទផ្ទាល់ដៃ ដោយតម្រូវឲ្យប្រើគ្រប់មធ្យោបាយទាំងអស់ ប៉ុន្តែប្រសិនបើអវត្តមានជនជាប់ចោទ ឬអ្នកដែលមានវត្តមានក្នុងលំនៅឋានរបស់ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅនេះ អាជ្ញាសាលាត្រូវប្រគល់ ដីកានេះទៅមេឃុំ ឬចៅសង្កាត់។ ចំពោះការប្រគល់ដីកាកោះហៅនីមួយត្រូវប្រគល់តែចុងដីកាតែប៉ុណ្ណោះ។[187] ក្នុងករណីដែលជនជាប់ចោទកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន ដីកានេះត្រូវបញ្ជូនដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[188]

ចំពោះដីកាកោះហៅបុគ្គលដែលពាក់ព័ន្ធមួយចំនួនដែលក្រៅពីជនជាប់ចោទ អាចត្រូវបានបញ្ជូនដោយព្រះរាជអាជ្ញា អាជ្ញាសាលា មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ក្រឡាបញ្ជី ឬតាមផ្លូវរដ្ឋបាល។ ចំណែករយៈពេលដែលត្រូវគោរពសម្រាប់ការកោះហៅភាគីក្រៅពីជនជាប់ចោទអោយចូលសវនាការ ក្រមនីតិវិធីមិនបានកំណត់នោះទេ។ ករណីនេះព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលអោយបានសមរម្យសម្រាប់បុគ្គលដែលពាក់ព័ន្ធ ដើម្បីឲ្យភាគីទាំងអស់នោះបានត្រៀមខ្លួនក្នុងការចូលសវនាការតាមការកោះហៅ។

#### ៣.៣.២.៣. ការចូលខ្លួនរបស់ភាគី

ការចូលខ្លួនរបស់ភាគី និងបុគ្គលត្រូវបានធ្វើការកោះហៅឲ្យចូលរួមសវនាការដោយព្រះរាជអាជ្ញា។

##### ៣.៣.២.៣.១. ការចូលខ្លួនរបស់ជនជាប់ចោទ

ជនជាប់ចោទ ត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយខ្លួនឯងផ្ទាល់ និងអាចអមដោយមេធាវីការពារសិទ្ធិដែលខ្លួនបានជ្រើសរើស ឬត្រូវបានចាត់តាំង។

- ក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួនដោយសេរី និងដោយខ្លួនឯង។[189]
- ក្នុងករណីនីតិវិធីបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវចូលបង្ហាញខ្លួន ដោយមានការឃុំគ្រងពីកងកម្លាំង ការពាររហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។[190]

[186] មាត្រា២៩៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[187] មាត្រា៤៥៨, ៤៥៩, ៤៦១ និង៤៦២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[188] មាត្រា៤៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[189] មាត្រា៣០២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[190] មាត្រា៣០៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

– ក្នុងករណីបញ្ជូនទៅជំនុំជម្រះតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ជនជាប់ចោទដែលស្ថិតនៅក្នុងឃុំ ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ ហើយជនជាប់ចោទដែលស្ថិតនៅក្រៅឃុំ ត្រូវចូលបង្ហាញខ្លួនដោយសេរី។[191]
– ករណីដែលជនជាប់ចោទពុំអាចចូលបង្ហាញខ្លួនបានដោយមានមូលហេតុស្ថានភាពសុខភាព ឬមូលហេតុធ្ងន់ធ្ងរ ប្រធានអង្គជំនុំជម្រះអាចបង្គាប់ឲ្យសួរជនជាប់ចោទ នៅកន្លែងដែលជនជាប់ចោទស្នាក់នៅបានដោយធ្វើឡើងនៅចំពោះមុខព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីរបស់ជនជាប់ចោទ ហើយត្រូវកត់ត្រាទុកនៅក្នុងកំណត់ហេតុ។[192]
– ករណីដែលជនជាប់ចោទមិនបង្ហាញខ្លួន នៅក្នុងសំណុំរឿងមជ្ឈិម ឬឧក្រិដ្ឋ តុលាការអាចបង្គាប់ឲ្យបង្អង់សំណុំរឿងនេះទុកសិន និងចេញដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទនេះ ដោយបញ្ជាក់អំពីកាលបរិច្ឆេទថ្មីនៃការបើកសវនាការ។[193]

**៣.៣.២.៣.២. ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើតាមការប្រកាសសាមញ្ញនៅចំពោះក្រឡាបញ្ជី។ ការប្រកាសនេះ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃអង្គជំនុំជម្រះ។ ដើមបណ្តឹងរដ្ឋប្បវេណី អាចចូលខ្លួនដោយផ្ទាល់ និងអមដោយមេធាវីដែលខ្លួនបានជ្រើសរើស ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្រគល់សិទ្ធិឲ្យមេធាវី សហព័ទ្ធផ្ទាល់ ឬញាតិលោហិតផ្ទាល់ ចូលសវនាការ និងធ្វើជាអ្នកតំណាងឲ្យខ្លួន។ ចំពោះអ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។[194]

**៣.៣.២.៣.៣. ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែកបណ្តឹងរដ្ឋប្បវេណី**

ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ត្រូវធ្វើឡើងតាមដីកាកោះហៅរបស់តុលាការ ហើយត្រូវមានមេធាវីអម ដែលខ្លួនបានជ្រើសរើស ដើម្បីចូលមកបង្ហាញខ្លួនចំពោះមុខតុលាការនៅក្នុងសវនាការ។ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីត្រូវតែឆ្លើយនូវរាល់សំណួរ ដែលតុលាការបានសួរក្នុងពេលសវនាការ ព្រមទាំងទទួលជំនួសផ្នែកសំណង ដែលជនជាប់ចោទបានប្រព្រឹត្តទៅលើជនរងគ្រោះ។ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីអាចប្រគល់សិទ្ធិឲ្យមេធាវី សហព័ទ្ធផ្ទាល់ ឬញាតិលោហិតផ្ទាល់ ចូលសវនាការ និងធ្វើជាអ្នកតំណាងឲ្យខ្លួន។ ចំពោះអ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។[195]

---

[191] មាត្រា៣០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[192] មាត្រា៣០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[193] មាត្រា៣១០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[194] មាត្រា៣១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[195] មាត្រា៣១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៣.៣.២.៣.៤. ការចូលខ្លួនរបស់សាក្សី

សាក្សីត្រូវបានកោះហៅដោយព្រះរាជអាជ្ញា ហើយចូលបង្ហាញខ្លួននៅក្នុងសវនាការទៅតាមកាលបរិច្ឆេទដែលតុលាការបានកំណត់ច្បាស់លាស់។[196] តុលាការអាចបញ្ជាកងកម្លាំង ដើម្បីធ្វើការនាំខ្លួនសាក្សីឲ្យចូលបង្ហាញខ្លួននៅក្នុងសវនាការសម្រាប់ធ្វើការស្រាយបំភ្លឺនូវអង្គហេតុ ដែលអាចជាប្រយោជន៍ដល់ភាគីនៅក្នុងសវនាការ ក៏ដូចជាតុលាការក្នុងការវិនិច្ឆ័យទៅលើអង្គហេតុឲ្យបានត្រឹមត្រូវ។

### ៣.៣.២.៤. កិច្ចដេញដោលក្នុងពេលជំនុំជម្រះ

ការពិភាក្សាដេញដោលត្រូវបានប្រព្រឹត្តនៅក្នុងសវនាការជាសាធារណៈនៅក្នុងការជំនុំជម្រះក្ដី លើកលែងតែក្នុងករណីពិសេស ការពិភាក្សាដេញដោលអាចត្រូវធ្វើឡើងទាំងស្រុង ឬមួយផ្នែកដោយសម្ងាត់ ដែលត្រូវធ្វើឡើងដោយសេចក្ដីសម្រេចមានសំអាងហេតុត្រឹមត្រូវ ហើយចំពោះសេចក្ដីសម្រេចនេះ មិនអាចធ្វើការតវ៉ាបានឡើយ។[197] ចំពោះអនីតិជន នៅក្នុងករណីខ្លះដែលតម្រូវឲ្យបើកការជំនុំជម្រះជាអាសាធារណៈ ដើម្បីការពារកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់អនីតិជននោះ។ តុលាការអាចបើកការជំនុំជម្រះដោយកំបាំងមុខ ពោលគឺបើកការជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ ដោយត្រូវស្វែងរកឲ្យឃើញនូវការពិតស្ដាប់ចម្លើយរបស់ភាគី និងសាក្សី ព្រមទាំងពិនិត្យវត្ថុតាងឲ្យបានច្បាស់លាស់។[198]

### ៣.៣.២.៥. សវនកម្ម និងភស្តុតាង

ក្រោយពីបានប្រាប់ឲ្យដឹងពីបទចោទប្រកាន់ទៅដល់ជនជាប់ចោទហើយ ចៅក្រមជំនុំជម្រះធ្វើការសួរទៅកាន់ជនជាប់ចោទនូវសំណួរដែលគិតថាជាប្រយោជន៍ក្នុងការស្វែងរកការពិតដែលអាចដាក់បន្ទុក ឬដោះបន្ទុកទៅដល់ជនជាប់ចោទ។ ក្រៅពីចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា មេធាវី និងភាគីដទៃទៀត ក៏អាចសួរសំណួរទៅកាន់ជនជាប់ចោទបានផងដែរ ដោយមានការអនុញ្ញាតពីប្រធានសវនាការ។[199] ប្រធានអង្គសវនាការធ្វើការស្ដាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេត អាចត្រូវបានស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីបានផងដែរ។

ភស្តុតាងនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ អាចដាក់ជូនតុលាការបានដោយសេរី ប៉ុន្តែស្ថិតនៅក្នុងច្បាប់កំណត់ ប្រសិនបើមានបញ្ញត្តិច្បាប់ណាហាមឃាត់នោះ មិនអាចដាក់ជាភស្តុតាងបានឡើយ។ វត្ថុតាង ដែលមានពាក់ព័ន្ធទៅនឹងជនជាប់ចោទ ក៏ដូចជាពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ ឬការសារភាព អាចត្រូវបានបង្ហាញនៅក្នុងពេលសវនាការ និង

[196] មាត្រា៣១៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[197] មាត្រា៣១៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[198] មាត្រា៣៣៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[199] មាត្រា៣២៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ប្រើប្រាស់ជាភស្តុតាងបាន ហើយចៅក្រមជំនុំជម្រះត្រូវថ្លឹងថ្លែងអំពីតម្លៃនៃភស្តុតាង ដែលបានដាក់មកជូន។ ចំពោះចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំ នោះតុលាការនឹងមិនចាត់ទុកថាជាភស្តុតាងនោះឡើយ។[200]

#### ៣.៣.២.៦. សេចក្តីសន្និដ្ឋានចុងក្រោយ

បន្ទាប់ពីបញ្ចប់នូវកិច្ចពិភាក្សាដេញដោលរួចហើយ ប្រធានសវនាការនឹងបើកឲ្យភាគីទាំងអស់មានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន ដើម្បីបញ្ជាក់ទៅកាន់តុលាការ។ ចំពោះសេចក្តីសន្និដ្ឋានចុងក្រោយត្រូវធ្វើតាមលំដាប់ដូចតទៅ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លីៗ
- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។

ស្របពេលដែលដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាអាចឆ្លើយតបទៅវិញបាននោះ ជនជាប់ចោទ និងមេធាវីរបស់ខ្លួន តម្រូវឲ្យនិយាយក្រោយគេបង្អស់ជានិច្ច។

## ៣.៤. សេចក្តីសម្រេចរបស់សាលាដំបូងរាជធានី-ខេត្ត

### ៣.៤.១. ការពិភាក្សាសម្រេច

ក្រោយពីបានស្តាប់អំពីសេចក្តីសន្និដ្ឋានចុងក្រោយរួចហើយ ចៅក្រមជំនុំជម្រះត្រូវលើកយកសំណុំរឿងនេះទៅធ្វើការពិភាក្សាសម្រេច។ នៅពេលដែលចៅក្រមជំនុំជម្រះធ្វើការពិភាក្សាសម្រេច គ្មានបណ្តឹងសុំ ឬទឡ្ហីករណ៍ណាមួយអាចដាក់ជូន ក៏ដូចជាយកមកធ្វើជាសំអាងទៀតបានឡើយ ហើយព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើការចូលរួមនៅក្នុងនីតិវិធីពិភាក្សាសម្រេចរបស់តុលាការឡើយ។[201]

### ៣.៤.២. ការប្រកាសសាលក្រម

#### ៣.៤.២.១. ការតាក់តែងសាលក្រម

សេចក្តីសម្រេចរបស់តុលាការជាន់ទាបត្រូវបានគេឲ្យឈ្មោះថា**សាលក្រម**។ សាលក្រមគឺជាការសម្រេចសេចក្តីដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ហើយកើតមានអានុភាពដោយសារការប្រកាសដោយផ្អែកលើលិខិតសាលក្រមនេះ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ហើយផ្នែកនៃសេចក្តីសម្រេចត្រូវអានឲ្យខ្លាំងៗ ដោយប្រធានសវនាការ។ សាលក្រមអាចត្រូវបានប្រកាសនៅក្នុងថ្ងៃដដែល ឬតុលាការអាចលើកទៅប្រកាសកាលបរិច្ឆេទក្រោយទៀត ប៉ុន្តែប្រសិនបើ

---

[200] មាត្រា៣២១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[201] មាត្រា៣៣៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សម្រេចថានឹងលើកទៅប្រកាសនៅកាលបរិច្ឆេទក្រោយ តុលាការត្រូវជូនដំណឹងដល់ភាគីដែលមានវត្តមាននៅក្នុងសវនាការ។[202] ចំពោះការប្រកាសអំពីពិរុទ្ធភាព តុលាការត្រូវពិនិត្យមើល ៖

- តើអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ?
- តើជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់ទៅលើជនរងគ្រោះ ឬទេ?

ប្រសិនបើពិនិត្យឃើញពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ ។ បើសិនតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទ នោះត្រូវបានសម្រេចឲ្យរួចផុតពីបទចោទ។

នៅក្នុងសាលក្រមត្រូវមានជាចាំបាច់នូវផ្នែកសំអាងហេតុ និងផ្នែកសម្រេច ព្រមទាំងនិទ្ទេសផ្សេងៗ

**ក. ផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេច**

- ផ្នែកសំអាងហេតុ ៖ ជាផ្នែកដែលតុលាការធ្វើការពិនិត្យមើលទឡ្ហីករណ៍នៃអង្គហេតុនីមួយៗ និងអង្គច្បាប់ ដែលត្រូវបានលើកឡើងនៅក្នុងសវនាការ។
- ផ្នែកសេចក្តីសម្រេច ៖ ជាផ្នែកដែលតុលាការចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត និងច្បាប់ដែលអនុវត្ត ព្រមទាំងទោសដែលតុលាការបានសម្រេច ហើយទោសនេះអាចមានទាំងទណ្ឌកម្មរដ្ឋប្បវេណីផងដែរ។[203]

**ខ. និទ្ទេសផ្សេងៗ**

និទ្ទេសដែលមាននៅក្នុងសាលក្រមមានដូចជា៖

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈរបស់តំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ ទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី
- ឈ្មោះរបស់មេធាវី។ [204]

---

[202] មាត្រា៣៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[203] មាត្រា៣៥៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[204] មាត្រា៣៥៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ប្រធានសវនាការ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើសាលក្រម រួចសាលក្រមដើមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុតចំនួន ០៨(ប្រាំបី)ថ្ងៃ ក្រោយការប្រកាសសាលក្រម។ ការិយាល័យក្រឡាបញ្ជីត្រូវតែរក្សាទុកនូវសាលក្រមដើមជានិច្ច។ ករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រម។

**៣.៤.២.២. ការជូនដំណឹងពីសាលក្រម**

គ្រប់សាលក្រមទាំងអស់មិនមែនសុទ្ធតែត្រូវបានធ្វើការជូនដំណឹងនោះទេ ដើម្បីឲ្យដឹងថាសាលក្រមណាខ្លះដែលត្រូវធ្វើការជូនដំណឹងនោះ គប្បីយល់ពីប្រភេទនៃសាលក្រមជាមុនសិន។ សាលក្រមត្រូវបានបែងចែកជាបីប្រភេទគឺសាលក្រមចំពោះមុខ សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ។

**៣.៤.២.២.១. សាលក្រមចំពោះមុខ**

នៅក្នុងករណី ដែលជនជាប់ចោទបានចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមគឺជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវបានឲ្យដំណឹងដល់ជននេះទេ ហើយសាលក្រមចំពោះមុខនេះអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍បាន។[205] ម្យ៉ាងទៀត សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះក្នុងករណីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ។[206] លើសពីនេះទៅទៀត កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលពុំបានបង្ហាញខ្លួនដោយសារតែមូលហេតុនៃសុខភាព ឬមានមូលហេតុធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យជនជាប់ចោទមិនអាចចូលទៅបង្ហាញខ្លួននៅក្នុងសវនាការបាន សាលក្រមនេះក៏នៅតែជាសាលក្រមចំពោះមុខផងដែរ[207] ហើយករណីនេះប្រធានសវនាការអាចធ្វើការបង្គាប់ឲ្យសួរចម្លើយជនជាប់ចោទនៅទីកន្លែងដែលជននោះស្នាក់នៅ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងត្រឹមត្រូវ សាលក្រមនេះ គឺជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយសាលក្រមចំពោះមុខនេះមិនត្រូវឲ្យដំណឹងដល់សាមីខ្លួនទេ។

**៣.៤.២.២.២. សាលក្រមដែលចាត់ទុកថាចំពោះមុខ**

ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីដីកាកោះហៅហើយនោះ សាលក្រមនោះនឹងត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវជូនដំណឹងដល់ជនជាប់ចោទ ហើយសាលក្រមនេះអាចត្រូវបានប្តឹងឧទ្ធរណ៍។ ក្នុងករណីជនជាប់ចោទអវត្តមានបានបង្ហាញនូវមូលហេតុអំពីអវត្តមានរបស់ខ្លួន ហើយ

[205] មាត្រា៣៦០ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[206] មាត្រា៣៦០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[207] មាត្រា៣៦០ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

តុលាការក៏បានទទួលថាត្រឹមត្រូវនោះ តុលាការអាចលើករឿងនេះទៅធ្វើការជំនុំជម្រះនៅសវនាការក្រោយទៀតបាន។[208]

### ៣.៤.២.២.៣. សាលក្រមកំបាំងមុខ

នៅក្នុងករណី ដែលជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការនោះទេ ហើយបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទត្រូវឲ្យដំណឹងដល់ជនជាប់ចោទនេះ ហើយសាលក្រមនេះអាចប្ដឹងទាស់បាន។[209]

ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយព្រមទាំងគ្មានអ្នកតំណាងត្រឹមត្រូវនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយសាលក្រមនេះអាចប្ដឹងទាស់បាន។[210]

---

[208] មាត្រា៣៦១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[209] មាត្រា៣៦២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[210] មាត្រា៣៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

# ជំពូកទី៤
# ដំណាក់កាលក្រោយចេញសាលក្រម

# ជំពូកទី៤
# ដំណាក់កាលក្រោយចេញសាលក្រម

នៅក្រោយពេល ដែលតុលាការចេញនូវសាលក្រមបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទហើយ ប៉ុន្តែមិនទាន់បានចូលជាស្ថាពរបុគ្គលនោះត្រូវបានគេហៅថា"**ពិរុទ្ធជន**" និងរង់ចាំការប្តឹងតវ៉ា ព្រមទាំងការដាក់ពាក្យប្តឹងឧបាស្រ័យ ហើយក្នុងករណីដែលសាលក្រមបានចូលជាស្ថាពរហើយ ពិរុទ្ធជននោះនឹងត្រូវបានគេហៅថា "**ទណ្ឌិត**"។ ក្រោយពីប្រកាសសាលក្រមដែលបានបញ្ជាក់អំពីពិរុទ្ធភាពហើយ ក្នុងអំឡុងពេលនេះទណ្ឌិត ឬពិរុទ្ធជន ត្រូវអនុវត្តនូវទោសដែលខ្លួនបានប្រព្រឹត្តទៅតាមច្បាប់នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិ។ លើសពីនេះ ភាគីនៃរឿងក្តីព្រហ្មទណ្ឌនេះរួមទាំងព្រះរាជអាជ្ញា អាចធ្វើការប្តឹងតវ៉ា ប្តឹងទាស់ និងប្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ក្នុងករណីដែលខ្លួនយល់ឃើញថាសេចក្តីសម្រេចមិនទាន់ត្រឹមត្រូវនៅឡើយ។ ជំពូកទី៤ ដែលជាដំណាក់កាលក្រោយពេលចេញសាលក្រមនេះ នឹងអធិប្បាយអំពីការអនុវត្តទោស បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍។

## ៤.១. ការអនុវត្តទោស

### ៤.១.១. និដ្ឋភាពទូទៅនៃការអនុវត្ត

ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ។ ចំណែកឯការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណី ដែលជាសំណងនៃការខូចខាតឆ្លើយតបទៅនឹងព្យសនកម្ម ដែលបានកើតចេញពីអំពើរបស់ចារីដែលបានប្រព្រឹត្តស្ថិតនៅក្រោមគំនិតផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។[211] អង្គការអយ្យការចាប់ផ្តើមធ្វើការអនុវត្តទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយជាស្ថាពរ។[212] ជាងនេះទៅទៀត ព្រះរាជអាជ្ញាអាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងការអនុវត្តទោស។

ក្នុងការអនុវត្តទោស ប្រសិនបើមានអត្ថិភាពនៃការលំបាកនានាបានកើតឡើង អយ្យការ ឬភាគីពាក់ព័ន្ធ ត្រូវលើកជូនតុលាការជាន់ដំបូងដែលបានសម្រេចផ្តន្ទាទោសនោះ ក្នុងគោលដៅដើម្បីដោះស្រាយ។ តុលាការទទួលពាក្យបណ្តឹងតាមពាក្យប្តឹងរបស់អយ្យការ ឬភាគីពាក់ព័ន្ធ និងសម្រេចនៅពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ។[213] ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ។ លើសពីនេះទៅទៀត តុលាការអាចសម្រេចស្រូបទោសបញ្ចូលគ្នាតាមពាក្យសុំដោយទទួលពីអយ្យការ ឬភាគីពាក់ព័ន្ធ ក្នុងករណីដែលពាក្យសុំស្រូបទោសបញ្ចូលគ្នានេះ ត្រូវបានលើកឡើងនៅមុខតុលាការ ដែលបានសម្រេចចុងក្រោយ។[214]

211 មាត្រា៤៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

212 មាត្រា៤៩៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

213 មាត្រា៥០០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

214 មាត្រា៥០១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ម្យ៉ាងវិញទៀត ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារនៅក្រោមបង្គាប់របស់អង្គការអយ្យការហើយត្រូវបង់ចូលថវិការដ្ឋ។ គ្រប់សេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរមានតម្លៃជាបញ្ជាឲ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី។[215] ដើម្បីធ្វើការអនុវត្តនូវទោស យើងត្រូវដឹងអំពីប្រភេទនៃទោសដែលតម្រូវឲ្យអនុវត្ត ដោយនៅក្នុងក្រមព្រហ្មទណ្ឌបានបែងចែកទោសព្រហ្មទណ្ឌជាបីប្រភេទដែលមានដូចជាមូលទោស អនុទោស ឬទោសបន្ថែម និងទោសជំនួស។[216]

### ៤.១.១.១. មូលទោស

មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោសត្រូវបានបែងចែកជាពីរប្រភេទគឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[217]

- ទោសដាក់ពន្ធនាគារ គឺជាទោសគុកដែលដកសិទ្ធិសេរីភាព មានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។
- ទោសពិន័យជាប្រាក់ គឺជាទោសដែលចៅក្រមជំនុំជម្រះប្រកាសឲ្យជនជាប់ចោទបង់ប្រាក់ចូលរដ្ឋតាមការកំណត់ឲ្យបង់ការពិន័យជាប្រាក់ត្រូវគិតជាប្រាក់រៀល។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។

### ៤.១.១.២. អនុទោស ឬទោសបន្ថែម

អនុទោស ឬទោសបន្ថែម គឺជាទោសមួយប្រភេទ ដែលតុលាការបានប្រកាសបន្ថែមទៅលើមូលទោសចំពោះជនជាប់ចោទ។ ទោសបន្ថែមអាចធ្វើការប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវបានចោទប្រកាន់ដោយតុលាការ។ ចំពោះទោសបន្ថែមនេះ តុលាការអាចធ្វើការប្រកាសក៏បាន មិនប្រកាសក៏បានដែរ។ ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ នោះទោសបន្ថែមត្រូវក្លាយជាកាតព្វកិច្ចរបស់ជនជាប់ចោទ។

អនុទោស ឬទោសបន្ថែម មានដូចជា៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ ។
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

---

[215] មាត្រា៥៩៨ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[216] មេរៀននីតិព្រហ្មទណ្ឌ ផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧, ភាគីទី៣។

[217] មាត្រា៤៣, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។
- ការព្យួរលិខិតបើកបរ។
- ការហាមឃាត់ចំពោះការស្នាក់នៅ។
- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិត ដែលជាជនបរទេស។
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។
- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍។[218]

#### ៤.១.១.៣. ទោសជំនួស

ទោសជំនួស គឺជាទោសដែលយកមកអនុវត្តជំនួសឲ្យមូលទោស ដោយតុលាការយកមកប្រកាស។ ប្រសិនបើតុលាការសម្រេចក្នុងការប្រកាសទោសជាទោសជំនួស នោះតុលាការមិនអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យបានទេ។[219] នៅពេលដែលធ្វើការវិនិច្ឆ័យចំពោះទោសដែលត្រូវប្រកាស តុលាការធ្វើការពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ហើយតុលាការអាចយកទោសជំនួសមកអនុវត្តជំនួសឲ្យមូលទោសវិញបាន។

---

[218] មាត្រា៥៣, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[219] មាត្រា៥៨, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ទោសជំនួសបានបែងចែងជាពីរ គឺ៖

- ការងារសហគមន៍៖ កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹងបីឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍។ ការងារសហគមន៍គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី៣០ ម៉ោង ទៅ២០០ ម៉ោងនូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[220]
- ទោសស្ដីបន្ទោស៖ តុលាការអាចធ្វើការស្ដីបន្ទោសដល់ជនជាប់ចោទ ប៉ុន្តែមិនផ្ដន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ឡើយ។ ទោសស្ដីបន្ទោសអាចយកមកអនុវត្តដោយមានលក្ខខណ្ឌបីមានដូចជា៖
  - ភាពចលាចលដែលបណ្ដាលមកពីការប្រព្រឹត្តបទល្មើសដល់សណ្ដាប់ធ្នាប់សង្គមត្រូវបានបញ្ចប់
  - ការខូចខាតត្រូវបានជួសជុលរួចហើយ
  - ជនជាប់ចោទ បានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[221]

### ៤.១.២. ការប្រតិបត្តិការឃុំខ្លួនបណ្ដោះអាសន្ន និងទោសដកហូតសេរីភាព

#### ៤.១.២.១. វិធានទាក់ទងនឹងការឃុំខ្លួន

ចិរវេលានៃការដាក់ពន្ធនាគារ ត្រូវគិតដូចខាងក្រោមទោសដាក់ពន្ធនាគារក្នុង១ ថ្ងៃ មានចិរវេលា ២៤ ម៉ោង។

- ទោសដាក់ពន្ធនាគារក្នុង០១ខែ មានចិរវេលា ៣០ ថ្ងៃ។
- ទោសដាក់ពន្ធនាគារលើសពី០១ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃនៅក្នុងខែមួយទៀត។[222]

ទណ្ឌិតដែលបានអនុវត្តទោសរួចហើយ ត្រូវបានដោះលែងនៅចន្លោះម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ល្ងាច។ គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណាអាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការឡើយ។ ការអនុវត្តដោយបំពាននឹងនាំឲ្យបុគ្គលនោះជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់។[223] អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើការអធិការកិច្ចលើ

---

[220] មាត្រា៧២, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[221] មាត្រា៧៦, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[222] មាត្រា៥០២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[223] មាត្រា៥០៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ពន្ធនាគារជាប្រចាំ។ ទោះបីជាទណ្ឌិតនោះស្ថិតក្នុងពន្ធនាគារក៏ដោយ ជននេះនៅតែមានសិទ្ធិសន្ទនាជាសម្ងាត់ជាមួយមេធាវីរបស់ខ្លួន។[224]

#### ៤.១.២.២. ការដោះលែងដោយមានលក្ខខណ្ឌ

ការបង្ហាញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ជាមូលហេតុដែលអាចនាំឲ្យទណ្ឌិតរូបនោះត្រូវបានដោះលែងដោយមានលក្ខខណ្ឌទោះបីជាជននេះត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើនយ៉ាងណាក៏ដោយ។[225]

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវបានផ្តល់ឲ្យទណ្ឌិតដែលទទួលរងទោសជាប់ពន្ធនាគារៈ

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១ឆ្នាំ
- ចំនួនពីរភាគបីនៃទោស ក្នុងករណីផ្សេងទៀត។

បន្ថែមពីលើនេះទៅទៀត ទណ្ឌិតដែលជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលបានការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ឆ្នាំ រួចមកហើយ។[226]

ប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន ជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការសម្រេចពីការដោះលែង ដោយមានលក្ខខណ្ឌ បន្ទាប់ពីទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។[227] ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ហើយសេចក្តីសម្រេចនេះ អាចជាកម្មវត្ថុដែលត្រូវប្តឹងតវ៉ាទៅប្រធានសាលាឧទ្ធរណ៍ក្នុងរយៈពេល០៥ថ្ងៃ ពីសំណាក់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះ។[228] ប្រធានសាលាឧទ្ធរណ៍ សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ។

សេចក្តីសម្រេចឲ្យដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិតព្រមទាំងកំណត់ពីរយៈពេលសាកល្បង ដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ។ ក្នុងករណីដែលមានការផ្តន្ទាទោសថ្មី ឬការមិនគោរពលក្ខខណ្ឌដែលមានកំណត់ក្នុងដីកាទេនោះប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន។ ក្នុងស្ថានភាពបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមី អាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ដោយត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម។[229]

---

[224] មាត្រា៥១០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[225] មាត្រា៥១២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[226] មាត្រា៥១៣ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[227] មាត្រា៥១៤ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[228] មាត្រា៥១៦ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[229] មាត្រា៥១៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់ ប្រសិនបើមានការដកហូតការដោះលែងដោយមានលក្ខខណ្ឌហើយរយៈពេលសេសសល់ត្រូវគិតចាប់ពីពេល ដែលទណ្ឌិតបានទទួលសេចក្តីសម្រេចឲ្យដោះលែងដោយមានលក្ខខណ្ឌ។[230] ក្នុងករណីដែលទណ្ឌិត ត្រូវបានចាប់ខ្លួនដោយអនុវត្តតាមមាត្រា ៥១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រយៈពេលឃុំខ្លួនរហូតមកទល់នឹងសេចក្តីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌ ត្រូវយកមកគិតក្នុងថិរវេលានៃទោសដែលនៅសេសសល់។ យ៉ាងណាមិញ ប្រសិនបើការដោះលែងដោយមានលក្ខខណ្ឌមិនត្រូវបានដកហូតក្នុងរយៈពេលសាកល្បងដែលកំណត់ដោយមាត្រា ៥១៧នៃក្រមនីតិវិធីព្រហ្មទណ្ឌនាំឲ្យការដោះលែងនឹងក្លាយជាស្ថាពរ។[231] ក្នុងស្ថានភាពនេះ ទោសត្រូវចាត់ទុកថាបានទទួលតាំងពីថ្ងៃដោះលែងដោយមានលក្ខខណ្ឌមក។

### ៤.១.៣. ការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយ ត្រូវអនុវត្តលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយដែលមិនបង់នូវប្រាក់ពិន័យប្រាក់ពន្ធនៃនីតិវិធីប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី។[232]

ការបង្ខំដល់រូបកាយត្រូវអនុវត្តដោយពេញលក្ខណៈច្បាប់ ហើយមិនចាំបាច់ប្រកាសដោយតុលាការទេ។ ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឲ្យដំណឹងថាប្រសិនបើមិនបង់នោះទេ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ។ រយៈពេលនេះមិនអាចតិចជាង១០ ថ្ងៃទេ។[233]

ការឲ្យដំណឹងត្រូវធ្វើៈ

- ដោយផ្ទាល់មាត់ ឬ
- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ជាលក្ខខណ្ឌចាំបាច់ចំពោះការឲ្យដំណឹង គឺត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឲ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតម្រាមដៃ។ កាលណាផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញានឹងចេញបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន។

[230] មាត្រា៥២០ កថាខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[231] មាត្រា៥២១ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[232] មាត្រា៥២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[233] មាត្រា៥២៥ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពសុខភាពរបស់ទណ្ឌិត។[234]

បញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន មានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃទណ្ឌិត
- ប្រភេទ និងការយោងនៃទណ្ឌកម្ម
- ការយោងនៃដីកាឲ្យដំណឹង
- ចំនួនទឹកប្រាក់ដែលមិនបានបង់
- ថិរវេលានៃការបង្ខំដល់រូបកាយ។

បញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួននេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។ ព្រះរាជអាជ្ញាសុំឲ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនចំពោះទណ្ឌិតនោះ។

ប្រសិនបើពេលចាប់ខ្លួន ឬឃុំខ្លួន ឬក្រោយមកទណ្ឌិតបានធ្វើការតវ៉ាចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទណ្ឌិតនោះនឹងត្រូវបានគេនាំខ្លួនទៅជូនប្រធានតុលាការ។[235] ប្រធានតុលាការត្រូវធ្វើការពិនិត្យមើលចំពោះនីត្យានុកូលភាពនៃបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន។ នៅក្នុងករណីមានការបំពានច្បាប់ ប្រធានតុលាការត្រូវលុបចោលនូវបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួននេះតាមរយៈដីកាដោយមានសំអាងហេតុត្រឹមត្រូវផងដែរ។ សេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង អាចត្រូវបានតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ០២ថ្ងៃ។ បណ្តឹងតវ៉ានេះអាចធ្វើបានឡើងដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញាអមសាលាដំបូង ឬទណ្ឌិត។[236]

ក្នុងករណីដែលប្រធានតុលាការជាន់ដំបូងបានលុបចោលនូវបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន សេចក្តីសម្រេចនេះនឹងគ្មានអានុភាពអនុវត្តទេនៅក្នុងរយៈពេល០២ ថ្ងៃ និងក្នុងករណីប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍មកវិញចំពោះសេចក្តីសម្រេចនេះ។ ប្រធានសាលាឧទ្ធរណ៍ត្រូវសម្រេចតាមដីកាមានសំអាងហេតុត្រឹមត្រូវ ហើយដីកានេះមិនអាចធ្វើការតវ៉ាបានឡើយ។ ក្នុងករណីលុបចោលបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន នោះទណ្ឌិតត្រូវដោះលែងឲ្យមានសេរីភាពវិញ។[237]

ថិរវេលានៃការបង្ខំដល់រូបកាយត្រូវកំណត់ដូចតទៅៈ

- ១០ ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០.០០០ រៀល។
- ២០ ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១ រៀលដល់ ៥០០.០០០ រៀល។

[234] មាត្រា៥២៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[235] មាត្រា៥២៧ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[236] មាត្រា៥២៧ កថាខណ្ឌទី៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[237] មាត្រា៥២៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- ០១ ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១ រៀលដល់ ១.០០០.០០០ រៀល។
- ០២ ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១.០០០.០០១ រៀលដល់ ២.៥០០.០០០ រៀល។
- ០៣ ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២.៥០០.០០១ រៀលដល់ ៥.០០០.០០០ រៀល។
- ០៦ ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥.០០០.០០១ រៀលដល់ ១០.០០០.០០០រៀល។
- ០១ ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០.០០០.០០១ រៀលដល់ ២០.៥០០.០០០រៀល។
- ១៨ ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០.០០០.០០០ រៀល។

កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើន នោះថិរវេលានៃការបង្ខំនេះត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។[238] ការបង្ខំដល់រូបកាយមិនអាចធ្វើទៅលើទណ្ឌិត ដែលជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះដែលមានវ័យចំណាស់បានឡើយពោលគឺប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ ឆ្នាំឡើងទៅបានឡើយ និងមិន អាចធ្វើបានព្រមជាមួយគ្នាទៅលើប្តី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ។[239]

ទណ្ឌិតដែលទទួលការបង្ខំរូបកាយរួចហើយនោះ នៅតែជំពាក់ចំនួនទឹកប្រាក់ដែលត្រូវបង់ដដែល។ ប៉ុន្តែទណ្ឌិតនេះ មិនត្រូវទទួលរងការបង្ខំរូបកាយចំពោះបំណុលដដែលនេះទៀតទេ។[240] កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ព្រះរាជអាជ្ញាឲ្យធ្វើការបង្ខំដល់រូបកាយបាន ប៉ុន្តែវាអាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវជូនភស្តុតាងថាខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាដើម។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ។[241]

ប្រសិនបើទណ្ឌិតមិនព្រមបង់ នាំឲ្យការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តនៅក្នុងលក្ខខណ្ឌ ដែលមានចែងនៅមាត្រា ៥២៣ ដល់មាត្រា ៥៣២ នៃក្រមនេះ។ ក្នុងករណីមានការប្រជែងគ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្ត នោះប្រាក់សំណង និងជម្ងឺចិត្តត្រូវមានអាទិភាពទទួលសងមុនគេ។[242]

238 មាត្រា៥៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

239 មាត្រា៥៣១ កថាខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

240 មាត្រា៥៣២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

241 មាត្រា៥៣៣ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

242 មាត្រា៥៣៣ កថាខណ្ឌទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៤.១.៤. ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

#### ៤.១.៤.១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ការផ្តល់ឲ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការអាចត្រូវបានផ្តល់ឲ្យ ឬមិនព្រមផ្តល់ឲ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ។[243]

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ៖[244]

- ៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៣ ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ឆ្នាំ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិត៖

- ពីការអនុវត្តទោសរួច
- ពីការអនុវត្តការបង្ខំដល់រូបកាយរួច នៅក្នុងករណីដែលមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា ៥៣៦ (ការផ្តល់ភស្តុតាងចាំបាច់) នៃក្រមនេះ។

ហេតុនេះហើយទណ្ឌិតត្រូវជូនភស្តុតាងដែលបញ្ជាក់ថាខ្លួនបានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តរួចហើយ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ចោលមិនទារប្រាក់សំណង និងជម្ងឺចិត្តទេ នោះទណ្ឌិតត្រូវផ្តល់ការបញ្ជាក់អំពីការបោះបង់នេះ លើកលែងតែរកដើមបណ្តឹងរដ្ឋប្បវេណីមិនឃើញ។[245]

ប្រសិនបើទណ្ឌិត ត្រូវបានបង្ខំដល់រូបកាយ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្តមិនមែនជាឧបសគ្គដល់ការឲ្យមាននីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតបានជូនភស្តុតាងថាខ្លួនស្ថិតក្នុងភាពអសាធនី។[246] ជាងនេះទៅទៀត ក្នុងករណីដែលអ្នកប្តឹងសុំ ត្រូវបានផ្តន្ទាទោសពីបទនិទ្ទនភាព[247] សាមីខ្លួនត្រូវជូនភស្តុតាងដែលបញ្ជាក់ថាបានទូទាត់ប្រាក់បំណុលនៃការក្ស័យធនរួចហើយ។ ប្រសិនបើម្ចាស់បំណុលបានបោះបង់ចោលមិនឲ្យទូទាត់ប្រាក់បំណុលនេះទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់ពីការបោះបង់នេះ។[248] ទណ្ឌិតត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី។ ទណ្ឌិតត្រូវចង្អុលបង្ហាញ

[243] មាត្រា៥៣៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[244] មាត្រា៥៣៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[245] មាត្រា៥៣៦ កថាខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[246] មាត្រា៥៣៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[247] បទនិទ្ទនភាព: បទល្មើសក្ស័យធន។

[248] មាត្រា៥៣៦ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។[249] ព្រះរាជអាជ្ញា ចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែង ដែលទណ្ឌិតធ្លាប់បានរស់នៅតាំងពីពេលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ហើយសុំឲ្យគេប្រគល់មកខ្លួនវិញនូវៈ

– លិខិតចម្លងនៃសេចក្ដីសម្រេចផ្ដន្ទាទោស
– លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តរួចហើយ
– ព្រឹត្តិបត្រលេខ១ នៃបញ្ជីថ្កោលទោស។

ក្រោយមក ព្រះរាជអាជ្ញាបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់មកជាមួយទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាធ្វើការប្ដឹងទៅកាន់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រមទាំងជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្ដឹងសុំ និងដល់មេធាវី។[250]

តុលាការត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា។ ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល ២ ឆ្នាំបានឡើយ។ យ៉ាងណាមិញ ប្រសិនបើពាក្យសុំលើកទី ១ ត្រូវបានតុលាការបដិសេធ ដែលបណ្ដាលមកពីការមិនគោរពរយៈពេលដែលចែងនៅមាត្រា ៥៣៥ នៃក្រមនេះ ពាក្យសុំថ្មីអាចធ្វើបានគិតចាប់ពីផុតរយៈពេលនោះ។[251]

#### ៤.១.៤.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទា ត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់ នៅក្នុងករណីដូចតទៅៈ[252]

- នៅពេលផុតរយៈពេល ៥ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីបុគ្គលនោះ ត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារមិនលើសពី ៥ឆ្នាំ ឬក៏ផ្ដន្ទាទោសពិន័យ។
- នៅពេលផុតរយៈពេល ១០ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីបុគ្គលនោះ ត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារលើសពី ៥ឆ្នាំ។

### ៤.២. បណ្ដឹងទាស់

ក្រោយពីសាលក្រមត្រូវបានប្រកាស ភាគីនៅក្នុងរឿងព្រហ្មទណ្ឌអាចប្ដឹងទាស់បាន ក្នុងករណីដែលសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខខ្លួន។

[249] មាត្រា៥៣៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[250] មាត្រា៥៣៩ កថាខណ្ឌទី១ និងទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[251] មាត្រា៥៤០ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[252] មាត្រា៥៤១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ៤.២.១. បុគ្គលដែលមានសិទ្ធិប្ដឹងទាស់

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ថាជនដែលអាចប្ដឹងទាស់បានមានដូចជាពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។

#### ៤.២.១.១. ពិរុទ្ធជន

ក្នុងករណីដែលសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខខ្លួន ពិរុទ្ធជនអាចប្ដឹងទាស់នឹងសាលក្រមនេះបាន។[253] ប្រសិនបើជនជាប់ចោទអវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ហើយតុលាការពុំមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ចោទបានទទួលដំណឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅទេ សាលក្រមដែលប្រកាសដោយតុលាការ គឺជាសាលក្រមកំបាំងមុខទោះបីជានៅពេលសវនាការ ប្រកាសជនជាប់ចោទមានវត្តមានក៏ដោយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ចោទមានវត្តមាននាពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោលសាលក្រមដែលចេញជាសាលក្រមចំពោះមុខ បើទោះបីជានៅពេលប្រកាសសាលក្រមជនជាប់ចោទអវត្តមានក៏ដោយ។ ក្នុងករណីបែបនេះ សាលក្រមត្រូវចាត់ទុកជាចំពោះមុខ ហើយត្រូវជូនដំណឹងទៅជនជាប់ចោទ។[254] ដោយហេតុថា ទោះបីជាសាលក្រមត្រូវបានប្រកាសដោយកំបាំងមុខដល់ជនជាប់ចោទក៏ដោយ តែជនជាប់ចោទប្រាកដជាបានដឹងពីថ្ងៃដែលត្រូវប្រកាសសាលក្រម ព្រោះថានៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោល ប្រធានសវនាការបានជូនដំណឹងដល់ភាគីដែលមានវត្តមានពីថ្ងៃដែលត្រូវប្រកាសសាលក្រមរួចហើយ។[255] ពិរុទ្ធជនអាចប្ដឹងទាស់នឹងសាលក្រមទាំងមូល ឬក៏កម្រិតការប្ដឹងទាស់ត្រឹមតែសេចក្ដីសម្រេចផ្ដន្ទាទោស ឬសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីបាន។[256] ក្នុងករណីដែលពិរុទ្ធជនធ្វើការប្ដឹងទាស់ ព្រះរាជអាជ្ញា, អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលបានទទួលពាក្យប្ដឹងទាស់របស់ពិរុទ្ធជន ត្រូវបញ្ជូនបណ្ដឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។[257] ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីក្នុងការដាក់ពាក្យប្ដឹងទាស់ ប៉ុន្តែត្រូវមានលិខិតប្រគល់សិទ្ធិ (តំណាងដោយអាណត្តិ) ផងទើបច្បាប់អនុញ្ញាត។ ប៉ុន្តែក្នុងករណីដែលពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយឪពុកម្ដាយ ឬអាណាព្យាបាល ដោយពុំបាំបាច់មានលិខិតប្រគល់សិទ្ធិទេ។[258]

253 មាត្រា៣៦៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

254 មាត្រា៣៦១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

255 មាត្រា៣៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

256 មាត្រា៣៦៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

257 មាត្រា៣៦៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

258 មាត្រា៣៦៦ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

កាលណាបណ្តឹងទាស់ធ្វើឡើងក្នុងការប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះត្រូវចាត់ទុកជាអសារបង់។ ការអនុវត្តសាលក្រមត្រូវព្យួរ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអានុភាព។[259]

### ៤.២.១.២. ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចប្តឹងទាស់នឹងសាលក្រមដែលសម្រេចកំបាំងមុខខ្លួនបាន។[260] បណ្តឹងទាស់នេះត្រូវកំណត់ទៅសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ។

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់បានដែរ តែត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងទាស់ទើបបាន។

### ៤.២.២. នីតិវិធី និងបែបបទនៃបណ្តឹង

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យមានសាមីខ្លួនដោយផ្ទាល់ដៃ ឬថ្ងៃដែលសាមីខ្លួនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់សាមីខ្លួនដោយផ្ទាល់ដៃទេ។[261] ការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវអនុលោមតាមមាត្រា ៤៨២ ដល់មាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកាឲ្យដំណឹងត្រូវធ្វើតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញារបស់អគ្គព្រះរាជអាជ្ញា ឬរបស់គូភាគី។[262] ដីកាឲ្យដំណឹងត្រូវចុះនិទ្ទេសដូចតទៅ៖

- ប្រភេទ និងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង
- អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង។

ដីកាឲ្យដំណឹងបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបានសម្រាប់ការប្តឹងទាស់ និងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង។ អ្នកជូនដំណឹងត្រូវភ្ជាប់នូវលិខិតចម្លងនៃសេចក្តីសម្រេច ដែលត្រូវជូនដំណឹងទៅនឹងដីកាឲ្យដំណឹងផងដែរ បើយោងតាមមាត្រា ៣៨៣ កថាខណ្ឌចុងក្រោយ។

ការជូនដំណឹងអាចធ្វើដោយ៖

- ព្រះរាជអាជ្ញា
- អាជ្ញាសាលា
- ក្រឡាបញ្ជី

[259] មាត្រា៣៧០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[260] មាត្រា៣៧២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[261] មាត្រា៣៦៨ និងមាត្រា៣៧២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[262] មាត្រា៤៨២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- អាជ្ញាធររដ្ឋបាល
- អាជ្ញាធរពន្ធនាគារ
- មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ។

ការប្រគល់ការជូនដំណឹងធ្វើតាមមធ្យោបាយដូចតទៅះ

ប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឲ្យដល់ភាគីពាក់ព័ន្ធ ដែលក្នុងករណីនេះ អ្នកប្រគល់ត្រូវចារលើសេចក្តីសម្រេចដើមថា លិខិតចម្លងត្រូវបានប្រគល់ឲ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ អ្នកប្រគល់ចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើម ក្នុងករណីដែលអ្នកប្រគល់ការជូនដំណឹងមិនមែនជាព្រះរាជអាជ្ញា សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់។[263]

ប្រសិនបើភាគីពាក់ព័ន្ធបានអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឲ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន។ អ្នកប្រគល់ត្រូវចារលើសេចក្តីសម្រេចដើមថាលិខិតចម្លងនៃសេចក្តីសម្រេច ត្រូវបានប្រគល់ឲ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន និងចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើមដែលត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ [264]បុគ្គល ដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់ឲ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត។ ក្នុងករណីនេះលិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចជាឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ។

ក្នុងករណីដែលភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច ឬគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ ឬគ្មានបុគ្គលណាម្នាក់ ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ព្រមទទួលសេចក្តីសម្រេចនោះទេ អ្នកប្រគល់ដីកាឲ្យដំណឹង ត្រូវប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំចៅសង្កាត់ ឬទៅជំទប់ ឬចៅសង្កាត់រងណាមួយ។ អ្នកប្រគល់ការឲ្យដំណឹងត្រូវចុះ និទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គល ដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតចម្លង ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម ដែលត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិត ត្រូវសន្យាថានឹងប្រគល់ឲ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។[265] ក្នុងករណីនេះ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចជាឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួន ដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោម

[263] មាត្រា៤៨៦ និងមាត្រា ៤៨៩ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[264] មាត្រា៤៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[265] មាត្រា៤៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សំបុត្រ។ ប្រសិនបើភាគីដែលពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីដែលពាក់ព័ន្ធនេះរស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា សេចក្ដីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្ដីសម្រេចតុលាការត្រូវចាត់ទុកជាកាលបរិច្ឆេទនៃការជូនដំណឹង។ ឯការប្រគល់ជូនដំណឹងត្រូវបានធ្វើតាមវិធីដូចដែលរៀបរាប់ខាងលើ គឺមានន័យថាការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវទៅតាមនីតិវិធី។[266] នៅពេលដែលមានពាក្យបណ្ដឹងទាស់ត្រឹមត្រូវ សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះ ដោយតុលាការដដែល(តុលាការដែលបានចេញសាលក្រមកំបាំងមុខ) ដោយភាគីទាំងអស់នឹងត្រូវបានកោះហៅ។

### ៤.២.៣. ប្រភេទនៃសេចក្ដីសម្រេចរបស់តុលាការ

សេចក្ដីសម្រេចរបស់តុលាការអាចជា៖

- សាលក្រមលើកចោលបណ្ដឹងទាស់ ដោយសារតែបណ្ដឹងទាស់មិនអាចទទួលបាន ដោយសារតែអ្នកដាក់ពាក្យប្ដឹងទាស់ជាជនដែលពុំមានសិទ្ធិប្ដឹងទាស់ ឬដោយសារតែការដាក់ពាក្យប្ដឹងទាស់ធ្វើឡើងផុតរយៈពេលដែលច្បាប់កំណត់។
- សាលក្រមប្រកាសថាបណ្ដឹងទាស់ទុកជាឯកសារឥតបានការ ហើយតម្កល់សាលក្រម ដែលគេប្ដឹងទាស់ទុកជាបានការដដែល ដោយមូលហេតុថាអ្នកប្ដឹងទាស់មិនចូលបង្ហាញខ្លួន នៅពេលសវនាការក្រោយពីបានទទួលការកោះហៅដោយត្រឹមត្រូវ។[267]
- សាលក្រមលើអង្គសេចក្ដី ក្នុងករណីដែលអ្នកប្ដឹងទាស់បង្ហាញខ្លួននៅពេលសវនាការ តុលាការអាចធ្វើការសម្រេចតម្កល់នូវសេចក្ដីសម្រេចដើម ឬកែប្រែ ឬបដិសេធសេចក្ដីសម្រេច ហើយសម្រេចសេចក្ដីសាជាថ្មីម្ដងទៀតបាន ទៅតាមស្ថានភាពនៃរឿងនីមួយៗ។

## ៤.៣. បណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ គឺជាផ្លូវនៃបណ្ដឹងឧបាស្រ័យដែលនាំឲ្យសំណុំរឿងត្រូវផ្ទេរទៅសាលាឧទ្ធរណ៍នៅក្នុងព្រំដែនដែលកំណត់ដោយលិខិតបណ្ដឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្ដឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍សម្រេចសេចក្ដីដោយត្រួតពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ ដែលសាលាជម្រះក្ដីថ្នាក់ក្រោមបានស្រាវជ្រាវ រកឃើញ និងបានអនុវត្ត។

### ៤.៣.១. បុគ្គលដែលអាចប្ដឹងឧទ្ធរណ៍

ជនដែលអាចប្ដឹងឧទ្ធរណ៍បានមាន៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

[266] មាត្រា៤៩០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[267] មាត្រា៣៧១ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[268]

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម(សាលាដំបូងរាជធានី-ខេត្ត)។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីតែត្រូវមានលិខិតប្រគល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍។ ប៉ុន្តែក្នុងករណី ដែលពិរុទ្ធជនជាអនីតិជន ឪពុកម្តាយ ឬអាណាព្យាបាល អាចតំណាងក្នុងការដាក់ពាក្យប្តឹងឧទ្ធរណ៍បាន ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ ប្រសិនបើពិរុទ្ធជនជាប់ឃុំមានបំណងប្តឹងឧទ្ធរណ៍ ការប្តឹងឧទ្ធរណ៍អាចធ្វើបាននៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[269] ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ អាចត្រូវបានតំណាងដោយមេធាវីសហព័ទ្ធ ឬញាតិលោហិតផ្ទាល់បានដែរតែត្រូវមានលិខិតប្រគល់សិទ្ធិ។

យ៉ាងណាមិញ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក៏អាចដាក់ពាក្យប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់តុលាការជាន់ដំបូងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍បានដែរ។[270]

### ៤.៣.២. រយៈពេលនៃការប្តឹងឧទ្ធរណ៍

រយៈពេលនៃការប្តឹងឧទ្ធរណ៍ស្ថិតទៅតាមបុគ្គល និងកាលៈទេសៈដែលមានដូចជា៖

- ចំពោះព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ ខែ គិតពីពេលប្រកាសសាលក្រម។[271] ក្នុងករណីមានការឃុំខ្លួន ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ក្នុងរយៈពេល៤៨ម៉ោង គិតចាប់ពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០៣ ខែ គិតចាប់ពីពេលប្រកាសសាលក្រម។
- ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ ខែ គិតពីពេលប្រកាសសាលក្រម កាលបើសាលក្រមនោះជាសាលក្រមចំពោះមុខ ឬគិតពីពេលដែលបានទទួលដំណឹងអំពីសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ។ ករណីមានការឃុំខ្លួន ពិរុទ្ធជនអាចធ្វើបណ្តឹងឧទ្ធរណ៍នៅក្នុងរយៈពេល០៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន។

---

[268] មាត្រា៣៧៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[269] មាត្រា៣៧៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[270] មាត្រា៣៧៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[271] មាត្រា៣៨១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ក្នុងករណីដែលភាគីណាមួយបានប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេល ដែលបានបញ្ជាក់នៅចំណុចខាងលើនេះ ភាគីដទៃទៀតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ អាចធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុក្នុងរយៈពេលបន្ថែម ០៧ ថ្ងៃ ដោយរយៈពេលបន្ថែមនេះ ផ្តើមគិតពីការផុតរយៈពេលធម្មតា។[272]

**ចំណាំ៖** ការប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខមិនអាចធ្វើទៅបានទេ ដោយហេតុថាមាត្រា ៣៨២ អនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍តែអំពីសាលក្រមចំពោះមុខ និងសាលក្រមចាត់ទុកជាចំពោះមុខប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងសព្វថ្ងៃនេះ បើទោះបីជាសាលក្រមកំបាំងមុខក៏ដោយ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវបានអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍បានផងដែរ ប្រសិនបើសាមីខ្លួនពុំមានបំណងក្នុងការប្តឹងទាស់ទៅនឹងសាលក្រមកំបាំងមុខ ប៉ុន្តែចង់ជ្រើសរើសយកនូវវិធីនៃការប្តឹងឧទ្ធរណ៍តែម្តង។ ការប្តឹងឧទ្ធរណ៍នឹងសាលក្រមកំបាំងមុខ ត្រូវធ្វើក្នុងរយៈពេល ០១ ខែ ដែលកំណត់ដោយច្បាប់ ដោយផ្តើមគិតពីពេលទទួលដំណឹងពីសាលក្រមកំបាំងមុខ។ ការទទួលយកបណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខនេះ ពុំត្រូវបានហាមឃាត់ក្នុងការប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខដោយក្រមនីតិវិធីព្រហ្មទណ្ឌទេ។ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតឲ្យសាមីខ្លួនធ្វើការប្តឹងទៅនឹងសាលក្រមដែលសម្រេចលើបណ្តឹងទាស់ថែមទៀតផង។

[272] មាត្រា៣៨១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

# សេចក្តីសន្និដ្ឋាន

# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទស្តីពី "**លំហូរនីតិវិធីនៃបណ្តឹងព្រហ្មទណ្ឌ**" រួចមកយើងអាចយល់បានថាការធ្វើបណ្តឹងព្រហ្មទណ្ឌមានលក្ខខណ្ឌដូចម្តេច ហើយនរណាខ្លះមានសិទ្ធិក្នុងការធ្វើបណ្តឹងព្រហ្មទណ្ឌនេះ ព្រមទាំងរបៀបនៃការយកបណ្តឹងរបស់ខ្លួនទៅដាក់នៅក្នុងតុលាការផងដែរ។ បន្ទាប់មកនៅពេលដែលមានការដាក់ពាក្យបណ្តឹងទៅលើរឿងក្តីព្រហ្មទណ្ឌណាមួយ គេត្រូវធ្វើចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌនោះ ដោយយកចិត្តទុកដាក់បំផុតចាប់តាំងពីដំណាក់កាលនៃការទទួលពាក្យបណ្តឹងរហូតដល់ការប្រកាសសាលក្រមជាពិសេស គឺការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះនីតិវិធីនៃការចាត់ចែងសំណុំរឿងព្រហ្មទណ្ឌមានទំនាក់ទំនងនឹងគ្នាយ៉ាងខ្លាំង ពោលគឺមានការប្រទាក់ក្រឡាគ្នាពីដំណាក់កាលមួយទៅ ដំណាក់កាលមួយ។

នៅដំណាក់កាលដាក់ពាក្យបណ្តឹង បានបង្ហាញឲ្យប្រជាពលរដ្ឋទាំងអស់ និងអ្នកដែលសិក្សាផ្នែកនីតិសាស្ត្រពិសេសគឺនៅក្នុងវិស័យតុលាការឲ្យបានឃើញ និងស្វែងយល់បន្ថែមអំពីការសរសេរពាក្យបណ្តឹង និងដាក់ពាក្យបណ្តឹងនៅពេលដែលមានបទល្មើសបានកើតឡើង។ ហើយនៅពេលដែលបានដាក់ពាក្យបណ្តឹង ហើយជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវរង់ចាំការសម្រេចរបស់ព្រះរាជអាជ្ញា ដែលជាអ្នកមានសមត្ថកិច្ចក្នុងការចោទប្រកាន់ ឬមិនចោទប្រកាន់។

ដំណាក់កាលព្រះរាជអាជ្ញា គឺជាដំណាក់កាលចោទប្រកាន់ដោយក្នុងករណីដែលព្រះរាជអាជ្ញាបានពិនិត្យនូវពាក្យបណ្តឹងរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ព្រមទាំងបានពិនិត្យអត្ថិភាពនៃបទល្មើស និងបានយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់ក្នុងការចោទប្រកាន់ លោកអាចធ្វើតាមនីតិវិធីដូចជាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ការបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្ហាញខ្លួនភ្លាម។ ប៉ុន្តែព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការផងដែរ ក្នុងករណីដែលមិនមានបន្ទុកគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់។ ដូច្នេះភាគីនៃរឿងក្តីព្រហ្មទណ្ឌត្រូវរង់ចាំការសម្រេចរបស់ព្រះរាជអាជ្ញាដោយពេលខ្លះ ព្រះរាជអាជ្ញាអាចចេញដីកាកោះហៅភាគីក្នុងការស៊ើបអង្កេតរឿងក្តីផងដែរ។

បន្ទាប់ពីព្រះរាជអាជ្ញា បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងបញ្ជូនសំណុំរឿងទៅដល់ចៅក្រមស៊ើបសួរហើយ ចៅក្រមស៊ើបសួរនឹងបើកការស៊ើបសួរទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរនេះ មានគំនិតក្នុងការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុកទៅកាន់ជនត្រូវចោទ។ គួរបញ្ជាក់ផងដែរថា ការបើកការស៊ើបសួរនេះមិនមែនចំពោះតែជនត្រូវចោទប៉ុណ្ណោះទេ ប៉ុន្តែត្រូវបើកការស៊ើបសួរទៅកាន់គ្រប់ភាគីនៃរឿងក្តីរួមជាមួយនឹងសាក្សីផងដែរ។ ក្នុងករណីដែលការស៊ើបសួរ ចៅក្រមស៊ើបសួរ

មានតម្រុយថាអង្គហេតុថ្មី និងបទល្មើសថ្មី មិនមាននៅក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះចៅក្រមស៊ើបសួរត្រូវបង្វិលសំណុំរឿងឲ្យព្រះរាជអាជ្ញាវិញ ដើម្បីចេញដីកាចាត់ឲ្យស៊ើបសួរបន្ថែម។ ក្រោយពីចៅក្រមស៊ើបសួរបានបញ្ចប់នៃកិច្ចនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងគ្រប់ភាគីនៅក្នុងសំណុំរឿង ហើយប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាកិច្ចស៊ើបសួរនោះគ្រប់លក្ខណៈហើយ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរទៅឲ្យចៅក្រមស៊ើបសួរវិញ។ បន្ទាប់ពីចៅក្រមស៊ើបសួរបានទទួលសំណុំរឿងពីព្រះរាជអាជ្ញាភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទាំងមូលទៅចៅក្រមជំនុំជម្រះ។ ក្រោយពីទទួលបានសំណុំរឿង ហើយចៅក្រមជំនុំជម្រះត្រូវបើកសវនាការដើម្បីធ្វើការជំនុំជម្រះ ហើយសេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះអាចជាការផ្តន្ទាទោសលើជនជាប់ចោទ ឬឲ្យជនជាប់ចោទរួចផុតពីបទចោទ។

លើសពីនេះទៅទៀត នៅក្រោយដំណាក់កាលជំនុំជម្រះរួចមក ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក៏អាចប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ចំពោះសាលក្រមបានផងដែរ។

ចំពោះចំណាត់ការក្នុងដំណាក់កាលនីមួយៗនៃអង្គការតុលាការ ដែលបានអនុវត្តទៅលើពាក្យបណ្តឹងពិតជាមានភាពច្បាស់លាស់ និងហ្មត់ចត់ខ្លាំងមុននឹងចេញសេចក្តីសម្រេចដែលអាចប៉ះពាល់ដល់សិទ្ធិ និងការបាត់បង់សេរីភាពទៅលើបុគ្គលណាម្នាក់ ដែលតុលាការបានចេញសេចក្តីសម្រេច ហើយសេចក្តីសម្រេចនោះអាចជាការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ ព្រមទាំងទុកពេលឲ្យភាគីនៃសំណុំរឿងបានប្តឹងទៅកាន់តុលាការជាន់ខ្ពស់ក្នុងករណី ដែលភាគីមិនពេញចិត្តនឹងការសម្រេចរបស់តុលាការជាន់ទាប។

សរុបសេចក្តីមក ចំពោះកិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សានេះបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីលំហូរនីតិវិធីនៃបណ្តឹង និងការធ្វើចំណាត់ការក្នុងរឿងព្រហ្មទណ្ឌ ដែលនៅគ្រប់ដំណាក់កាលនៃនីតិវិធីនីមួយៗ មានភាពប្រទាក់ក្រឡាគ្នា និងមានភាពហ្មត់ចត់យ៉ាងខ្លាំងបំផុតនៅក្នុងគោលបំណងស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋ ជាពិសេសគឺជនរងគ្រោះ ព្រមទាំងការពារជនរងគ្រោះ និងថែរក្សាសណ្តាប់ធ្នាប់សង្គមជាដើម។ ជាងនេះទៅទៀត គឺដើម្បីដាក់ទណ្ឌកម្មដល់ជនដែលប្រព្រឹត្តអំពើខុសនឹងច្បាប់ឲ្យរាងចាល។ ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដោយឡែកនានាដែលគាំទ្រដល់ច្បាប់ព្រហ្មទណ្ឌ មានចំនួនសមស្របដែលអនុញ្ញាតឲ្យមន្ត្រីអនុវត្តច្បាប់យកទៅប្រតិបត្តិបាន ដោយមានភាពស៊ីសង្វាក់គ្នាជាមួយនឹងបរិបទនៃសង្គមនាពេលបច្ចុប្បន្នផងដែរ។

## ២.អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងបានធ្វើសេចក្តីសន្និដ្ឋានរួចមក យើងខ្ញុំយល់ឃើញថាការដំណើរការនៃការអនុវត្តរឿងក្តីព្រហ្មទណ្ឌចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ការចេញសាលក្រមរបស់តុលាការជាន់ទាប ព្រមទាំងការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់តុលាការមានបញ្ហាមួយចំនួនក្នុងកិច្ចនីតិវិធីដូចជាការ

អនុវត្តជាក់ស្តែងនៅមានចំណុចអសកម្មពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស និងការរួមសហការ ដែលជាហេតុធ្វើឲ្យមានភាពចន្លោះប្រហោង និងយឺតយ៉ាងក្នុងការបំពេញការងារ។ ចំណែកឯមូលហេតុមួយទៀត ដែលធ្វើឲ្យប្រព័ន្ធយុត្តាធិការមានការធ្លាក់ចុះ និងធ្វើឲ្យប្រជាពលរដ្ឋលែងមានទំនុកចិត្តទៅលើស្ថាប័នតុលាការនោះគឺបក្សពួកនិយម និងបុគ្គលដែលមានឋានៈ ពោលគឺចំពោះអ្នកមានអំណាចក្នុងជួររដ្ឋាភិបាលដែលបានល្មើសច្បាប់ ហើយអាចគេចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ និងការអន្តរាគមន៍ ដោយអ្នកមានអំណាចផងដែរ។ ដើម្បីជាការរួមចំណែកធ្វើឲ្យកាន់តែប្រសើរឡើងនៅក្នុងវិស័យតុលាការនៃព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំជានិស្សិតសរសេរសារណាសូមចូលរួមផ្តល់ជាអនុសាសន៍បន្ថែមទៅលើចំណុចខ្វះខាតទាំងនោះដូចជា៖

- **ពង្រឹងការអនុវត្តច្បាប់៖** គប្បីធានានូវការអនុវត្តច្បាប់ចំពោះមន្ត្រីនគរបាលយុត្តិធម៌ឲ្យបានតឹងរឹង និងលុបបំបាត់ឲ្យបាននូវអំពើពុករលួយ ដែលនៅតែមាននៅក្នុងវិស័យតុលាការ។ ក្នុងករណីនេះ ប្រសិនបើមន្ត្រីណាម្នាក់ដែលមិនបានប្រតិបត្តិតាមច្បាប់ត្រូវតែទទួលទណ្ឌកម្មជាដាច់ខាត ដោយមិនត្រូវលើកលែងឲ្យឡើយ។
- **បំពេញកង្វះខាតផ្នែកបច្ចេកទេស៖** គួរតែឧបត្ថម្ភនូវឧបករណ៍ប្រើប្រាស់ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធានាឲ្យការអនុវត្តច្បាប់បានល្អត្រឹមត្រូវ និងមានបច្ចេកទេសក្នុងការបង្ក្រាបបទល្មើសស្របទៅតាមស្តង់ដា។ លើសពីនេះ ត្រូវបំពេញតាមការស្នើសុំរបស់បុគ្គលិកផ្នែកតុលាការដូចជាព្រះរាជអាជ្ញា ចៅក្រម និងក្រឡាបញ្ជីជាដើម ដើម្បីឲ្យមានសម្ភារៈក្នុងការបំពេញការងារឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ។
- **លុបបំបាត់ការអន្តរាគមន៍៖** គប្បីលុបបំបាត់ឲ្យបាននូវការអន្តរាគមន៍អ្នកដែលមានអំណាច មានឋានៈតួនាទីនៅក្នុងជួររាជរដ្ឋាភិបាល ដែលតែងតែលូកដៃចូលទៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាតុលាការដែលធ្វើឲ្យការបំពេញតួនាទីមិនទាន់បានល្អប្រសើរ។
- **បណ្តុះបណ្តាលជំនាញបច្ចេកទេស និងច្បាប់៖** គប្បីជ្រើសរើសមន្ត្រីរាជការ ក្រឡាបញ្ជី ព្រះរាជអាជ្ញា ចៅក្រម ដើម្បីឲ្យបម្រើការងារនៅតាមស្ថានប័នតុលាការឲ្យបានគ្រប់ចំនួន ដោយហេតុនៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនៅមានកង្វះមន្ត្រីវិស័យយុត្តិធម៌ច្រើននៅឡើយ។ ម្យ៉ាងទៀតត្រូវបង្កើតតុលាការតាមជំនាញ ដែលមិនទាន់មានគ្រប់ស្របតាមតម្រូវការ និងជំនាញឯកទេសនោះទេ ដូចជាតុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាលជាដើម ដែលជាហេតុធ្វើឲ្យមានការមមាញឹកខ្លាំងក្នុងការដោះស្រាយរឿងក្តីនីមួយៗ។
- **ផ្សព្វផ្សាយវិស័យយុត្តិធម៌ឲ្យកាន់តែទូលំទូលាយ៖** គួរធ្វើការផ្សព្វផ្សាយច្បាប់ឲ្យបានដល់ប្រជាពលរដ្ឋទូទៅ ដើម្បីបានយល់ដឹង និងការពារកុំឲ្យប្រព្រឹត្តបទល្មើសផ្សេងៗ ដែលអាចបណ្តាលឲ្យបាត់បង់នូវកិត្តិយស និងសេរីភាព ដោយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាដើម។

# ឯកសារយោង

# ឯកសារយោង


## ១. កម្រងឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។
- ច្បាប់ស្ដីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣, ០៦ មិថុនា ២០១៣។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

## ២. កម្រងឯកសារមេរៀន

- កុយ នាម និងឡុង បញ្ញាវុធ, ផ្សព្វផ្សាយដោយសមាគមច្បាប់ខ្មែរ, ២០០៦, *អយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប,* បោះពុម្ពលើកទីមួយ. ភ្នំពេញ។
- ន.ស.រ., ផ្សព្វផ្សាយដោយទំព័រស្វែងយល់ពីច្បាប់, *ប្រធានបទ៖ការតម្កល់រឿងទុកឥតចាត់ការ,* ឆ្នាំ២០១៧។
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, ២០១៥, *មេរៀននីតិវិធីព្រហ្មទណ្ឌ,* ភ្នំពេញ ។
- សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ, ២០០៨, *មេរៀននីតិព្រហ្មទណ្ឌ ផ្អែកលើអត្ថបទនៃសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧។*
- អ៊ី ម៉ាណូកា, ផ្សព្វផ្សាយដោយសាលាត្រាជូ, ២០១៥, *សំណេរសាកល្បង ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍,* ភ្នំពេញ ។

## ៣. គេហទំព័រ

- កម្មវិធីនាទីច្បាប់, មេធាវីហុង គីមសួន និងមេធាវីទៀង វុទ្ធា, *នីតិវិធីដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌ,* https://www.youtube.com/watch?v=bkxBKsVjMGU, (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២១) ។
- កម្មវិធីនាទីច្បាប់, *នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ,* https://www.youtube.com/watch?v=Slk1vDyE9R4&list=PL48iwV2gkPae77_dWISt6Vr6rZ9LG5NM&index=21, (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១) ។
- ភក្តីឡដ៏, ២០១៦, *សំណួរ-ចម្លើយសម្រាប់ការត្រៀមប្រលងផ្សេងៗទាក់ទងនឹងវិធានការនិន្នាការ,* http://pheakdeylaw.com/en/publication/19, (ចូលទស្សនាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១)
- សេង បារាំង. វាយោអេហ្វអឹម, ២០២១, *ភាពខុសគ្នានៃបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី,* https://vayofm.com/news/detail/107589-352984000.html, (ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២១) ។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** ពាក្យបណ្តឹងទៅកាន់អង្គការអយ្យការ។
- **ឧបសម្ព័ន្ធទី២៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។
- **ឧបសម្ព័ន្ធទី៣៖** ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។
- **ឧបសម្ព័ន្ធទី៤៖** លិខិតជូនដំណឹងអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការ។
- **ឧបសម្ព័ន្ធទី៥៖** ដីកាកោះហៅឲ្យចូលបំភ្លឺរបស់ចៅក្រមស៊ើបសួរ។
- **ឧបសម្ព័ន្ធទី៦៖** ដីកាបង្គាប់ឲ្យចាប់ខ្លួន។
- **ឧបសម្ព័ន្ធទី៧៖** ដីកាសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន។
- **ឧបសម្ព័ន្ធទី៨៖** ដីកាបង្គាប់ឲ្យឃុំខ្លួន។
- **ឧបសម្ព័ន្ធទី៩៖** ដីកាកោះហៅឲ្យចូលសវនាការ។
- **ឧបសម្ព័ន្ធទី១០៖** លិខិតឲ្យដំណឹងពីសាលក្រមព្រហ្មទណ្ឌ។
- **ឧបសម្ព័ន្ធទី១១៖** ពាក្យបណ្តឹងឧទ្ធរណ៍។
- **ឧបសម្ព័ន្ធទី១២៖** ពាក្យបណ្តឹងទាស់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី១**

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ [redacted] ភេទប្រុស ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៨០ សញ្ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ២៤៥ ផ្លូវបេតុង ភូមិស្លែងលើង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
ទូរស័ព្ទលេខ: ០១២ ២៥ ៨២ ៣២

**សូមគោរពជូន**

**លោក ព្រះរាជអាជ្ញានៃអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

សូមមានជ្រាប!

**កម្មវត្ថុ:** សុំប្តឹងពីឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិចិន មុខរបរ អ្នកមើលការខុសត្រូវរោងចក្រ អាសយដ្ឋាន ភូមិជ្រោយចង្វារ សង្កាត់សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ: [redacted]

ពីបទ: ប្រើហិង្សា(ប្រើប្រាស់កាំបិត ប៉ុងតោ និងដុំថ្ម) និងគម្រាម សម្លាប់ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤:៣០នាទី ស្ថិតនៅ គេហដ្ឋានរបស់ខ្ញុំបាទ ផ្ទះលេខ២៤៥ ផ្លូវបេតុង ភូមិស្លែងលើង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកព្រះរាជអាជ្ញា** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤:៣០នាទី ឈ្មោះ [redacted] បានមកឡូឡានៅមុខរបងផ្ទះរបស់ខ្ញុំបាទ ហើយបានដើរចូលមកក្នុងផ្ទះរបស់ខ្ញុំ ស្រាប់តែឃើញកាំបិតប៉ុងតោ ឈ្មោះ [redacted] បានស្ទុះទៅទាញកាំបិតប៉ុងតោ គម្រាមចង់កាប់សម្លាប់ខ្ញុំបាទ និងប្រពន្ធរបស់ខ្ញុំ បើមិនឲ្យលុយដែលជំពាក់ចំនួន ៣,៨៥២ដុល្លារអាមេរិក ដូចមានរូបភាព និងវីដេអូកាមេរ៉ា សុវត្ថិភាពស្រាប់។ ខ្ញុំ និងប្រពន្ធ បានសុំពន្យាពេលសិន តែឈ្មោះនេះ ស្រែកឡូឡា(និយាយជាភាសាចិន) មិនដឹងមានន័យអ្វី ហើយយាកាំបិតប៉ុងតោ រកកាប់ខ្ញុំ និងប្រពន្ធ តែប្រពន្ធរបស់ខ្ញុំបាទបានព្យាយាមលោម និងឃាត់គាត់ ទើបឈ្មោះ [redacted] ទុកកាំបិតវិញ ពេលនោះខ្ញុំបានរុញគាត់ចេញទៅក្រៅរបង និងបានបិទទ្វាររបង តែឈ្មោះ [redacted] បានរុញទ្វារ និងយកដុំថ្មមករកគប់ខ្ញុំ និងវាយខ្ញុំនិងដុំថ្ម ទោះខ្ញុំហាមឃាត់បែបណា ក៏មិនស្តាប់ ព្រោះពេលនោះឈ្មោះ [redacted] និយាយស្តាប់គ្នាមិនបាន ហើយដូចជាកំពេលចូល ហើយឈ្មោះនេះមករករឿងខ្ញុំ២ ទៅ៣ដងហើយ ដែលជាហេតុធ្វើឲ្យខ្ញុំនិងប្រពន្ធមានការភ័យខ្លាចជាខ្លាំង ខ្លាចថ្ងៃណាមួយឈ្មោះ [redacted] មកសំលាប់ខ្ញុំ និងប្រពន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើ **សូមលោកព្រះរាជអាជ្ញា** មេត្តាជួយចាត់ការលើឈ្មោះ [redacted] នេះតាមផ្លូវច្បាប់ ដើម្បីកុំឲ្យឈ្មោះនេះ បន្តគម្រាមសម្លាប់ និងប្រមាថអាយុជីវិតខ្ញុំ និងប្រពន្ធ របស់ខ្ញុំបាទបន្តទៀត និងសូមឲ្យឈ្មោះ [redacted] សងសំណងជំងឺចិត្ត ដល់ខ្ញុំបាទចំនួន ២០០០០$(**ពីរម៉ឺនដុល្លារអាមេរិក**)តាមការស្នើសុំរបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។

**សូម លោកព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩
ស្នាមមេដៃស្តាំ



[redacted]

ជូនភ្ជាប់មកជាមួយ
-រូបថតចំនួន ០៦សន្លឹក និងឌីសជាវីដេអូដែលយកចេញពីកាមេរ៉ា សុវត្ថិភាព

141

**ឧបសម្ព័ន្ធទី២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

លេខ:...1237...អ.យ.ច

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៧៤ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍លេខ ០៦៩ ល.ស ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា៖

-នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិក្រាំញ ឃុំក្រាំញ ស្រុកក្រាំញ ខេត្តពោធិ៍សាត់ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួល សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរសន្តិសុខ និងកម្មករសំណង់ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ជាទីតិជន កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុនគ្មាន ។ (ឃាត់ខ្លួនកាលពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០២០)

បានប្រព្រឹត្តល្មើសដូចតទៅ៖ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង២១និង១០នាទី នៅចំណុចមុខ HOTEL PREMIUM លើផ្លូវលេខ១២៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងរវាងរថយន្តមួយគ្រឿងម៉ាក NISSAN NAVARA ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ ភ្នំពេញ [redacted] បើកបរដោយជនសង្ស័យឈ្មោះ [redacted] ភេទប្រុស ទិសដៅពីត្បូងទៅជើង លុះមកដល់ចំណុចកើតហេតុខាងលើក៏បុកពីក្រោយរថយន្តមួយគ្រឿងទៀតម៉ាក KIA ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ [redacted] ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ភេទប្រុស ដែលចតនៅចិញ្ចើមផ្លូវ បណ្តាលឱ្យរថយន្តជ្រុលទៅបុកអ្នកថ្មើរជើងជនជាតិបរទេសចំនួន ០២នាក់ដែលកំពុងដើរឆ្លងផ្លូវធ្វើឱ្យរងរបួសធ្ងន់ម្នាក់ និងស្រាលម្នាក់ ហើយបន្តទៅបុកពីក្រោយរថយន្តម៉ាក LEXUS RX330 ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ [redacted] ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ភេទប្រុស ដែលចតនៅចិញ្ចើមផ្លូវ បន្ទាប់មកក៏ត្រូវប្រជាពលរដ្ឋនៅជិតនោះជួយអន្តរាគមន៍ចាប់ជនសង្ស័យ ប្រគល់ជូនសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង ។

អំពើខាងលើ គឺជាបទល្មើសៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកបានតម្រូវ បណ្ដាលឱ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅចំណុចមុខ HOTEL PREMIUM លើផ្លូវលេខ១៦៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**<u>សម្រេច</u>**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ

☑ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (ឃាត់ខ្លួន) ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកបានតម្រូវ បណ្ដាលឱ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅចំណុចមុខ HOTEL PREMIUM លើផ្លូវលេខ១៦៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

☑ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើឈ្មោះខាងលើដោយមូលហេតុៈ

ក. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

ខ. ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំជូត ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ. ថ្ងៃទី ..០៣.. ខែមីនា ឆ្នាំ២០២០

ជ.ព្រះរាជអាជ្ញា

[redacted]

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ: [redacted]
ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩
លេខ៖ ........[redacted]... អ.យ.ជ

# ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង** [redacted] **តំណាងអយ្យការ នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**
បានឃើញ:របាយការណ៍សំយោគលេខ:១៦៥/១៩ រ.ប.ក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា ៖**

១. អវត្តមានបទល្មើស
- ☐ ១.១.អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់
- ☐ ២.១.ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត
- ☐ ៣.១.ការដកពាក្យបណ្តឹង
- ☐ ៣.២.ការលើកលែងទោសជាទូទៅ
- ☐ ៣.៣.មរណភាពជនល្មើស
- ☐ ៣.៤.ផុតអាជ្ញាយុកាល
- ☐ ៣.៥.និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- ☐ ៣.៦.អាជ្ញាអស់ជំនុំ
- ☐ ៣.៧.ការសម្រុះសម្រួលជាមួយរដ្ឋ
- ☐ ៣.៨.ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្រុះសម្រួល
- ☐ ៣.៩.អភ័យឯកសិទ្ធិ
- ☐ ៣.១០.អនិយ័តភាពនៃនីតិវិធី
- ☐ ៣.១១.ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

☐ ៤.១.ការស្វែងរកមិនបានផល

☑ ៤.២.ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣.ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤.៤.ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥.អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦.ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

☐ ៤.៧.និយ័តកម្មដោយឯកឯង[3]

☐ ៤.៨.ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

☐ ៥.១.ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២.សន្ធានកម្ម[4]

☐ ៥.៣.អធិបញ្ញាផ្តល់ការព្យាបាល

☐ ៥.៤.ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ ព្រះរាជអាជ្ញា

☐ ៥.៥.និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

☐ ៥.៦.ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧.ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាពនៃសង្គមឬនៃវិជ្ជាជីវៈ

☐ ៥.៨.ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត

☐ ៦.១.ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

☐ ៧.១.ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

☐ ៨.១.ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ៖ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១៨និង៣០នាទី នៅចំណុចបរិវេណផ្ទះលេខ២៤៥ ផ្លូវបេតុង ភូមិស្លែងរលើង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណី ហិង្សាដោយចេតនា មួយបានកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ [redacted] បាននៅមុនពេលកើតហេតុជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ បានទៅផ្ទះរបស់ជនសង្ស័យឈ្មោះ [redacted] ដើម្បីទៅគិតលុយថ្លៃសាច់ទា ពេលនោះជនសង្ស័យបានលើកជើងធាក់ជនរងគ្រោះ តែជនរងគ្រោះគេចផុត ហើយជនសង្ស័យក៏ស្ទុះមកដាល់ជនរងគ្រោះមួយដៃចំភ្នែកខាងឆ្វេងបណ្តាលអោយប៉ោងហើមជាំ និងហូរឈាមតាមច្រមុះ រួចជនរងគ្រោះបានទូរស័ព្ទទៅមិត្ត

---

[2] ដើមបណ្តឹងឈប់ប្តឹង

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[4] ករណីវៃងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមាន ឱ្យឈប់ប្រព្រឹត្ត

[6] ករណីវៃងដោយច្បាប់

ក្ត ជនជាតិខ្មែរ ប្រាប់ថាមានគេវ៉ៃ។ បន្ទាប់មកសមត្ថកិច្ចក៏មកដល់សួរនាំ រួចនាំជនសង្ស័យមកប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបែកក្អម ដើម្បីធ្វើការសាកសួរតែម្តង។

បានឃើញៈចម្លើយរបស់ឈ្មោះ [redacted] បានបំភ្លឺនៅចំពោះមុខសមត្ថកិច្ចថាៈ នៅដើមឆ្នាំ ២០១៨ ខ្លួនបានស្គាល់ឈ្មោះ [redacted] និងបានរកស៊ីជាមួយគ្នាដោយឈ្មោះ [redacted] បានទទួល ទិញសាច់ទាពីខ្លួនទៅលក់បន្ត ហើយឈ្មោះ [redacted] បានទូទាត់អោយខ្លះ និងនៅជំពាក់ប្រាក់ចំនួន៣៨៥២$ ។នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ពេលរសៀល ខ្លួនបានបើករថយន្តចេញពីផ្ទះស្នាក់នៅតែម្នាក់ឯងក្នុងគោលបំណងទៅផ្ទះឈ្មោះ [redacted] ដើម្បីទារលុយថ្លៃសាច់ទា ពេលទៅដល់ផ្ទះ [redacted] បានជួបប្រពន្ធគាត់ រួចខ្លួននិយាយភាសាខ្មែរ ជាមួយប្រពន្ធគាត់ថាគិតលុយថ្លៃសាច់ទា ពេលនោះស្រាប់តែឈ្មោះ [redacted] ស្ទុះចេញពីក្នុងផ្ទះលើកជើងធាក់ខ្លួនតែគេចផុត ហើយឈ្មោះ [redacted] ក៏ស្ទុះមកដាល់ខ្លួនមួយដៃចំភ្នែកខាងឆ្វេងបណ្តាលអោយប៉ោងហើមជាំ និងហូរឈាមតាមច្រមុះ រួចខ្លួនបានតេទៅមិត្តភក្រ្តិជាជនជាតិខ្មែរ ជាអ្នកបកប្រែភាសាចិន ប្រាប់គាត់ថាមានគេវ៉ៃខ្លួន បន្ទាប់មកក៏ឃើញសមត្ថកិច្ចមកដល់សួរនាំ រួចក៏នាំឈ្មោះ [redacted] មកប៉ុស្តិ៍នគរបាលរដ្ឋបាល អូរបែកក្អម ហើយខ្លួនបានមកដាក់ពាក្យបណ្តឹងចោទប្រកាន់ឈ្មោះ [redacted] តែម្តង។

បានឃើញៈចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] បានបញ្ជាក់ថាៈ ខ្លួនមិនបានចូលមកបំភ្លឺតាមដីកាកោះដោយសារខ្លួនទើបតែទទួលបានដីកាកោះនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង៣និង៥០នាទី ជាហេតុធ្វើអោយខ្លួនមិនអាចចូលមកបំភ្លឺបាន ទើបតែថ្ងៃនេះខ្លួនសូមបំភ្លឺជូនតំណាងអយ្យការដូចតទៅ។ ខ្លួនសូមបដិសេធចំពោះពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចោលទាំងស្រុង ដោយហេតុខ្លួនមិនបានវាយទៅលើឈ្មោះ នេះទេ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] បានមកទារប្រាក់ថ្លៃទិញទាពីខ្លួន ប៉ុន្តែនៅពេលមកដល់ផ្ទះរបស់ខ្លួនស្រាប់តែឈ្មោះនេះបានមកឡូឡា និងបានទាញកាំបិតប៉័ងតោមកគំរាមមកលើខ្លួន ឃើញដូច្នេះ ប្រពន្ធរបស់ខ្លួន និងកម្មកររបស់ខ្លួន បានលួងយកកាំបិតចេញពីគាត់ ប៉ុន្តែគាត់មិនអោយ ខ្លួនក៏បានដេញអោយឈ្មោះនេះចេញពីផ្ទះរបស់ខ្លួន រួចក៏មានការឈ្លោះប្រកែកគ្នា។ ខណៈពេលដែលខ្លួនបានរុញឈ្មោះ [redacted] ចេញពីផ្ទះខ្លួន ឈ្មោះនេះនៅតែចង់ចូលផ្ទះខ្លួនទៀត ទើបនៅពេលច្រានគាត់ចេញបណ្តាលអោយគាត់ត្រូវនឹងសសរផ្ទះបណ្តាលអោយឈាមច្រមុះ។ ចំណែកឯភ្នែករបស់ឈ្មោះ [redacted] ខ្លួនមិនបានវាយទៅលើគាត់ទេ។ ខ្លួនសូមបញ្ជាក់ថា ខណៈពេលដែលមានទំនាស់ គឺភ្នែករបស់ឈ្មោះ [redacted] គឺមិនមានស្នាមហើមប៉ោងទេ ។បន្ទាប់ពីមានទំនាស់រួច សមត្ថកិច្ចក៏បាននាំខ្លួន ខ្លួនមកប៉ុស្តិ៍អូរបែកក្អមនៅវេលាម៉ោង០រសៀល ដោយនៅពេលនោះឈ្មោះ [redacted] មិនបានចូលមកទេ ។លុះដល់ម៉ោង៥រសៀល ទើបឈ្មោះ [redacted] មកដល់ប៉ុស្តិ៍ដែរ ហើយមេប៉ុស្តិ៍ក៏បានសួរនាំរឿងជំពាក់លុយទៅវិញ មិនបានសួរនាំរឿងហិង្សានោះទេ ប៉ុន្តែខ្លួនមិនបានឃើញភ្នែករបស់គាត់ហើមប៉ោងទេ ស្រាប់តែមួយសន្ទុះក្រោយមកគាត់ក៏បានចូលមកប៉ុស្តិ៍ម្តងទៀតស្រាប់តែភ្នែករបស់គាត់មានហូរឈាមថ្មីៗទៅវិញ ទើបគាត់ចោទប្រកាន់ថាខ្លួនវាយគាត់តែម្តង។ ខ្លួនសូមសំណូមពរសុំអោយតំណាងអយ្យការមេត្តាតម្កល់រឿងទុកឥតចាត់ការ ដោយហេតុខ្លួនមិនបានវាយទៅលើជនរងគ្រោះទេ គឺនៅថ្ងៃកើតហេតុខ្លួនគ្រាន់តែច្រានគេតែប៉ុណ្ណោះ។

បានឃើញៈដីកាកោះលើកទី១ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ លើឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញៈដីកាកោះលើកទី២ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ លើឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញៈចំណាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយចង្វារ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

បានឃើញៈ ឯកសារមួយចំនួនពាក់ព័ន្ធក្នុងសំណុំរឿង។

**<u>យល់ឃើញថាៈ</u>**

-តំណាងអយ្យការបានធ្វើការកោះហៅដើមបណ្តឹងឈ្មោះ [redacted] ភេទប្រុស អាយុ៥៣ឆ្នាំ តាមនីតិវិធីរួចរាល់ហើយ ប៉ុន្តែដើមបណ្តឹងពុំព្រមចូលមកបំភ្លឺនៅចំពោះមុខតំណាងអយ្យការ នេះស បញ្ជាក់អោយឃើញថា ដើមបណ្តឹងបានបោះបង់ចោលការទាមទារ និងបណ្តឹងរបស់ខ្លួន។

-តាមចំណាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយចង្វារ បានបញ្ជាក់ថាៈឆ្លងតាមការស្រាវជ្រាវរបស់នគរបាលមណ្ឌលទាំង៩ នៃប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយចង្វារមកឈ្មោះ [redacted] ភេទប្រុស នេះ រកពុំឃើញទេ ដោយពុំមានទីលំនៅច្បាស់លាស់។បច្ចុប្បន្នប៉ុស្តិ៍នឹងធ្វើការស្រាវជ្រាវបន្ត។

- គប្បីតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ ។

**<u>ហេតុដូច្នេះសម្រេច</u>**

តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខៈ [redacted] ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ទុកឥតចាត់ការ។

ថ្ងៃចន្ទ......០៤រោច ខែបុស្ស. ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី13 ខែមករា ឆ្នាំ២០២០

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី៤**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខៈ 719 អ.យ.ណ

# លិខិតជូនដំណឹង

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជម្រាបមកលោក [redacted] មានអាសយដ្ឋានសព្វថ្ងៃស្នាក់នៅផ្ទះលេខ២៤៥ ផ្លូវបេតុង ភូមិ

ស្លែងរលើង សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

ស្បិតពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់លោកដែលប្តឹងលើឈ្មោះ [redacted]

ភេទ ប្រុស អាយុ ៥៣ឆ្នាំ ជនជាតិចិន ដែលមានអាសយដ្ឋានស្នាក់នៅភូមិជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណ្ឌ

ជ្រោយចង្វារ រាជធានីភ្នំពេញ ពីបទៈ ប្រើហិង្សា (កាំបិត ប៉ុងតោ និងដុំថ្ម) និងគម្រាមថានឹងសម្លាប់ ។

នោះយើងបានសម្រេចៈ តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខៈ [redacted] ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ

២០១៩ ទុកឥតចាត់ការ តាមដីកាសម្រេចលេខ៖ [redacted]........អ.យ.ណ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០២០

រួចហើយ ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

យើង..........................................................................................

បានប្រគល់លិខិតជូនដំណឹងនេះដល់ឈ្មោះ...............................................

..................................................................................................

ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ........................ផ្លូវ......................ក្រុម.................

ភូមិ........................ឃុំ-សង្កាត់..............................ស្រុកខណ្ឌ......................

ខេត្ត-រាជធានី..............................នៅថ្ងៃទី...........ខែ....................ឆ្នាំ..............

ហើយបានប្រាប់ថា បើមិនសុខចិត្តនឹង..................................................

..................................................................................................

របស់តំណាងអយ្យការនេះទេ ត្រូវចូលទៅប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

អ្នកប្រគល់

អ្នកទទួល

ហត្ថលេខា ឬផ្តិតមេដៃ

[redacted]

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៧៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិបារាំង ជាភ្ញៀវទេសចរណ៍ កាន់លិខិតឆ្លងដែនលេខ [redacted] មានទីលំនៅបច្ចុប្បន្នស្នាក់នៅសណ្ឋាគារ HOTEL PREMIUM លើផ្លូវលេខ ១២៣ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ **ជាជនរងគ្រោះ** ។

ឲ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង០៨:៣០ នាទីព្រឹក ជាកំហិត (នៅជាន់ទី៥ បន្ទប់"ច១") ។

ដើម្បីៈ ឆ្លើយបំភ្លឺ ។

ពីអង្គហេតុៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពភាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកបានកម្រូម បណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចមុខ HOTEL PREMIUM លើផ្លូវលេខ១២៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

សាម៉ីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះ ឲ្យបានទាន់ពេលវេលា និងមេត្តាជួយយកលិខិតផ្សេងៗដែលទាក់ទិននឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃសុក្រ ០៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

[redacted]

យ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី៦**

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ៤៥៥ ច-ដ.ច.ន

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: [redacted] អ.យ.ដ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងឱ្យស៊ើបសួរលេខ: [redacted] ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ [redacted] ព្រ.ម ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២១ ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់យល់ឃើញថា**

ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុន អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៣៨ ផ្លូវលេខ ៤១BT ភូមិក្បាលទំនប់១ សង្កាត់បឹងទំពន់ទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ។

ត្រូវចោទពីបទ: **ប្រើប្រាស់លិខិតក្លែងនិងក្លែងបន្លំឯកសារសាធារណៈ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៨ និងមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

**យល់ឃើញថា** ជនត្រូវចោទបន្ទាប់ពីប្រព្រឹត្តបទល្មើសហើយបានរត់គេចខ្លួន ។

-តាមដីកាបញ្ជូនឱ្យឆ្លើយលេខ [redacted] ព្រ.ម ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២១ តំណាងអយ្យការបានឯកភាពលើការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] នេះដែរ ។

-ដើម្បីឱ្យការស៊ើបសួរមានលក្ខណៈគ្រប់គ្រាន់តាមនីតិវិធី គប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] មកចំពោះមុខចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបំភ្លឺការពិត ។

**ហេតុដូច្នេះសម្រេច**

១-ឱ្យចាប់ខ្លួនឈ្មោះ [redacted] ដែលមានអត្តសញ្ញាណខាងលើនេះ ។

២-បញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ៕

ថ្ងៃ[illegible].....ខែចេត្រ ឆ្នាំជូតទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២១**
**ក្រឡាបញ្ជី**

[redacted]

**ឧបសម្ព័ន្ធទី៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
បន្ទប់ស៊ើបសួរ "ច"
លេខស៊ើបសួរ ៖ ១១១៧/០៤.០៣.២០២០
លេខ 1915 ដ.ក.ស

## ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញមាត្រា ២០៣, ២០៤, ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៧៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១២៣៧ រ.យ.ប ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខ មានទីកន្លែងកំណើត ភូមិក្រវ៉ាញ ឃុំក្រវ៉ាញ ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះជួល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] កម្រិតវប្បធម៌ថ្នាក់ទី៦ ជានីតិជន ទោសពីមុនគ្មាន ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖

***បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពភារកិច្ចដែលបានបញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកបានតម្រូវ បណ្ដាលឲ្យរបួសដល់អ្នកដទៃ*** ប្រព្រឹត្តនៅចំណុច មុខ HOTEL PREMIUM លើផ្លូវលេខ១២៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

-បានឃើញ កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង ។

-បានឃើញ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់**ភាគី** ។

### I.ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១/ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ត្រូវចោទពីបទ ***បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពភារកិច្ចដែលបានបញ្ញត្តិស្ដីពីចរាចរណ៍ផ្លូវគោកបានតម្រូវ បណ្ដាលឲ្យរបួសដល់អ្នកដទៃ*** ។

២/ប្រព្រឹត្តនៅចំណុច មុខ HOTEL PREMIUM លើផ្លូវលេខ១២៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ ។

៣/ការពិភាក្សាដេញដោលចំពោះមុខត្រូវបានធ្វើឡើងតាមនីតិវិធីរួចរាល់ហើយ ។

៤/កំពាលាងអយ្យការបានស្នើសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកលើសំអាងហេតុដូចតទៅ៖

☑ការពារភស្តុតាង ឬតម្រុយជាសម្ភារៈ

☑ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធី

II.សំអាងហេតុសេចក្តីសម្រេច

១/ជនត្រូវចោទត្រូវចោទពីបទមជ្ឈិម ដែលច្បាប់តម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ ។

២/ជាផលវិបាកយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានសារៈសំខាន់ដើម្បី៖

☐រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☑បង្ការបទល្មើសកុំឲ្យកើតមានជាថ្មី

☐រារាំងកុំឲ្យមានការគាបសង្កត់សាក្សី ឬជនរងគ្រោះ

☑ការពារភស្តុតាង ឬតម្រុយជាសម្ភារៈ

☑ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធីដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរឹងនិងមានប្រសិទ្ធិភាពអាចធានាឲ្យមានការបំពេញកិច្ចប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ ។

**<u>សម្រេច</u>**

ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ជាបណ្តោះអាសន្នរយៈពេលអតិបរមា ។

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

ចៅក្រមស៊ើបសួរ

[redacted]

**ឧបសម្ព័ន្ធទី៨**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ច១"

លេខ ៖ 2802 "ច១" ដ.ឃ.ដ

# ដីកាបង្គាប់ឲ្យឃុំខ្លួន

**យើង** [redacted] **ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។**

-បានឃើញមាត្រា ២០៦,២១៩,២២០,២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៧៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ១១១៧ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១២៣៧ អ.យ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខ មានទីកន្លែងកំណើត ភូមិក្រវ៉ាញ ឃុំក្រវ៉ាញ ស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះជួល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] កម្រិតវប្បធម៌ថ្នាក់ទី៦ ជានីតិជន ទោសពីមុនគ្មាន ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖ ***បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបានប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកបានតម្រូវ បណ្តាលឲ្យរបួសដល់អ្នកដទៃ*** ប្រព្រឹត្តនៅចំណុច មុខHOTEL PREMIUM លើផ្លូវលេខ១២៣ សង្កាត់បឹងទំពុន១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ 1915 "ច១" ដ.ព.ស ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**<u>បង្គាប់</u>**

១/ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ទៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ។

២/ឲ្យប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) ទទួលយកជននេះ និងឃុំខ្លួនជននេះរហូតដល់មានបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣/ឲ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

ថ្ងៃពុធ [illegible] ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

[illegible] ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០

ចៅក្រមស៊ើបសួរ

[illegible]

[illegible] 4 [illegible] 2020

[redacted]

[redacted]

**ឧបសម្ព័ន្ធទី៩**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងខេត្តកំពង់ស្ពឺ**

## ដីកាកោះអញ្ជើញឲ្យចូលសវនាការ

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ : [redacted] ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១៨ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: [redacted] ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

អញ្ជើញឈ្មោះ: [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២០ ផ្លូវលេខ១៨ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ: [redacted] មានកូនចំនួន ១នាក់ ឲ្យចូលទៅកាន់សាលាដំបូងខេត្តកំពង់ស្ពឺ *នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៨.៣០ នាទីព្រឹក* នៅសាលសវនាការអក្សរ (A) ជាកំហិតដើម្បីជំនុំជម្រះ។

ពីដំណើររឿង: *គំរាមកំហែងថានឹងសម្លាប់ និងហិង្សាកេរ្តិ៍ជាសាធារណៈ* ប្រព្រឹត្តនៅចំណុចភូមិព្រៃរោង ឃុំរការកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២០,២១,២២ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៣, ៣០៥ នៃក្រមព្រហ្មទណ្ឌ។

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ឋានៈ ចៅក្រម

**តំណាងអយ្យការ**

-លោក [redacted] ឋានៈ ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ឋានៈ ជាក្រឡាបញ្ជី

សាមីខ្លួនមានសិទ្ធិពឹងពាក់មេធាវីឲ្យការពារខ្លួនបាន និងត្រូវចូលខ្លួនឲ្យបានទាន់ពេលវេលាដោយយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី ... ខែ ... ឆ្នាំ២០២១

**តំណាងអយ្យការ**

[redacted]

**ឧបសម្ព័ន្ធទី១០**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# លិខិតឲ្យដំណឹងពីសាលក្រមកំបាំងមុខ

សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌលេខ
[redacted]
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧
លេខ ១៧០ លក្រ

យើង [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ជម្រាបមកឈ្មោះ [redacted] ភេទស្រី អាយុ៥៦ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៣១ ផ្លូវលេខ៥៥៤កែងផ្លូវលេខ៣១៣ ភូមិ១០ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ឲ្យបានដឹងថាតាមសាលក្រមកំបាំងមុខលេខ [redacted] ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីដូចខាងក្រោម៖

១.ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ៥០០.០០០ (ប្រាំសែន)រៀល ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ សងសំណងជម្ងឺចិត្តសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីលោក [redacted] និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

សាមីខ្លួនមានសិទ្ធិប្តឹងទាស់នឹងសាលក្រមនេះក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីពេលបានទទួលដំណឹងពីសាលក្រមនេះ និងមានរយៈពេល១ខែ ដើម្បីប្តឹងឧទ្ធរណ៍គិតចាប់ពីពេលបានទទួលដំណឹងពីសាលក្រមនេះ។

ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ពស២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]

**ឧបសម្ព័ន្ធទី១១**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹងឧទ្ធរណ៍

យើងខ្ញុំឈ្មោះ [redacted] អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិពោធិ៍ ឃុំជំណាក់រាំង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងខេត្តកំពង់ស្ពឺ**

**កម្មវត្ថុ:** សុំប្ដឹងឧទ្ធរណ៍សាលក្រមព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០២១ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់ **សាលាដំបូងខេត្តកំពង់ស្ពឺ គឺប្ដឹងគ្រប់ចំណុចសេចក្ដីសម្រេចទាំងមូលនៃសាលក្រម។**

**យោង:** -សាលក្រមព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០២១ របស់ **សាលាដំបូងខេត្តកំពង់ស្ពឺ ។**

-សំណុំរឿងព្រហ្មទណ្ឌលេខ: [redacted] ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់ **សាលាដំបូងខេត្តកំពង់ស្ពឺ ។**

សេចក្ដីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ សាលក្រមព្រហ្មទណ្ឌដែលបានសម្រេចខាងលើនេះមានភាពអយុត្តិធម៌បំផុតមកលើរូបយើងខ្ញុំ ដែលធ្វើឲ្យយើងខ្ញុំ មិនអាចទទួលយកបាននូវសេចក្ដី សម្រេចរបស់ **សាលាដំបូងខេត្តកំពង់ស្ពឺ** ឡើយ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកពាក្យបណ្ដឹងឧទ្ធរណ៍របស់យើងខ្ញុំទៅតាមផ្លូវច្បាប់ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅខេត្តកំពង់ស្ពឺ ,ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

**ស្នាមមេដៃស្ដាំ**

[redacted] [redacted]

**ឧបសម្ព័ន្ធទី១២**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងទាស់

ខ្ញុំមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យមេធាវី ក្រុមមេធាវី **យុត្តិធម៌ និងសហការី** ផ្ទះលេខ៤២០ ផ្លូវ៣៧១ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងខេត្តត្បូងឃ្មុំ**

*សូមទានជ្រាប។*

**កម្មវត្ថុ:** សុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌកំបាំងមុខ [redacted] ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ របស់ **សាលាដំបូងខេត្តត្បូងឃ្មុំ គឺប្តឹងគ្រប់ចំណុចសេចក្តីសម្រេចទាំងមូលនៃសាលក្រម។**

**យោង:** -សាលក្រមព្រហ្មទណ្ឌកំបាំងមុខ លេខ [redacted] ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០២០ របស់ **សាលាដំបូងខេត្តត្បូងឃ្មុំ។**

-សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ របស់ **សាលាដំបូងខេត្តត្បូងឃ្មុំ ។**

-លិខិតប្រគល់សិទ្ធិ របស់ឈ្មោះ [redacted] ភេទប្រុស និងឈ្មោះ [redacted] ភេទស្រី ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: សាលក្រមព្រហ្មទណ្ឌដែលមានចែងក្នុងកម្មវត្ថុខាងលើនេះ គឺតុលាការបានសម្រេចមានភាពអយុត្តិធម៌បំផុតមកលើកូនក្តីខ្ញុំបាទ ដែលធ្វើឲ្យកូនក្តីខ្ញុំបាទមិនអាចទទួលយកបាននូវសេចក្តីសម្រេចរបស់ **តុលាការខេត្តត្បូងឃ្មុំ** ឡើយ និងបានប្រគល់សិទ្ធិដល់ខ្ញុំបាទជាមេធាវី ដើម្បីប្តឹងទាស់នឹង សាលក្រមព្រហ្មទណ្ឌខាងលើនេះ ជំនួស។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកពាក្យបណ្តឹងទាស់របស់ខ្ញុំបាទទៅតាមផ្លូវច្បាប់ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃអង្គារ ០៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅត្បូងឃ្មុំ ,ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

**ហត្ថលេខា និងត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

[redacted]